# ការងារផ្ទះ ៖

# ជាការងាររបស់អ្នកណា?

ការសិក្សាស្រាវជ្រាវអំពីតួនាទីយេនឌ័រ ការងារថៃទាំគ្មានប្រាក់កម្រៃ និងបន្ទុកផ្លូវចិត្តនៅកម្ពុជា។

កិច្ចការស្រាវជ្រាវបែបចូលរួម
ផ្អែកលើគោលការណ៍
លទ្ធិស្ត្រីនិយម

**ឆ្នាំ២០២២**

ការស្រាវជ្រាវនេះអាចសម្រេចបានដោយជោគជ័យដោយមានការគាំទ្រមូលនិធិសប្បុរសពីម្ចាស់ជំនួយរបស់យើង។

# តារាងមាតិកា


១.០
សេចក្តីផ្តើម

២.០
វិធីសាស្ត្រ

៣.០
ការត្រួតពិនិត្យផ្នែកអក្សរសាស្ត្រ

៤.០
តើការងារផ្ទះជាការងាររបស់អ្នកណា? ស្ថានភាពបច្ចុប្បន្ន
៤.១ ការយល់ឃើញអំពី ការងារផ្ទះ
៤.២ ស្ថានភាពនៃបន្ទុកផ្លូវចិត្ត?

៥.០
ការយល់ឃើញអំពីមូលហេតុ៖ កត្តាជម្រុញ
៥.១ កត្តាវប្បធម៌
៥.២ កត្តាសង្គម
៥.៣ កត្តាអន្តរជំនាន់
៥.៤ កត្តាភូមិសាស្ត្រ

៦.០
នៅក្នុងពិភពដ៏តតខ្វោះ... ការយល់ឃើញអំពីស្ថានភាព
នៃការបែងចែកការងារផ្ទះដែលសមស្រប
៧.០
ការវិវត្តន៍នៃបរិបទសង្គម... ការយល់ឃើញអំពីការផ្លាស់ប្តូរជំនាន់

៨.០
សេចក្តីសន្និដ្ឋាន

## ក្រុមការងារក្លាហាន

បុណ្យ រចនា
Kate Seewald
ពេជ្រ ភារ័ក្ស
គង់ ស្រីនូ

## សមាជិកក្រុមអ្នកស្រាវជ្រាវសកម្មនៅមូលដ្ឋាន

មេត មន្ថារី
ហឿ សុខធារ:
មឹង ច័ន្ទសុម៉ានីតា
សុង ដាភា
គង់ សាកានា
វ៉ាន់ ច័ន្ទកញ្ញា
ស៊ាម សុមន្ថា
សុខ ដាំរ៉ុង
សុភា ពេជ្រមុន្នីទា
អាន សុភាវត្តី
លន់ ស្រីរីន

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមក្នុងគម្រោងនេះ ព្រមទាំងចំណាយពេលដ៏មានតម្លៃរបស់ពួកគេដើម្បីជួយឱ្យកិច្ចស្រាវជ្រាវនេះប្រព្រឹត្តិទៅដោយជោគជ័យ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ អង្គការសហគមន៍ឥន្ទធនូកម្ពុជា (RoCK) ចំពោះជំនួយផ្នែកបច្ចេកទេសវាក្យស័ព្ទដ៏មានតម្លៃ។

ក្រុមការងារក្លាហានក៏សូមថ្លែងអំណរគុណជាពិសេស និងកោតសរសើរយ៉ាងខ្លាំងដល់ក្រុមស្រាវជ្រាវសកម្មនៅមូលដ្ឋាន។ អ្នកស្រាវជ្រាវវ័យក្មេងទាំងនេះបានចំណាយពេលវេលា ក៏ដូចជាការប្តេជ្ញាចិត្ត និងពោពេញដោយថាមពលដែលធ្វើឲ្យកិច្ចការស្រាវជ្រាវកាន់តែមានភាពប្រសើរឡើង។

# សន្ទានុក្រម

**ស៊ីសយេនឌ័រ (អ្នកកំណត់យេនឌ័រស្របតាមភេទពីកំណើត)**
បុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និង/ឬការបង្ហាញយេនឌ័រស្របនឹងភេទកំណើតរបស់ពួកគេ។ ស៊ីសយេនឌ័រគឺជាអត្តសញ្ញាណយេនឌ័រ មិនមែនជានិន្នាការភេទទេ។

**UNESCAP**
គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក

**អត្តសញ្ញាណយេនឌ័រ**
អារម្មណ៍ និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗអំពីយេនឌ័រ ដែលអាចស្រប ឬមិនស្របទៅនិងភេទកំណើតរបស់បុគ្គលនោះ។

**អ្នកស្រឡាញ់ភេទផ្ទុយគ្នា**
គឺជាពាក្យដែលប្រើដើម្បីពណ៌នាបុគ្គលមានភេទកំណើតជាស្ត្រី និងកំណត់អត្តសញ្ញាណយេនឌ័រជាស្ត្រី និងមានការទាក់ទាញផ្នែកមនោសញ្ចេតនា ស្នេហា និង/ឬអារម្មណ៍ចំពោះអ្នកមានភេទកំណើតជាបុរស និងកំណត់អត្តសញ្ញាណជាបុរស ឬប្រើដើម្បីពណ៌នាដល់បុគ្គលដែលមានភេទកំណើតជាបុរស និងកំណត់អត្តសញ្ញាណយេនឌ័រជាបុរស និងមានមនោសញ្ចេតនា ស្នេហា និង/ឬអារម្មណ៍ចំពោះស្ត្រី។

**ប្តី ប្រពន្ធ**
ដើម្បីផ្តល់ភាពងាយស្រួលសម្រាប់ការអានរបាយការណ៍នេះ និងដោយសារតែដៃគូស្និទ្ធស្នាលដែលមិនទាន់រៀបការនៅមិនទាន់មានស្ថិតិច្បាស់លាស់ក្នុងប្រទេសកម្ពុជា យើងប្រើប្រាស់ពាក្យ 'ប្តី' និង 'ប្រពន្ធ' ជាជាងពាក្យ 'ដៃគូស្និទ្ធស្នាល' នៅក្នុងរបាយការណ៍នេះ។ ចំណុចនេះមិនមែនមានន័យថា ទំនាក់ទំនងដៃគូស្និទ្ធស្នាលនៃយេនឌ័រណាមួយមានសុពលភាពទាបជាងទំនាក់ទំនងដែលបានរៀបការ (តាមប្រពៃណី ឬតាមច្បាប់) នោះទេ។

**អ្នកស្រលាញ់ភេទដូចគ្នា (LGBTQ+)**
ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អ្នកដែលមិនទាន់កំណត់យេនឌ័រ។ល។ អក្សរកាត់ និងបម្រែបម្រួលនៃពាក្យទាំងអស់នេះ បានចាប់ផ្តើមប្រើប្រាស់តាំងពីទសវត្សរ៍ឆ្នាំ ១៩៨០ ដើម្បីពណ៌នាអំពីភាពចម្រុះនៃសហគមន៍មនុស្សដែលមាននិន្នាការភេទ និង/ឬអត្តសញ្ញាណយេនឌ័រខុសពី 'អ្នកស្រលាញ់ភេទផ្ទុយគ្នា' និង 'អ្នកកំណត់យេនឌ័រស្របតាមភេទកំណើត'។

**បន្ទុកផ្លូវចិត្ត/ពលកម្មបញ្ញា**
បន្ទុកផ្លូវចិត្តសំដៅដល់ពលកម្មបែបអរូបី (ការគិត និងអារម្មណ៍) ពាក់ព័ន្ធនិងការថែទាំផ្ទះនិងសមាជិកគ្រួសារដើម្បីធានានូវភាពសុខដុមរមនានៅក្នុងគ្រួសារ។ កិច្ចការទាំងនោះរួមមាន ការរៀបចំ ការធ្វើផែនការ និងការចងចាំនូវកិច្ចការចាំបាច់ដែលត្រូវធ្វើជាប្រចាំ ដើម្បីគ្រប់គ្រងជីវិត និងបុគ្គលគ្រប់រូបដែលរស់នៅក្នុងបន្ទុករបស់ពួកគេ។ នៅក្នុងទំនាក់ទំនងគូស្វាមីភរិយាភេទផ្ទុយគ្នា បន្ទុកផ្លូវចិត្តត្រូវបានបង្ហាញយ៉ាងជាប់លាប់ ថាជាបន្ទុកដែលរ៉ាប់រងយ៉ាងច្រើនលើសលប់ដោយស្ត្រី។

**និន្នាការភេទ**
ការទាក់ទាញផ្នែករាងកាយ មនោសញ្ចេតនា និង/ឬផ្លូវអារម្មណ៍របស់បុគ្គលចំពោះយេនឌ័រជាក់លាក់មួយ ឬច្រើន។

**អ្នកប្តូរយេនឌ័រ**
បុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និង/ឬការបង្ហាញយេនឌ័រ ដែលជាទូទៅមិនស្របជាមួយនឹងភេទកំណើត។ នេះគឺជាអត្តសញ្ញាណយេនឌ័រ មិនមែនជានិន្នាការភេទនោះទេ (មើលបន្ថែម៖ RoCK, ២០១៩)។

**ការងារថែទាំគ្មានប្រាក់កម្រៃ**
ការងារថែទាំគ្មានប្រាក់កម្រៃ៖ អង្គការពលកម្មអន្តរជាតិ (ILO) កំណត់និយមន័យ ការងារថែទាំគ្មានប្រាក់កម្រៃ ជាសកម្មភាពពាក់ព័ន្ធនឹងការងារថែទាំគ្រួសារប្រចាំថ្ងៃដែលមិនទទួលបានប្រាក់កម្រៃ ដូចជាការចម្អិនអាហារ ការបោសសម្អាត ការដើរទិញឥវ៉ាន់ ការបោកគក់ ការមើលថែទាំកូនជាដើម។ល។ ទាំងនេះសម្តៅលើ “សកម្មភាព និងទំនាក់ទំនងដែលពាក់ព័ន្ធនឹងការបំពេញតម្រូវការរាងកាយ ផ្លូវចិត្ត និងអារម្មណ៍របស់មនុស្សពេញវ័យ និងកុមារ មនុស្សចាស់ និងក្មេង អ្នកមានរាងកាយទន់ខ្សោយ និងមានកម្លាំងមាំមួន” (សូមមើល៖ ILO, ២០១៨)។

១

# សេចក្តីផ្តើម

# ១
# សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅតាមបណ្តាប្រទេសជាច្រើនទៀតនៅជុំវិញពិភពលោកដែរ ការកំណត់តួនាទីយេនឌ័រនៅតែបន្តមានឥទ្ធិពលទៅលើសកម្មភាពការងារនៅក្នុងផ្ទះ និងទំនាក់ទំនងក្នុងគ្រួសារ។ ការកំណត់តួនាទីយេនឌ័រនេះគឺផ្អែកលើបទដ្ឋានសង្គម និងបន្តពង្រឹងបទដ្ឋានសង្គមដែលជះឥទ្ធិពលលើរបៀបដែលសមាជិកនៅក្នុងគ្រួសារប្រាស្រ័យទាក់ទងគ្នា។ ជាលទ្ធផល បទដ្ឋានសង្គមទាំងនេះជះឥទ្ធិពលលើការរំពឹងទុករបស់សមាជិកគ្រួសារចំពោះគ្នាទៅវិញទៅមកព្រមទាំងកំណត់អំពីរបៀបដែលសមាជិកម្នាក់ៗបែងចែកការងារផ្ទះ ការសម្រេចចិត្តលើការចំណាយនៅក្នុងជីវភាពប្រចាំថ្ងៃ។

របាយការណ៍សិក្សាស្រាវជ្រាវពាក់ព័ន្ធនិងការងារថែទាំគ្មានប្រាក់កម្រៃ (UCW) ជាច្រើនបានចង្អុលបង្ហាញថា ការងារថែទាំគ្មានប្រាក់កម្រៃបង្កផលប៉ះពាល់វិសមាមាត្រធ្ងន់ធ្ងរដល់ស្ត្រី និងក្មេងស្រីនៅទូទាំងពិភពលោក។ ជាឧទាហរណ៍ ការងារថែទាំគ្មានប្រាក់កម្រៃ គឺជាឧបសគ្គចម្បងដែលរារាំងស្ត្រីពីការចូលរួម ការបន្ត និងការរីកចម្រើននៅក្នុងអាជីពការងាររបស់ពួកគេ [១]។ ទោះបីជា ជាក់ស្តែងទៅ ស្ត្រី និងបុរសភាគច្រើននៅទូទាំងពិភពលោក បានរាយការណ៍ថាពួកគេមានទំនោរចង់ធ្វើការងារដែលមានប្រាក់កម្រៃក៏ដោយ ការស្រាវជ្រាវក្នុងឆ្នាំ២០១៨ របស់អង្គការពលកម្មអន្តរជាតិ (ILO) បានបង្ហាញថា ស្ត្រីដែលមានអាយុក្នុងវ័យធ្វើការប្រហែល ៦០៦ លាននាក់បានរាយការណ៍ថា ពួកគេមិនអាចទៅប្រកបការងារមានប្រាក់កម្រៃបាននោះទេ ដោយសារតែពួកគេត្រូវធ្វើការងារថែទាំគ្មានប្រាក់កម្រៃ។ ខណៈដែល មានបុរសត្រឹមតែ ៤១ លាននាក់ប៉ុណ្ណោះដែលបាន រាយការណ៍ថា ពួកគេមិនអាចទៅប្រកបការងារបានដោយសារហេតុផលដូចគ្នា [២] ។




ចំនួនម៉ោងដែលស្ត្រីធ្វើការងារថែទាំគ្មានប្រាក់កម្រៃ ចំនួនម៉ោងដែលបុរសធ្វើការងារថែទាំគ្មានប្រាក់កម្រៃ

ប្រភព [៣]៖ OECD, ២០១៩

ដូចដែលបានបង្ហាញដោយ អង្គការអាកសិនអេដអន្តរជាតិ វិសមភាពនៃការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃនឹងជម្រុញឱ្យមានការរំលោភបំពានសិទ្ធិមនុស្សដែលបានទទួលសម្គាល់នៅក្នុងច្បាប់ជាតិ និងអន្តរជាតិ [៤]។ ឧទាហរណ៍៖

*"...អសមត្ថភាពក្នុងការអភិវឌ្ឍជីវភាពរស់នៅដោយស្វ័យភាពគឺជាប់ទាក់ទងទៅនឹងការរំលោភបំពានសិទ្ធិការងារ... ដូចគ្នាដែរ ការធ្លាក់ខ្លួនឈឺនិងភាពនឿយហត់ដោយសារតែធ្វើការងារហួសកម្រិតគឺជាប់ទាក់ទងទៅនឹងការរំលោភសិទ្ធិទទួលបានពេលលំហែរ និងការសម្រាក... ឬសិទ្ធិទទួលបានស្តង់ដារនៃការរស់នៅដោយថ្លៃថ្នូរ។*

*ទស្សនវិស័យផ្អែកលើមូលដ្ឋានសិទ្ធិអនុញ្ញាតឱ្យយើងវិភាគពីរបៀបដែលការងារថៃទាំលើសកម្រិតបង្កផលប៉ះពាល់ដល់សិទ្ធិបុគ្គល និងសិទ្ធិសមូហភាពផ្សេងទៀត ដូចជាសិទ្ធិសុខភាព សិទ្ធិទទួលបានការអប់រំ ឬការចូលរួមផ្នែកនយោបាយ ដោយសារតែអ្នកថៃទាំដែលធ្វើការហួសកម្រិត គ្មានពេលវេលា លទ្ធភាព សុខភាព ថាមពល ឬសមត្ថភាពដើម្បីអនុវត្តសិទ្ធិទាំងនោះឲ្យបានពេញលេញឡើយ" [៥]*

ទោះបីជាមានការយល់ដឹងអំពីផលប៉ះពាល់សិទ្ធិមនុស្សដែលបណ្តាលមកពីភាពអយុត្តិធម៌នៃការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃរួចមកហើយ តើមូលហេតុអ្វីបានជាមនុស្សជាច្រើននៅតែប្រកាន់ទស្សនៈថា ស្ត្រីបាន 'ជ្រើសរើស' ធ្វើជាអ្នកគ្រប់-គ្រង និងរ៉ាប់រងការងារភាគច្រើននៃការថៃទាំគ្មានប្រាក់កម្រៃ ឬមានការសន្មតថា ស្ត្រីមានភាពប៉ិនប្រសប់ក្នុងការធ្វើកិច្ចការទាំងនេះពីកំណើត?

គេអាចចោទសួរថាតើស្ត្រីពិតជា 'ជ្រើសរើស' ធ្វើការងារនេះមែន ឬ ដោយសារតែពួកគេទទួលរងនូវឥទ្ធិពលនៃការសន្មតថាស្ត្រីមានសន្តានចិត្តចេះយកអាសារតាំងពីកំណើត ឬ ដោយសារតែនៅក្នុងប្រទេសដែលមានអត្រាខ្ពស់នៃអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល ស្ត្រីត្រូវជ្រើសរើសធ្វើការងារថៃទាំគ្មានប្រាក់កម្រៃដោយសារតែស្ថានភាពនៃការត្រួតត្រាដោយបង្ខិតបង្ខំធ្ងន់ធ្ងរមកលើពួកគេ[៦]។

កត្តារួមចំណែកមួយទៀត ដែលផ្អែកលើទិដ្ឋភាពជាក់ស្តែង ស្ត្រីជ្រើសរើសធ្វើការងារទាំងអស់នេះ ដោយសារតែភាពចំបាច់ដែលមិនអាចទុកចោលបាន។ ក្នុងករណីនេះ តើបុរសដែលស្ថិតក្នុងទំនាក់ទំនងភេទផ្ទុយគ្នា គប្បីរួមចំណែក និងបំពេញកាតព្វកិច្ចរបស់ខ្លួនដោយរបៀបណា?

ការឆ្លើយតបចំពោះសំណួរនេះគឺពោពេញដោយភាពស្មុគស្មាញយ៉ាងខ្លាំង និងជំពាក់ជំពិនដោយកត្តាជាច្រើន។ ដូច្នេះការសិក្សាស្រាវជ្រាវនេះមិនព្យាយាមឆ្លើយតបនឹងបញ្ហាទាំងនេះឱ្យបានទាំងស្រុងនោះទេ។ ការសិក្សានេះផ្តល់នូវភស្តុតាងថ្មីៗដែលឆ្លុះបញ្ចាំងតថភាពនៃការបែងចែកការងារក្នុងគ្រួសារនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន៖ ពោលគឺការយល់ឃើញនិងឥរិយាបថចំពោះតួនាទីទាំងនេះ។

យោងតាមការសិក្សានាពេលថ្មីៗនេះធ្វើឡើងដោយ UN ESCAP "...ឥរិយាបថបិតាធិបតេយ្យ [នៅកម្ពុជា] នៅតែមានឥទ្ធិពលនៅក្នុងសង្គម ហើយការយល់ដឹងសាធារណៈអំពីសារៈសំខាន់នៃការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅមានកម្រិតទាបនៅឡើយ" [៧] ។ លើសពីនេះទៅទៀត នៅក្នុងការស្ទង់មតិរបស់អង្គការសហប្រជាជាតិក្នុងឆ្នាំ ២០១៣ បុរសចំនួន ៨២% និងស្ត្រីចំនួន ៩២% បានរាយការណ៍ថាតួនាទីដ៏សំខាន់បំផុតរបស់ស្ត្រីគឺត្រូវមើលថែផ្ទះ និងធ្វើម្ហូបសម្រាប់គ្រួសាររបស់នាង [៨] ។ ការសិក្សានេះបន្តបង្កើត និងធ្វើបច្ចុប្បន្នភាពលើបញ្ហានេះ ដោយធ្វើការស៊ើបអង្កេតឱ្យកាន់តែស៊ី-ជម្រៅទៅលើឥរិយាបថសង្គមដែលកំពុងអនុវត្តចំពោះការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃនាពេលបច្ចុប្បន្នដោយស្ត្រីនិងបុរសកម្ពុជានៅតាមជំនាន់ខុសៗគ្នា សារតារខុសគ្នា និងនិន្នាការភេទខុសៗគ្នា។

តាមរយៈការអនុវត្តវិធីសាស្ត្រស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម (FPAR) កិច្ចការស្រាវជ្រាវនេះត្រូវបានសហការបង្កើតឡើងដោយសមាជិកក្នុងសហគមន៍កម្ពុជាដែលមានបទពិសោធន៍ជីវិតផ្ទាល់លើប្រធានបទនេះ។

របកគំហើញនៃការស្រាវជ្រាវនេះ ផ្តល់ភស្តុតាងដែលជាមូលដ្ឋានសម្រាប់ អ្នកតស៊ូមតិផ្នែកសមភាពយេនឌ័រ និងអ្នកបង្កើតគោលនយោបាយក្នុងការសម្របសម្រួលសារ និងកិច្ចអន្តរាគមន៍របស់ពួកគេឱ្យកាន់តែមានប្រសិទ្ធភាព។ កិច្ចអន្តរាគមន៍ដែលមានភាពជាក់លាក់មានសារៈសំខាន់ណាស់ មិនថាអ្នកតស៊ូមតិព្យាយាមលើកកម្ពស់តម្លៃការងារថែទាំគ្មានប្រាក់កម្រៃឱ្យក្លាយជាការងារសំខាន់ដែលសក្តិសមនឹងទទួលបានការគោរព ឬលើកទឹកចិត្តបុរសឱ្យប្រឆាំងតបនឹងផ្នត់គំនិតបិតាធិបតេយ្យតាមរយៈការចូលរួមធ្វើការងារផ្ទះបន្ថែមដោយមិនបាច់ទាល់តែមានការស្នើសុំ។

ការស្រាវជ្រាវនេះក៏ពិនិត្យផងដែរទៅលើបញ្ហាសំខាន់នៃ 'បន្ទុកផ្លូវចិត្ត' ដែលជាប្រធានបទដ៏សំខាន់ និងទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងកិច្ចសន្ទនារបស់បុគ្គលស្ត្រីនិយមនៅទូទាំងសកលលោក [៩] រយៈពេលថ្មីៗនេះ ប៉ុន្តែជាប្រធានបទមួយដែលពុំទាន់ត្រូវបានសិក្សាលម្អិតនៅក្នុងបរិបទកម្ពុជានៅឡើយ។ បន្ទុកផ្លូវចិត្តសំដៅលើពលកម្មអរូបីជាការងារប្រើបញ្ញាស្មារតី (មានន័យថា ពាក់ព័ន្ធនឹងការគិត និង ការចងចាំ) ដែលជាផ្នែកនៃការដឹកនាំគ្រួសារ៖ “ក្នុងចិត្តរបស់ [ស្ត្រីកម្ពុជា] ពោរពេញដោយគំនិត ក្តីកង្វល់ និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រង និងជួយគាំទ្រដល់ដំណើរការប្រចាំថ្ងៃរបស់គ្រួសារ និងសមាជិកក្នុងគ្រួសារ” [១០]។

# សំណួរស្រាវជ្រាវ

ក្រុមស្រាវជ្រាវបានបង្កើតសំណួរស្រាវជ្រាវដូចខាងក្រោម៖

១. តើប្រជាជនខ្មែរដែលមានអាយុ យេនឌ័រ និងនិន្នាការភេទខុសគ្នា មានអារម្មណ៍ដូចម្តេចអំពីការបែងចែកការងារផ្ទះនាពេលបច្ចុប្បន្ន រវាងសមាជិកគ្រួសារ?

២. តើប្រជាជនខ្មែរដែលមានអាយុ យេនឌ័រ និងនិន្នាការភេទខុសគ្នាយល់ថាការងារផ្ទះនាពេលបច្ចុប្បន្នគួរតែត្រូវបែងចែកដោយរបៀបណារវាងសមាជិកគ្រួសារ?

៣. តើវិសមភាពនៃ 'បន្ទុកផ្លូវចិត្ត' (នៃការងាររៀបចំទុកដាក់ និងមើលថែសមាជិកនៅក្នុងផ្ទះ) ដែលបានរ៉ាប់រងដោយស្ត្រី បានបង្កផលប៉ះពាល់ដល់ស្ត្រីក្នុងកម្រិតណា ហើយតើផលប៉ះពាល់នេះជះឥទ្ធិពលទៅលើអ្វីខ្លះ?

# សេចក្តីសង្ខេបអំពីលទ្ធផលរបកគំហើញ

១. ទិន្នន័យស្ទង់មតិក្នុងរូបភាពទី ១ (ទំព័រ ១៤) បង្ហាញថា ជារួម អ្នកឆ្លើយតបភាគច្រើន (៨៨%) មានអារម្មណ៍ថា ជាធម្មតាស្ត្រីធ្វើកិច្ចការផ្ទះច្រើនជាង។

២. បីភាគបួននៃអ្នកឆ្លើយតបការស្ទង់មតិ (៧៥%) យល់ថាការងារផ្ទះត្រូវបានសង្គមចាត់ទុកថាមិនសូវសំខាន់ដូចការងារដែលមានប្រាក់ឈ្នួល ខណៈដែលអ្នកឆ្លើយតបផ្សេងទៀត បង្ហាញការមិនយល់ស្រប (រូបភាពទី ២ ទំព័រ ១៥)។

៣. អ្នកចូលរួមសម្ភាសន៍មួយចំនួនបានយល់ឃើញថា នៅពេលស្ត្រីមិនបំពេញការងារថៃទាំគ្មានប្រាក់កម្រៃសម្រាប់ស្វាមី និងគ្រួសារ ពួកគេអាចប្រឈមនឹងហានិភ័យនៃការទទួលរងអំពើហិង្សាក្នុងគ្រួសារ (ទំព័រ ១៦, ៣៧)។

៤. ត្រឹមតែ ៣៣% នៃអ្នកឆ្លើយតបការស្ទង់មតិប៉ុណ្ណោះ ដែលមានអារម្មណ៍ថា បុរស និងស្ត្រីបានចែករំលែក 'បន្ទុកផ្លូវចិត្ត' ស្មើគ្នា និងមានអ្នកឆ្លើយតបតិចជាងមួយភាគរយ (០.៤%) ដែលយល់ថា បុរសអនុវត្តការងារនេះភាគច្រើន (រូបភាពទី ៦ ទំព័រ ២៧) ។

៥. ដៃគូអ្នកស្រលាញ់ភេទដូចគ្នា ត្រូវបានគេយល់ឃើញថា មានភាពជឿនលឿនជាងមុនក្នុងការចែករំលែកការងារថៃទាំគ្មានប្រាក់កម្រៃរបស់ពួកគេ ដែលនេះជាការយល់ឃើញនិងលើកឡើងដោយអ្នកចូលរួមជាអ្នកស្រឡាញ់ភេទផ្ទុយគ្នា និងអ្នកស្រលាញ់ភេទដូចគ្នា (ទំព័រ ២៤, ២៥)។

៦. ផ្ទត់គំនិតដែលថាស្ត្រីគួរតែអនុវត្តការងារថៃទាំគ្មានប្រាក់កម្រៃរបស់គ្រួសារសម្រាប់ជាប្រយោជន៍នៃ 'សុភមង្គល' និង 'ភាពសុខដុមរមនា' នៅក្នុងគ្រួសារ គឺជាបទដ្ឋានសង្គមដែលអាចផ្លាស់ប្តូរបាន ហើយអ្នកចូលរួមឆ្លើយតបជាច្រើនអះអាងថា ការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃគួរធ្វើឡើងប្រកបដោយសមធម៌រវាងដៃគូ ធ្វើឱ្យគុណភាពទំនាក់ទំនង និងសុភមង្គលគ្រួសារមានភាពប្រសើរឡើង (ទំព័រ ៣៦ )។

៧. ទោះបីជាមានអ្នកចូលរួមជាស្ត្រីវ័យចំណាស់ជាច្រើនបានគាំទ្រ និងស្វាគមន៍នូវសមភាពនៃការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃរវាងដៃគូក្តី ក៏អ្នកឆ្លើយតបជាច្រើនបានបង្ហាញថាពួកគេរីករាយ និងមានមោទនភាពចំពោះការធ្វើការងារនេះ (ទំព័រ ៣៦)។

៨. បុរសដែលធ្វើការងារថៃទាំគ្មានប្រាក់កម្រៃត្រូវបានរាយការណ៍ថានៅពុំទាន់ចាត់ទុកជាផ្នែកនៃបទដ្ឋានសង្គម (ជារឿងធម្មតា) នៅកម្ពុជានៅឡើយនោះទេ ដោយអ្នកចូលរួមណែនាំថា សកម្មភាពនេះត្រូវបានចាត់ទុកថាជារឿងអាម៉ាស់ ឬគួរឱ្យកោតសរសើរ (រូបភាពទី ៩ ទំព័រ ៤១)។

៩. អ្នកចូលរួមបានរាយការណ៍ពីទស្សនៈថាស្ត្រីរស់នៅក្នុងតំបន់ជនបទប្រឈមមុខនឹងបន្ទុកការងារថៃទាំគ្មានប្រាក់កម្រៃខ្ពស់ជាងស្ត្រីនៅទីក្រុង (ទំព័រ៤៤)។

១០. ទោះបីជាបន្ទុកការងារថៃទាំគ្មានប្រាក់កម្រៃនៅតែជាបន្ទុកយ៉ាងធ្ងន់ធ្ងរដែលរ៉ាប់រងដោយស្ត្រីក៏ដោយ ទិន្នន័យបានបង្ហាញថាប្រជាជនកម្ពុជាមានអារម្មណ៍ថាការងារនេះគួរតែត្រូវបានចែករំលែកឱ្យស្មើភាពគ្នារវាងដៃគូ ជាពិសេសនៅពេលដែលអ្នកទាំងពីរធ្វើការនៅខាងក្រៅផ្ទះ (ទំព័រ ៤៨-៥២)។

១១. អ្នកចូលរួមក៏មានអារម្មណ៍ថាក្មេងស្រី និងក្មេងប្រុសគួរតែចែករំលែកទំនួលខុសត្រូវក្នុងគ្រួសារស្មើៗគ្នាដែរ (ទំព័រ ៥១)។ ទោះជាយ៉ាងនេះក្តីមានតែ ១.២% នៃអ្នកឆ្លើយតបប៉ុណ្ណោះ ដែលមានអារម្មណ៍ថាក្មេងប្រុសបំពេញកិច្ចការផ្ទះច្រើនជាង ធៀបនឹង ១៦% យល់ថាការងារនេះត្រូវបានបែងចែកស្មើគ្នា ខណៈអ្នកឆ្លើយតប ១.២% ដែលឆ្លើយថាមិនបានដឹងច្បាស់លាស់ - ធៀបនឹង ៨១.៦% ដែលបង្ហាញថាជាធម្មតាកូនស្រីជាអ្នកបំពេញការងារនេះ (រូបភាពទី ៣ ទំព័រ ១៧)។

១២. ស្រដៀងគ្នានេះដែរ អ្នកឆ្លើយតបការស្ទង់មតិជាច្រើននៅក្នុងរូបភាពទី ១៤ (ទំព័រ ៥៧) បានរាយការណ៍ថា ជីដូនក្នុងគ្រួសាររបស់ពួកគេធ្វើការងារផ្ទះច្រើនជាង (៨០.៣%) បើធៀបទៅនឹងជីតា (៣.៥) និង 'ស្មើគ្នា' (១៦.២%) ត្រូវបានរាយការណ៍ថាធ្វើកិច្ចការផ្ទះច្រើនជាង។

១៣. នៅពេលសួរថាតើគូស្វាមីភរិយាវ័យក្មេង (អាយុក្រោម ៣៥ ឆ្នាំ) ចែករំលែកការងារផ្ទះស្មើៗគ្នាជាងឪពុកម្តាយរបស់ពួកគេដែរទេ មានតែ ៣.៦% ប៉ុណ្ណោះដែលមានអារម្មណ៍ថាស្ថានភាពនៃការបែងចែកការងារផ្ទះគឺនៅដដែល ធៀបនឹង ៦.៤% មិនប្រាកដ ២២% យល់ថា គូស្វាមីភរិយាវ័យក្មេងឥឡូវនេះចេះចែករំលែកការងារផ្ទះស្មើគ្នា និង ៦៨% យល់ថា ទោះគូស្វាមីភរិយាវ័យក្មេងទោះចែករំលែកការងារផ្ទះស្មើគ្នាក៏ដោយ ក៏ស្ត្រីនៅតែធ្វើការងារច្រើនជាង (រូបភាពទី ១៥ ទំព័រ ៥៨)។

១៤. នៅពេលសួរថា៖ ក្នុងគ្រួសាររបស់អ្នក តើការងារផ្ទះត្រូវបានចែករំលែកស្មើភាពគ្នាដែរឬទេ? (រូបភាពទី ៨ ទំព័រ ៣១) ស្ត្រីមួយចំនួននៃ ៣១% បានជ្រើសរើស 'ចាស' ខណៈពេលដែលបុរស ៤២% ជ្រើសរើស 'បាទ' ដែលបង្ហាញពីភាពខុសគ្នារវាងការយល់ឃើញរបស់បុរស និងស្ត្រីចំពោះការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃ។

# ២

# វិធីសាស្ត្រ

# ២
# វិធីសាស្រ្ត

កិច្ចការស្រាវជ្រាវនេះអនុវត្តតាមវិធីសាស្រ្តស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្រ្តីនិយម (FPAR) នៅគ្រប់ដំណាក់កាលនៃការរៀបចំ និងដំណើការនៃការបង្កើតផែនការសារស្រាវជ្រាវ។ យោងតាម APWLD ដែលជាអ្នកបង្កើត និងអនុវត្តវិធីសាស្រ្ត FPAR ដំបូងគេនៅក្នុងតំបន់ ពន្យល់ថា FPAR គឺជាវិធីសាស្រ្តស៊ើបអង្កេត និងវិភាគបញ្ហាសង្គមដែលមានការចូលរួមដោយផ្ទាល់ពីភាគីដែលទទួលរងការនូវគាបសង្កត់ និងពលរដ្ឋទូទៅ ក្នុងការកំណត់បញ្ហា និងស្វែងរកដំណោះស្រាយ។

វិធីសាស្រ្តនេះគឺជា "មធ្យោបាយសម្រាប់ឱ្យអ្នកស្រាវជ្រាវ និងអ្នកចូលរួមរួបរួមគ្នាធ្វើសកម្មភាពរួម ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែងដើម្បីបង្កើតការផ្លាស់ប្តូរជាវិជ្ជមានក្នុងសង្គម" [១១] ។ FPAR ក៏រួមបញ្ចូលយ៉ាងហ្មត់ចត់នូវគោលការណ៍លទ្ធិស្រ្តីនិយមនៅគ្រប់ដំណាក់កាលដែលនេះគឺជាមធ្យោបាយក្នុងការកសាងសមត្ថភាព និងការចែករំលែកចំណេះដឹងក្នុងចំណោមអ្នកចូលរួមផងដែរ។ អាស្រ័យហេតុនេះ ក្រុមអ្នកស្រាវជ្រាវសកម្មនៅមូលដ្ឋាន និងក្រុមការងារក្លាហាន បានសហការរៀបចំការស្រាវជ្រាវនេះឡើង។

ក្រុមអ្នកស្រាវជ្រាវសកម្មនៅមូលដ្ឋានរួមមានយុវជនកម្ពុជាចំនួន ១១ រូប មកពីរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តពោធិ៍សាត់។ ពួកគេបានទទួលការបណ្តុះបណ្តាលអំពីក្រមសីលធម៌នៃការស្រាវជ្រាវ បច្ចេកទេសប្រមូលទិន្នន័យ ព្រមទាំងបានចូលរួមក្នុងដំណើរការនៃការសិក្សាទាំងស្រុងផងដែរ។

វិធីសាស្រ្តស្រាវជ្រាវបែបគុណវិស័យដែលប្រើប្រាស់កម្រងសំណួរសម្រាប់ការសម្ភាសន៍ជាមួយស្រ្តី និងបុរស (ដែលស្ថិតនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ ឬទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍) អនុញ្ញាតឱ្យអ្នកស្រាវជ្រាវធ្វើការពិភាក្សាស៊ីជម្រៅបន្ថែមទៀតលើសំណួរដែលមានស្រាប់។ ការសម្ភាសន៍បែបគុណវិស័យចំនួន ៦០ និងការពិភាក្សាក្រុមគោលដៅចំនួនពីរបានធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញ និងតំបន់ជនបទនៃខេត្តកំពង់ឆ្នាំង ត្រូវបានបំពេញបន្ថែមដោយទិន្នន័យនៃការស្ទង់មតិតាមប្រព័ន្ធអនឡាញ។








# ការសំយោគ និងវិភាគទិន្នន័យ

សមាជិកក្រុមអ្នកស្រាវជ្រាវសកម្មនៅមូលដ្ឋាន បានចូលរួមយ៉ាងសកម្មនៅគ្រប់ដំណាក់កាលទាំងអស់នៃការស្រាវជ្រាវ ពួកគេមិនត្រឹមតែចូលរួមក្នុងនាមជា 'អ្នកប្រមូលទិន្នន័យ' ដែលគ្រាន់តែទទួលបានកម្រងសំណួរទៅធ្វើការស្ទង់មតិ និងបញ្ជូនលទ្ធផលនៃការស្ទង់មតិមកវិញនោះទេ។

ក្នុងការសំយោគទិន្នន័យ (កំណត់កូដ)បែបគុណវិស័យ ក្រុមអ្នកស្រាវជ្រាវបានទទួលការបណ្តុះបណ្តាលដែលមានការអនុវត្តជាក់ស្តែងស្តីពីការវិភាគទិន្នន័យតាមប្រធានបទ របស់ Braun & Clarke (២០១៣) នៅរាជធានីភ្នំពេញ [១២] ។ ទិន្នន័យសម្ភាសន៍ត្រូវបានវិភាគ និងកំណត់កូដដោយអ្នកក្រុមអ្នកស្រាវជ្រាវវ័យក្មេងទាំងនេះដោយផ្ទាល់។

សម្រង់មតិរបស់អ្នកចូលរួមត្រូវបានកំណត់សម្គាល់អក្សរ 'Y' សម្រាប់អ្នកមានវ័យក្មេង (មនុស្សជំនាន់សហសវត្សរ៍ ឬយុវវ័យជំនាន់ Z) អក្សរ 'O' សម្រាប់មនុស្សវ័យចំណាស់ និង 'C' សម្រាប់អ្នកចូលរួមពីអង្គការសង្គមស៊ីវិល (CSO) ។ អក្សរ 'M' ឬ 'F' តំណាងឱ្យបុរស ឬស្ត្រី។ ឧទាហរណ៍ O១១ ស្ត្រី សំដៅដល់អ្នកចូលរួមដែលជាស្ត្រីវ័យចំណាស់ ចំណែកឯ M៣៨ បុរស សម្គាល់អ្នកចូលរួមដែលជាបុរសវ័យក្មេង ជាអ្នកចូលរួមទី ៣៨ នៃបទសម្ភាសន៍។ រាល់អ្នកចូលរួមឆ្លើយតបទាំងអស់បានកំណត់ទិន្នការភេទជាអ្នកស្រឡាញ់ភេទផ្ទុយពីគ្នា លុះត្រាតែមានការកំណត់សម្គាល់ជាក់លាក់ផ្ទុយពីនេះ ។

# ការស្ទង់មតិអនឡាញ

បន្ថែមពីលើការសម្ភាសន៍ ការស្ទង់មតិអនឡាញត្រូវបានធ្វើឡើងដើម្បីផ្តល់ការយល់ដឹងឱ្យកាន់តែស៊ីជម្រៅតាមបែបបរិមាណវិស័យបន្ថែមទៀត ដែលបានទទួលការឆ្លើយតបចំនួន ២៥០ ។ ទិន្នន័យត្រូវបានវិភាគដោយប្រើកម្មវិធី Excel ហើយលទ្ធផលរកឃើញត្រូវបានរួមបញ្ចូលនៅគ្រប់ផ្នែកនីមួយៗនៃរបាយការណ៍នេះ។








| អ្នកចូលរួមសម្ភាសន៍ | ចំនួន | លេខកូដ | សរុប = ៦០ |
|---|---|---|---|
| បុគ្គលិកអង្គការសង្គមស៊ីវិល (អ្នកតស៊ូមតិយេនឌ័រ) | ៥ | 'C' | |
| អ្នកតបសម្ភាសន៍វ័យក្មេង (ភាគច្រើន ២៥-៣៩) | ២៩ | 'Y' | |
| អ្នកសម្ភាសន៍វ័យចំណាស់ (ជំនាន់ X ជំនាន់ baby boomers) | ២៦ | 'O' | |

៣

# ការត្រួតពិនិត្យ ឯកសារ និង របាយការណ៍ ដែលមានស្រាប់

# ៣
# ការត្រួតពិនិត្យឯកសារ និង របាយការណ៍ដែលមានស្រាប់

*“មនុស្សស្រីមុជមិនជ្រៅទៅមិនឆ្ងាយ”*

-សុភាសិតខ្មែរបុរាណ

ដូចដែលបានរៀបរាប់នៅផ្នែកខាងដើម មានឯកសារស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធដែលមានស្រាប់ជាច្រើនដែរពិភាក្សាអំពីផលប៉ះពាល់នៃការងារថែទាំគ្មានប្រាក់កម្រៃលើស្ត្រីនៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅទូទាំងតំបន់អាស៊ាន និងទូទាំងពិភពលោកផងដែរ។ ការកើនឡើងនៃឯកសារស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធនេះ ឆ្លុះបញ្ចាំងឱ្យឃើញអំពីការទទួលស្គាល់កាន់តែច្រើនឡើងថា ការងារថែទាំគ្មានប្រាក់កម្រៃកំពុងតែមានផលប៉ះពាល់យ៉ាងធំធេងលើជីវិតរបស់ស្ត្រី [១៣] ដែលស្ថានភាពនេះមានលក្ខណៈកាន់តែធ្ងន់ធ្ងរទៅៗចាប់តាំងពីការចាប់ផ្តើមនៃជំងឺរាតត្បាតកូវីដ-១៩។

ជាការពិតណាស់ អង្គការសហប្រជាជាតិដើម្បីស្ត្រីបានប៉ាន់ស្មានថា លទ្ធផលនៃជំងឺរាតត្បាតកូវីដ-១៩ និងការបិទខ្ទប់ជាបន្តបន្ទាប់ បានបណ្តាលឲ្យស្ត្រីត្រូវរ៉ាប់រងការងារថែទាំនៅផ្ទះកាន់តែច្រើន - “យ៉ាងហោចណាស់ច្រើនជាងបីដងបើធៀបទៅនឹងបុរស ដែលនាំឱ្យស្ត្រីធ្វើការបន្ថែមចំនួន ៥១២ ពាន់លានម៉ោងនៃការងារថែទាំគ្មានប្រាក់កម្រៃនៅផ្ទះ”។ [១៤]

យោងលើឯកសារស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធពីអត្ថបទព័ត៌មានក្នុងស្រុក និងអន្តរជាតិ [១៥, ១៦] ការវិភាគ [១៧] និងប្លក់ (blogs) [១៨] របស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ និងឯកសារអក្សរសាស្ត្រសិក្សាពីបុគ្គលស្ត្រីនិយម ផ្នែកសង្គមវិទ្យា សេដ្ឋកិច្ច និងការសិក្សាផ្សេងទៀត [១៩, ២០] ប្រធានបទនៃការងារថែទាំគ្មានប្រាក់កម្រៃកំពុងត្រូវបានវិភាគកាន់តែច្រើនឡើងដោយផ្អែកលើទស្សនៈផ្សេងៗគ្នា។

នៅក្នុងបរិបទកម្ពុជា ការសិក្សាដែលមានស្រាប់បានត្រួតពិនិត្យមើលបញ្ហាទាំងនេះបែបបរិមាណវិស័យ ឧទាហរណ៍តាមរយៈការស្ទង់មតិបែបប្រជាសាស្ត្រទ្រង់ទ្រាយធំ [២១] ឬការស្ទង់មតិលើការប្រើប្រាស់ពេលវេលា [២២] ដែលមានសារៈសំខាន់សម្រាប់កំណត់បញ្ហាជាក់ស្តែងក្នុងសង្គម។

ការស្រាវជ្រាវនេះបំពេញបន្ថែមលើការសិក្សាស្រាវជ្រាវដែលមានស្រាប់ទាំងអស់នោះ ក៏ដូចជា លើគំនិតផ្តួច-ផ្តើមស្រាវជ្រាវគោលនយោបាយសំខាន់ៗដែលអនុវត្តដោយអង្គការនានាដូចជា វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) [២៣] អង្គការអុកស្វាមប្រចាំប្រទេស កម្ពុជា [២៤] និងគណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក (ESCAP) [២៥] ក្នុងគោលបំណងលើកកម្ពស់ប្រព័ន្ធគាំពារសង្គម និងការចូលរួមរបស់ស្ត្រីនៅក្នុងកម្លាំងពលកម្ម។

> *“[ការងារថែទាំគ្មានប្រាក់កម្រៃ] ដាក់កម្រិតលើពេលវេលារបស់ស្ត្រីក្នុងការកសាង ជំនាញ ចំណេះដឹង និងបណ្តាញនៅខាងក្រៅផ្ទះ ដែលប៉ះពាល់ដល់សក្តានុពលក្នុងការចាប់ផ្តើម និង/ឬអភិវឌ្ឍអាជីវកម្មរបស់ពួកគេ ហើយជារឿយៗបង្ខំឱ្យពួកគេលាឈប់ ឬបន្ថយការធ្វើការងារដែលមានប្រាក់ឈ្នួល”*
>
> **[អង្គការអុកស្វាមប្រចាំប្រទេស, ២៦] ។**

# ការត្រួតពិនិត្យឯកសារ និងរបាយការណ៍ដែលមានស្រាប់ (ត)

ការស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធដែលគួរឱ្យកត់សម្គាល់ផ្សេងទៀតនោះគឺការសិក្សាដែលធ្វើឡើងដោយ Katherine Brickell [២៧, ២៨, ២៩] និង Kasumi Nakagawa [៣០] ដែលបានសិក្សាស្រាវជ្រាវស៊ីជម្រៅទៅលើឥទ្ធិពលប្រពៃណី និងវប្បធម៌នៅពីក្រោយវិសមភាពក្នុងគ្រួសារ៖ ជាបាតុភូតមួយដែល Brickell ហៅថាជា “ស្នាមប្រឡាក់ដែលរាំងស្ទះ” លើគោលបំណង និងការសម្រេចបាននៃការអភិវឌ្ឍន៍នានា។”

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់របកគំហើញនៃការស្រាវជ្រាវទាំងអស់នេះ និងបានធ្វើបច្ចុប្បន្នភាព ព្រមទាំងផ្តួចផ្តើមនូវកិច្ចសន្ទនា និងការជជែកពិភាក្សា (និទានកថា ការនិយាយ ឃ្លា) បែបស្លាបទាដែលប្រើប្រាស់ដោយអ្នកចូលរួមនៅពេលពួកគេពន្យល់អំពីស្ថានភាពប្រចាំថ្ងៃពួកគេដោយរួមបញ្ចូលនូវតួនាទីយេនឌ័រ និងបទដ្ឋានសង្គមផងដែរ។

ឧទាហរណ៍ ការសិក្សាឆ្នាំ ២០១១ របស់ Brickell ស្តីពីអត្ថន័យនៃ (ការមិន) ចូលរួមធ្វើការងារផ្ទះផ្អែកលើទស្សនៈយេនឌ័រនៅក្នុងប្រទេសកម្ពុជាមានអាយុកាលជាងមួយទសវត្សរ៍មកហើយ។ នៅទសវត្សរ៍ឆ្នាំ ២០១០ ដែលជាទសវត្សរ៍ពោរពេញដោយការផ្លាស់ប្តូរសម្រាប់ពិភពលោកទាំងមូល ប៉ុន្តែការផ្លាស់ប្តូរដែលគួរឲ្យកត់សម្គាល់សម្រាប់ប្រទេសកម្ពុជាមាន៖ ការកើនឡើងយ៉ាងខ្លាំងនៃការប្រើប្រាស់អ៊ីនធឺណិតដែលមានត្រឹមតែ ១.២% នៃចំនួនប្រជាជនក្នុងឆ្នាំ២០១០ រហូតដល់ ៧៨.៨% ក្នុងឆ្នាំ ២០២០ [៣១] និងជំនាន់មនុស្សប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដំបូង [វ័យកណ្តាល (millenials) និងជំនាន់ Z ចាស់ៗ] ដែលពួកគេកំពុងតែចូលបម្រើការងារ និងកសាងគ្រួសាររបស់ពួកគេ។

ប្រការនេះទាមទារឱ្យមានការត្រួតពិនិត្យជាថ្មីលើការយល់ឃើញនាពេលបច្ចុប្បន្នចំពោះការងារថែទាំគ្មានប្រាក់កម្រៃក្នុងចំណោមគូស្វាមីភរិយាវ័យក្មេង ក៏ដូចជាថាតើឥរិយាបទទាំងនេះមានការផ្លាស់ប្តូរនៅក្នុងចំណោមមនុស្សជំនាន់មុនដែរឬទេ។

បន្ថែមលើនេះ ការសិក្សាស្រាវជ្រាវនេះមានភាពខុសប្លែកពីការស្រាវជ្រាវមុនៗ ដោយមានចេតនារួមបញ្ចូលដៃគូស្និទ្ធស្នាលដែលជាអ្នកស្រលាញ់ភេទដូចគ្នា និងការវិភាគលើពលកម្មបែបអរូបីក្នុងទម្រង់ 'បន្ទុកផ្លូវចិត្ត' ។

ទោះបីជាការសិក្សានេះផ្តល់នូវការយល់ដឹងខ្លះៗអំពីការយល់ឃើញ និងឥរិយាបថជុំវិញការងារថែទាំគ្មានប្រាក់កម្រៃ ក្នុងចំណោមប្រជាជនកម្ពុជាដែលមានអាយុ សារតារ និងនិន្នាការភេទចម្រុះក៏ដោយ ក៏ការសិក្សានេះគឺជាការសិក្សាបែបគុណវិស័យ (ដោយគ្រាន់តែមានធាតុផ្សំនៃការស្ទង់មតិក្នុងទំហំតូចមួយបន្ថែមប៉ុណ្ណោះ) ដូច្នេះទិន្នន័យក្នុងរបាយការណ៍នេះមិនអាច និងមិនគួរជាតំណាងការយល់ឃើញរបស់ប្រជាជនក្នុងប្រទេសកម្ពុជាទាំងស្រុងបានទេ។

យើងសង្ឃឹមថាការសិក្សាស្រាវជ្រាវនេះបានជាការបំពេញបន្ថែម និងរួមចំណែកលើកិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់ដើម្បីបង្កើនការយល់ដឹងឱ្យកាន់តែស៊ីជម្រៅអំពីលក្ខណៈពិសេសរបស់ការងារថែទាំគ្មានប្រាក់កម្រៃនៅក្នុងបរិបទកម្ពុជា និងការសម្រេចឲ្យបាននូវការបែងចែក ដោយស្មើភាពគ្នាបន្ថែមទៀតនៃកម្លាំងពលកម្មដ៏ចាំបាច់នេះ ដែលផ្អែកដ៏សំខាន់នៃជីវភាពរស់នៅរបស់យើង។

# តើការងារផ្ទះជាការងាររបស់អ្នកណា? ស្ថានភាពបច្ចុប្បន្ន

# ៤
# ស្ថានភាពបច្ចុប្បន្ន

នេះគឺជាផ្នែកទីមួយ នៅក្នុងចំណោមផ្នែកទាំងបួននៃរបាយការណ៍ ដែលឈ្វេងយល់អំពីការយល់ឃើញ និងឥរិយាបថរបស់អ្នកចូលរួមលើការ បែងចែកការងារថែទាំគ្មានប្រាក់កម្រៃផ្អែកលើយេនឌ័រ នៅក្នុងប្រទេសកម្ពុជា។

ផ្នែកទីមួយនេះ ពិនិត្យមើលទៅលើរបៀបដែលអ្នកចូលរួមយល់ឃើញ និងពណ៌នាអំពីការបែងចែកការងារផ្ទះ និងបន្ទុកផ្លូវចិត្តនាពេលបច្ចុប្បន្ន។ ផ្នែកនេះ ក៏ពិភាក្សាផងដែរថាតើមានភាពខុសគ្នាសំខាន់ៗដែរឬទេ រវាងអ្នកចូលរួមដោយផ្អែកលើ យេនឌ័រ ឬអាយុរបស់ពួកគេ ហើយត្រូវបានបែងចែកជាពីរចំណុចធំៗ។

ចំណុចទីមួយ ឈ្វេងយល់អំពីការឆ្លើយតបរបស់អ្នកចូលរួមដែលលើកឡើង ពីអ្វីដែលកំពុងកើតឡើងនាពេលបច្ចុប្បន្ន។ តើស្ត្រីត្រូវចំណាយពេលប៉ុន្មាន លើផ្នែកផ្សេងៗនៃការងារថែទាំគ្មានប្រាក់កម្រៃបើធៀបនឹងបុរស? តើអ្វីជាផលប៉ះពាល់ដែលបានលើកឡើងដោយអ្នកចូលរួមលើបញ្ហានេះ? តើដៃគូអ្នកស្រលាញ់ភេទដូចគ្នាបានផ្ដល់នូវទស្សនៈអ្វីខ្លះជុំវិញប្រធានបទនេះ?

ចំណុចទីពីរ សិក្សាបន្ថែមលើការវិភាគខាងលើដោយពិនិត្យមើលជាពិសេសទៅលើបន្ទុកផ្លូវចិត្ត ដែលសំដៅដល់ពលកម្មបែបអរូបី (ពោលគឺការខិតខំប្រឹងប្រែងដែលទាមទារឱ្យគិតគូរ និងចងចាំជាប្រចាំលើកិច្ចការដែលទាក់ទងនឹងគ្រួសារ និងការថែទាំផ្ទះសម្បែង) ក៏ដូចជារបៀប (ដែលអ្នកចូលរួមយល់ឃើញ) នៃការចែករំលែកការងារនេះរវាងដៃគូស្និទ្ធស្នាល។

**៤.0** តើការងារផ្ទះជាការងាររបស់អ្នកណា? ស្ថានភាពបច្ចុប្បន្ន

៤.១ ការយល់ឃើញអំពី ការងារផ្ទះ
៤.២ ស្ថានភាពនៃបន្ទុកផ្លូវចិត្ត

**៥.0** ការយល់ឃើញអំពីមូលហេតុៈ កត្តាជម្រុញ

៥.១ វប្បធម៌
៥.២ សង្គម
៥.៣ អន្តរជំនាន់
៥.៤ ភូមិសាស្ត្រ

**៦.0** នៅក្នុងពិភពដ៏តតខ្មោៈ... ការយល់ឃើញអំពីស្ថានភាពនៃការបែងចែកការងារផ្ទះដែលសមស្រប

**៧.0** ការវិវត្តន៍នៃបរិបទសង្គម... ទស្សនៈអំពីការផ្លាស់ប្ដូរជំនាន់

# ៤.១ តើមានអ្វីខ្លះ កំពុងកើតឡើង

*"ខ្ញុំធ្វើកិច្ចការផ្ទះ (ធ្វើម្ហូប បោសជូតផ្ទះ លាងចាន) មុនពេលខ្ញុំទៅធ្វើការ។ នៅពេលខ្ញុំត្រឡប់មកវិញ ខ្ញុំធ្វើម្ហូបឱ្យគ្រួសាររបស់ខ្ញុំញ៉ាំ... នេះជាការងារដែលចំណាយពេលវេលាយូរជាងគេ ព្រោះខ្ញុំធ្វើការងារទាំងនេះតែម្នាក់ឯង។ ខ្ញុំត្រូវតែធ្វើម្ហូបឱ្យលឿនតាមដែលខ្ញុំអាចធ្វើបាន ពីព្រោះ... អាហារត្រូវតែរៀបចំរួចរាល់សម្រាប់ [កូនរបស់ខ្ញុំ] ដោយសារពួកគេឃ្លាន។*

*ស្ត្រីត្រូវសុំជំនួយពី [បុរស]។ បើមិនសុំពឹងពាក់ទេ គាត់មិនជួយឡើយ... ឧទាហរណ៍ ខ្ញុំពឹងប្ដីខ្ញុំឱ្យដួសបាយដាក់ចាន" (Y17 ស្ត្រី).*

ផ្នែកនៃរបាយការណ៍នេះ នឹងជួយកំណត់ទិដ្ឋភាពដែលកំពុងកើតមានឡើង ដោយផ្សាភ្ជាប់នឹងអ្វីដែលប្រជាជនកម្ពុជាទូទៅពណ៌នាលើការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃនាពេលបច្ចុប្បន្ន ដោយផ្ដោតលើការងារផ្ទះ។

ទិដ្ឋភាពដំបូង ស្ត្រីត្រូវបានគេរាយការណ៍ថាជាអ្នកដែលបំពេញការងារផ្ទះភាគច្រើន។ នេះជាការយល់ឃើញទូទៅក្នុងចំណោមអ្នកចូលរួមស្ទើរតែទាំងអស់ គ្រប់វ័យ និងគ្រប់យេនឌ័រ ដែលឆ្លុះបញ្ចាំងអំពីលទ្ធផលរកឃើញនៃការស្រាវជ្រាវដែលមានស្រាប់លើប្រធានបទនេះ ដូចដែលបានពិភាក្សានៅក្នុងផ្នែកពិនិត្យនិងវិភាគឯកសារ និងរបាយការណ៍ពាក់ព័ន្ធដែលមានស្រាប់ នៅផ្នែកមុន៖

*"ផ្អែកលើការសង្កេតផ្ទាល់ខ្លួនរបស់ខ្ញុំ ទាំងនៅតាមជនបទ និងទីក្រុង ស្ត្រីរួមមាន ប្រពន្ធ ម្ដាយ កូនស្រី សូម្បីតែចៅស្រី ភាគច្រើនសុទ្ធតែមានទំនួលខុសត្រូវក្នុងការធ្វើការងារផ្ទះ"   (Y៦ បុរស) ។*

ទោះជាយ៉ាងណាក៏ដោយ បុរសជាច្រើនបានរាយការណ៍ថាយ៉ាងហោចណាស់ពួកគេចំណាយពេលខ្លះទទួលខុសត្រូវលើទម្រង់មួយចំនួននៃការងារថែទាំគ្មានប្រាក់កម្រៃ។ ការងារទាំងនោះរួមមាន មួយ ឬច្រើននៃការងារដែលរៀបរាប់ទាំងនេះ៖ ការងូតទឹកឱ្យកូនតូចៗ បោសជូត និងសម្អាតផ្ទះ ជួសជុលបរិក្ខាក្នុងផ្ទះ និងថែទាំផ្ទះ 'ជួយ' ប្រពន្ធធ្វើកិច្ចការនៅពេលចាំបាច់។

ក្នុងនោះដែរក៏មានអ្នកចូលរួមជាបុរស និងស្ត្រីមួយចំនួនតូច បានរាយការណ៍ថាពួកគេបានធ្វើការងារថែទាំគ្មានប្រាក់កម្រៃស្មើភាពគ្នានឹងដៃគូរបស់ពួកគេ។ នៅក្នុងករណីទាំងនេះ ការទទួលខុសត្រូវបែងចែកទៅតាមប្រភេទការងារ ឬដៃគូម្នាក់ៗរាយការណ៍ថាពួកធ្វើការងារផ្ទះទាំងអស់ដែលជា 'ចំណែករបស់ពួកគេ' ។

*"អ្វីដែលពុំមានការផ្លាស់ប្ដូរនោះ គឺការគ្រប់គ្រងកិច្ចការក្នុងផ្ទះ គឺនៅតែជាកាតព្វកិច្ចចម្បងរបស់ស្ត្រី។*

*ទោះបីជាមានបុរសចាំជួយក៏ដោយ វានៅតែអាស្រ័យលើស្ត្រីជាអ្នកគ្រប់គ្រង។*

*ផ្នត់គំនិតបែបនេះមិនផ្លាស់ប្ដូរទេ។ បុរសអាចជួយបាន ប៉ុន្តែវាជាកាតព្វកិច្ចរបស់ស្ត្រី ទោះបីជានាងមានការងារក្រៅផ្ទះក៏ដោយ នាងនៅតែត្រូវគ្រប់គ្រងមើលថែកូន និងផ្ទះរបស់នាង"*

(Y៥ ស្ត្រី)។

*”និយាយតាមត្រង់ទៅ ក្នុងនាមជាស្ត្រី ខ្ញុំប្រាកដជានិយាយថា ពួកយើងគឺជាអ្នកទទួលខុសត្រូវលើការគ្រប់គ្រងការងារផ្ទះភាគច្រើន... ឧទាហរណ៍ ក្នុងនាមជាស្ត្រី ប្រសិនបើយើងមិនធ្វើការងារផ្ទះទេ នោះយើងនឹងត្រូវទទួលរងការស្តីបន្ទោស។ ដូច្នេះហើយស្ត្រី គឺជាអ្នករ៉ាប់រងទទួលបន្ទុកនេះ” (Y៦ ស្ត្រី) ។*

ទោះបីជាអ្នកចូលរួមសម្ភាសន៍មួយចំនួន បានរាយការណ៍អំពីស្ថានភាពគ្រួសាររបស់ពួកគេថាមានភាពស្មើគ្នាច្រើន ឬតិចលើការបែងចែកការងារផ្ទះ និងការងារថែទាំគ្មានប្រាក់កម្រៃផ្សេងទៀតក៏ដោយ ក៏ទស្សនៈដែលថា ជាទូទៅស្ត្រីនៅក្នុងសង្គមកម្ពុជាជាអ្នកធ្វើកិច្ចការទាំងនេះភាគច្រើន នៅតែជាទស្សនៈដែលមានឥទ្ធិពល។ វិសាលភាពនៃអតុល្យភាពនេះ ត្រូវបានគេលើកឡើងថាទទួលរងឥទ្ធិពលដោយសារកត្តាសំខាន់ៗជាក់លាក់មួយចំនួន។ ឧទាហរណ៍ អ្នកចូលរួមមួយចំនួនបានរាយការណ៍ថា ស្ត្រីមានទំនោរធ្វើការងារផ្ទះច្រើន (ឬទាំងអស់) នៅពេលដែល៖

- មានគ្រួសាររស់នៅតាមជនបទ
- ស្ត្រីមិនចេញទៅធ្វើការក្រៅផ្ទះ ឬធ្វើត្រឹមតែការងារក្រៅម៉ោង ឬ
- ក្នុងចំណោមមនុស្សជំនាន់មុន

កត្តាជះឥទ្ធិពលទាំងនេះ និងកត្តាផ្សេងៗទៀតនឹងត្រូវបានឈ្វេងយល់ឱ្យកាន់តែលម្អិតនៅពេលក្រោយនៅក្នុងផ្នែកនេះ និងនៅក្នុងផ្នែកបន្តបន្ទាប់ទៀត។ ទោះជាយ៉ាងណាក៏ដោយ ក្រាហ្វខាងក្រោម (គំនូសសម្គាល់ទី ១) បានបង្ហាញថា អ្នកឆ្លើយតបការស្ទង់មតិភាគច្រើន (៨៨%) មានអារម្មណ៍ថាជារួម ស្ត្រីគឺធ្វើការងារផ្ទះច្រើនជាងគេ។

ទោះបីជាទំហំសំណាកគម្រូនៃការស្ទង់មតិមានទំហំតូច ដោយមានការឆ្លើយតបចំនួន ២៥០ ភាពលម្អៀងក្នុងចំណោមស្ត្រី និងបុរសគឺមានសារៈសំខាន់ណាស់៖ ក្នុងចំណោមអ្នកឆ្លើយតបជាស្ត្រី ៩០.៥% មានអារម្មណ៍ថា ស្ត្រីធ្វើការងារផ្ទះច្រើនជាង។ ចំណែកបុរសវិញ ការយល់ឃើញនេះធ្លាក់ចុះដល់ ៧៨.៣% ។ ស្របពេលដែលមានតម្រូវការក្នុងការស្រាវជ្រាវបន្ថែមទៀត ការរកឃើញនេះបង្ហាញថា ក្នុងចំណោមបុរសកម្ពុជាពួកគេប្រហែលជាមានការយល់ឃើញថា ការងារថែទាំគ្មានប្រាក់កម្រៃត្រូវបានបែងចែកស្មើភាពគ្នាជាងអ្វីដែលស្ត្រីយល់ឃើញ។

### គំនូសសម្គាល់ទី ១៖ ចំពោះគូស្វាមីភរិយាខ្មែរ តើអ្នកគិតថាអ្នកណាធ្វើការងារផ្ទះច្រើនជាងគេក្នុងគ្រួសារ?



# ការមិនផ្តល់តម្លៃដល់ការងារថែទាំគ្មានប្រាក់កម្រៃ

**គំនូសសម្គាល់ទី ២៖ តើអ្នកគិតថាសង្គមខ្មែរយល់ឃើញថាការងារផ្ទះសំខាន់ដូចការងារដែលទទួលប្រាក់ឈ្នួលដែរឬទេ?**




ដូចដែលបុគ្គលស្រ្តីនិយម និងសកម្មជនសិទ្ធិមនុស្សជាច្រើនបានសង្កេតឃើញ ការងារថែទាំគឺជាការងារដ៏សំខាន់ដែលជាមូលដ្ឋានសម្រាប់ដំណើរការជោគជ័យរបស់សង្គមមួយ [៣២] ។ របាយការណ៍នេះមិនបានបដិសេធលើគំនិតដែលចាត់ទុកការងារ-ថែទាំ-ជាការងារ ហើយក៏មិនផ្តល់ការបកស្រាយថា ស្រ្តីដែលចាត់ទុកការងារថែទាំគ្មានប្រាក់កម្រៃជាការងារចម្បងរបស់ពួកគេមានមុខរបរមិនពេញលេញ ឬទទួលរងការគាបសង្កត់ដោយកត្តាណាមួយឡើយ។

ឯកសារណែនាំរបស់អង្គការអាកសិនអេដបាន កាលពីឆ្នាំ ២០១៥ រំឭកយើងថា៖

ការទទួលបានសិទ្ធិសម្រាប់គ្រប់គ្នាអាចសម្រេចបានតាមរយៈ៖

ក) <u>ការទទួលស្គាល់</u> ថាការងារថែទាំពិតជាមានពិតប្រាកដ និងមានសារៈសំខាន់
ខ) <u>កាត់បន្ថយ</u> ការងារថែទាំតាមរយៈគោលនយោបាយ (ឧ. ការផ្តល់ទឹកដោយឥតគិតថ្លៃ)
គ) <u>ការបែងចែកឡើងវិញ</u> ឬការចែករំលែកការងារថែទាំ [៣៣]] ។

ដើម្បីសម្រេចបាននូវការ <u>កាត់បន្ថយ</u> បន្ទុកការងារថែទាំលើស្ត្រី និង <u>ការបែងចែកឡើងវិញ</u> លើការទទួលខុសត្រូវលើការងារថែទាំគ្មានប្រាក់កម្រៃ ទាមទារឲ្យមានផងដែរនូវការសម្រេចឲ្យបាននូវវឌ្ឍនភាពឆ្ពោះនៃ <u>ការទទួលស្គាល់</u> ពីសង្គមថាការងារថែទាំពិតជាមានពិតប្រាកដ និងមានសារៈសំខាន់។ ក្រាហ្វខាងលើ (គំនូសសម្គាល់ទី ២) បានបង្ហាញពីតម្រូវការនៃការខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងផ្នែកនេះ ដោយមានអ្នកឆ្លើយតបចំនួន បីភាគបួន បានរាយការណ៍អំពីការយល់ឃើញដែលថា ការងារផ្ទះមិនត្រូវបានសង្គមចាត់ទុកថាមានសារៈសំខាន់ដូចការងារដែលទទួលបានប្រាក់ឈ្នួលផ្សេងទៀតនោះទេ។

ជារួម ស្ត្រីមិនត្រឹមតែធ្វើ និងគ្រប់គ្រងកិច្ចការទាំងនេះទេ ប៉ុន្តែពួកគេក៏ទទួលបានការ 'មិនដឹងគុណ ឬមិនផ្តល់តម្លៃ' និងតម្រូវការតតណប់ឈរក្នុងការបំពេញការងារទាំងនេះផងដែរ៖ “មិនត្រឹមតែថាយើង [ប្រពន្ធ] មិនទទួលបានប្រាក់ខែប៉ុណ្ណោះនោះទេ យើងថែមទាំងមិនទទួលបានការសរសើរពេលបំពេញការងារនេះទៀតផង ហើយយើងក៏ត្រូវបានបុរសបន្ទាបតម្លៃផងដែរ” (០១៧ ស្ត្រី)។ កង្វះកិត្យានុភាពដែលផ្សារភ្ជាប់ជាមួយនឹងការងារថែទាំគ្មានប្រាក់កម្រៃ រួមបញ្ចូលការមិនទទួលបានការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច និងការទទួលស្គាល់ ក៏ដូចជាការមិនផ្តល់ភាពសំខាន់ និងបរិមាណការងារដ៏ច្រើនសន្ធឹកសន្ធាប់នៃការងារថែទាំនេះ បានចូលរួមចំណែកជម្រុញឲ្យស្ត្រី និងបុរសទូទាំងពិភពលោកមានទំនោរជ្រើសយកការងារមានប្រាក់ឈ្នួល ជាជាងការងារថែទាំគ្មានប្រាក់កម្រៃពេញម៉ោង [៣៤] ។

# ការមិនផ្តល់តម្លៃដល់ការងារថែទាំគ្មានប្រាក់កម្រៃ (ត)

អ្នកចូលរួមមួយរូបមិនត្រឹមតែលើកឡើងពីកង្វះនៃការផ្តល់តម្លៃ និងការពេញចិត្តពីបុរសមួយចំនួនចំពោះការផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃក្នុងផ្ទះរបស់ពួកគេពីសំណាក់ដៃគូរដែលជាប្រពន្ធប៉ុណ្ណោះទេ គាត់ក៏បានលើកពីផលជះអវិជ្ជមានមួយចំនួនបន្ថែមទៀតប្រសិនបើស្ត្រីប្រកែកមិនព្រមធ្វើការងារផ្ទះ ឬធ្វើមិនបានល្អ ឬលើកឡើងអំពីការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃមិនស្មើគ្នារវាងពួកគេ៖

*“យើងបានពិភាក្សាគ្នា [អំពីវិសមភាពនៃការងារផ្ទះ] ប៉ុន្តែគាត់មិនស្តាប់... គាត់គ្រាន់តែឆ្លើយតបវិញដោយពាក្យគំរោះគំរើយ ព្រមទាំងប្រាប់ខ្ញុំឱ្យធ្វើការងាររបស់ខ្ញុំឱ្យបានត្រឹមត្រូវ” (ស្ត្រី Y៤) ។*

ក្នុងកំឡុងពេលពិភាក្សាក្រុម អ្នកចូលរួមជាស្ត្រីម្នាក់ទៀតថែមទាំងបានលើកឡើងអំពីការអាចកើតមានឡើងនៃអំពើហិង្សាទៀតផង៖

*“យើងចង់ពិភាក្សាពីបញ្ហានេះដែរ ប៉ុន្តែដៃគូខ្លះ ពេលយើងលើកបញ្ហានេះឡើង បែរជាចង់ប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ឬពួកគេនិយាយថា គ្មានអ្វីត្រូវពិភាក្សាឡើយ ពោលវាជារឿងឥតបានការ។ បុរសខ្លះស្តាប់ ប៉ុន្តែខ្លះមិនស្តាប់ ពួកគេគិតថា យើងកំពុងព្យាយាមគ្រប់គ្រងពួកគេ ឬពួកគេប្រាប់យើងថាយើងនិយាយច្រើន” (ស្ត្រី OFGD) ។*

ចំណុចសំខាន់ដែលគួរតែគូសបញ្ជាក់នៅផ្នែកនេះ ត្រង់ថាមានបុរសមួយចំនួនដែលចូលរួមក្នុងការសិក្សានេះបានរាយការណ៍ពីទស្សនៈបែបជឿនលឿនអំពីសារៈសំខាន់នៃការចែករំលែកការងារក្នុងផ្ទះ (ទោះបី ជាភាគច្រើននៃការលើកឡើងប្រើពាក្យថា 'ការជួយ' ជាជាងការធ្វើក៏ដោយ។ យើងនឹងពិភាក្សាបញ្ហានេះបន្ថែមទៀតនៅចំណុច ៤.២.១)។ បើទោះបីជាបុរសទាំងអស់ មិនបានគិតថាប្រពន្ធរបស់ពួកគេរ៉ាប់រងការងារថែទាំគ្មានប្រាក់កម្រៃច្រើនជាងពួកគេក៏ដោយ ក៏បទពិសោធន៍នៃការរស់នៅជាមួយនឹងរ៉ាប់រងបន្ទុកនៃការងារទាំងអស់នេះ (ការងារថែទាំគ្មានប្រាក់កម្រៃ) របស់ស្ត្រីជាច្រើនរូបជាបទពិសោធន៍ដែលកើតឡើងពិតប្រាកដ។ វិសមភាពនេះ ស្តែងឡើងតាមរយៈហេតុផលមួយចំនួនដែលនឹងត្រូវជជែកដេញដោលបន្ថែមទៀត។

បើយើងក្រឡេកមើលរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិ (ILO) កាលពីឆ្នាំ ២០១៨ [៣៥] បានរកឃើញថា ស្ត្រីខ្មែរធ្វើការងារថែទាំគ្មានប្រាក់កម្រៃប្រហែល ១៨៨ នាទីក្នុងមួយថ្ងៃ ខណៈដែលបុរសជាមធ្យមធ្វើត្រឹមតែ ១៨ នាទី ដែលបញ្ជាក់ថាវិសមភាពនៃការរ៉ាប់រងការងារថែទាំគ្មានប្រាក់កម្រៃពិតជាកើតមានមែន។ បន្ថែមពីនេះ ស្ទើរតែ ៩០% នៃអ្នកឆ្លើយតបការស្ទង់មតិនៅក្នុងការសិក្សានេះ (គំនូសសម្គាល់ទី ១) បង្ហាញអារម្មណ៍ថា មានការបែង-ចែកការងារថែទាំគ្មានប្រាក់កម្រៃមិនស្មើរគ្នារវាងយេនឌ័រនៅទូទាំងប្រទេសកម្ពុជា។

*“ជួនកាល [ការដើរតួជាបុគ្គលិកគំរូ និងដៃគូល្អ] គឺមិនស្រួលនោះទេ។ ពេលខ្លះគាត់ (ប្តី) សួរខ្ញុំថា “គ្រាន់តែសម្ល និងបាយមួយឆ្នាំងទេ ហេតុអ្វីបានជាចំណាយពេលយូរម្ល៉េះ?”*

*ខ្ញុំប្រាប់គាត់ពីការងារដែលខ្ញុំធ្វើ ដូចជា បោកខោអាវកូន លាងចាន និងធ្វើម្ហូប ដែលទាំងនេះជាកិច្ចការតូចតាច ប៉ុន្តែស្ត្រីត្រូវធ្វើវាតាំងពីព្រឹករហូតដល់រសៀល... គាត់មិនឆ្លើយតបអ្វីទាំងអស់”*

(Y១០ ស្ត្រី)។

# ការយល់ឃើញអំពីការបាត់បង់ឱកាសផ្សេងៗ

*“មានការប៉ះពាល់ដល់ការសិក្សារបស់ក្មេងស្រី” [ប្រសិនបើពួកគេបំពេញការងារផ្ទះច្រើនជាងក្មេងប្រុស]។ នៅពេលខ្ញុំអាយុ ១០ ឆ្នាំ ខ្ញុំទៅរៀនបានត្រឹមតែ ៣ ថ្ងៃប៉ុណ្ណោះក្នុងមួយសប្តាហ៍... ខ្ញុំត្រូវទៅធ្វើស្រែ បររទេះគោ ហើយដឹកបន្លែ។ នោះហើយជាមូលហេតុដែលខ្ញុំមិនចេះអក្សរ” (O១៥ ស្ត្រី )។*

*"[ការឱ្យកូនស្រីធ្វើការងារថៃទាំគ្មានប្រាក់កម្រៃជំនួសកូនប្រុស] គឺមិនស្មើភាពគ្នានោះទេ។ យើងទាំងអស់គ្នាសុទ្ធតែជាមនុស្ស។ ហេតុអ្វីបានជាយើងត្រូវឲ្យមនុស្សម្នាក់ធ្វើនេះ ធ្វើនោះ ដើម្បីឱ្យអ្នកផ្សេងទៀតអាចគេចវេសពីការធ្វើការងារផ្ទះ?*

*នេះជារឿងមិនសមហេតុផល និងអយុត្តិធម៌ណាស់ចំពោះស្ត្រី កូនស្រី និងចៅស្រី។*

*កុមារី និងស្ត្រីចាំបាច់ត្រូវទទួលបានការអប់រំ ទំនាក់ទំនងជាមួយអ្នកដទៃ និងការបង្កើតបណ្តាញសម្រាប់ខ្លួនឯង។ ពួកគេមិនអាចនៅតែផ្ទះបានទេ។ នេះដូចជាការរារាំងពួកគេ (ពីការទទួលបាន និងចាប់យកឱកាសអញ្ចឹង)"*

(Y1 អ្នកស្រលាញ់ភេទដូចគ្នាជាស្ត្រី ស្រឡាញ់ស្ត្រី)។

នៅពេលដែលស្ត្រី និងក្មេងស្រីចំណាយពេលវេលាច្រើនជាងបុរសក្នុងការធ្វើការងារថៃទាំគ្មានប្រាក់កម្រៃ ពួកគេប្រឈមនឹងការបាត់បង់ឱកាសសំខាន់ពីរគឺ ការទទួលបានការអប់រំ និងការប្រកបការងារ (ដែលទទួលបានប្រាក់កម្រៃ)។ នេះបើយោងទៅតាមទិន្នន័យដែលយើងទទួលបាន។

## ការទទួលបានការអប់រំ

ដូចដែលបានរៀបរាប់នៅក្នុងផ្នែកពិនិត្យ និងវិភាគឯកសារស្រាវជ្រាវដែលមានស្រាប់ លទ្ធផលសិក្សាស្រាវជ្រាវទាំងនោះសុទ្ធតែបានចង្អុលបង្ហាញនូវផលប៉ះពាល់នៃការងារថៃទាំគ្មានប្រាក់កម្រៃលើការអប់រំរបស់ក្មេងស្រី។ ដូចគ្នានេះដែរ ទិន្នន័យបែបគុណវិស័យដែលបានមកពីការផ្តល់សក្ខីកម្មអំពីបទពិសោធផ្ទាល់ខ្លួនរបស់អ្នកចូលរួមដែលជាស្ត្រីបង្ហាញថា ពួកគេត្រូវបានជម្រុញឲ្យធ្វើការងារថៃទាំគ្មានប្រាក់កម្រៃ ខណៈពេលដែលបងប្អូនប្រុសរបស់ពួកគេមានពេលទំនេរក្នុងការ 'ដើរលេង' (Y៤ ស្ត្រី) 'សម្រាក' (Y១១ ស្ត្រី) 'រំលឹកមេរៀន' (Y១ ស្ត្រី) ឬ 'លេងបាលជាមួយមិត្តភក្តិ' (Y៤ អ្នកស្រលាញ់ភេទដូចគ្នាជា Tomboy)។[១]

មិនខុសពីសាច់រឿងដែលបានចែករំលែកដោយស្ត្រីដែលរងផលប៉ះពាល់ពីបន្ទុកការងារថៃទាំគ្មានប្រាក់កម្រៃច្រើនជាងលើសលុបកាលពីកុមារ ទិន្នន័យបែបបរិមាណវិស័យក៏ចង្អុលបង្ហាញនូវអតុល្យភាពនៃការបំពេញការងារថៃទាំគ្មានប្រាក់កម្រៃនាពេលបច្ចុប្បន្នចំពោះកុមារផងដែរ៖ ក្នុងចំណោមអ្នកឆ្លើយតប ៥ នាក់ មានច្រើនជាង ៤ នាក់ ដែលជឿថា ជាធម្មតាកូនស្រីធ្វើការងារផ្ទះច្រើនជាងកូនប្រុស។ ផ្ទុយមកវិញ មានតែ ១.៧% ប៉ុណ្ណោះដែលយល់ថា ជាធម្មតាកូនប្រុសធ្វើការងារថៃទាំគ្មានប្រាក់កម្រៃច្រើនជាងកូនស្រី។

**គំនូសសម្គាល់ទី ៣៖ នៅក្នុងគ្រួសារកម្ពុជា តើអ្នកគិតថាកូនមួយណាដែលធ្វើការងារផ្ទះច្រើនជាងគេ?**




[១]នៅពេលសួរទៅកាន់អ្នកចូលរួមដែលជាអ្នកស្រលាញ់ភេទដូចគ្នាទាំងបួននាក់អំពីសព្វនាម និងពាក្យគន្លឹះអ្វីដែលពួកគេចង់ឲ្យយើងប្រើប្រាស់នៅក្នុងរបាយការណ៍នេះ អ្នកចូលរួមពីរនាក់កំណត់ខ្លួនថាជាស្ត្រីស្រឡាញ់ស្ត្រី (ប្រើសព្វនាម នាង) ខណៈដែលអ្នកចូលរួមពីររូបទៀតកំណត់អត្តសញ្ញាណជា Tomboy (ប្រើសព្វនាម គាត់)។ នៅក្នុងបរិបទកម្ពុជា ពាក្យ Tomboy (ឬ Tom) ត្រូវបានប្រើប្រាស់ដោយមនុស្សមួយចំនួន ដើម្បីកំណត់អត្តសញ្ញាណខ្លួនឯង ដោយសំដៅលើទិន្នាការភេទ និង/ឬការបង្ហាញយេនឌ័រ និង/ឬ អត្តសញ្ញាណយេនឌ័រ។ ឧទាហរណ៍៖

- Tomboy (ឬ Tom) អាចជាពាក្យស្ត្រីដែលមានអត្តសញ្ញាណយេនឌ័រស្របតាមភេទស្រីពីកំណើតប្រើដើម្បីកំណត់អត្តសញ្ញាណរបស់ពួកគេ។ ពួកគេមានទំនោរស្លៀកពាក់ កាត់សក់ ឬមានអាកប្បកិរិយាដែលគេចាត់ទុកថាបែបបុរស ហើយមានរម្មណ៍ស្រឡាញ់ស្ត្រី (ជួនកាលពួកគេក៏អាចប្រើពាក្យ 'butch lesbian' ឬ 'masculine lesbian ' កំណត់អត្តសញ្ញាណផងដែរ)។
- Tomboy (ឬ Tom) ក៏អាចជាពាក្យដែលប្រើដោយអ្នកមានភេទស្រីពីកំណើត តែមានអត្តសញ្ញាណយេឌ័រជាបុរស (ជួនកាលពួកគេកំណត់អត្តសញ្ញាណជាអ្នកប្តូរយេនឌ័រជាបុរស) ហើយមានរម្មណ៍ស្រឡាញ់ស្ត្រី (Faminine women)។

ពាក្យ Tomboy (ឬ Tom) នៅក្នុងប្រទេសកម្ពុជា អាចត្រូវបានប្រើប្រាស់ខុសៗគ្នាដោយមនុស្សផ្សេងគ្នាទៅតាមតំបន់ភូមិសាស្ត្រផ្សេងៗគ្នា។ ការប្រើប្រាស់របស់ពាក្យនេះក៏អាចខុសគ្នាពីប្រទេសផ្សេងទៀតដូចជាប្រទេសថៃជាដើម។ ដូចនេះ ជម្រើសដ៏ល្អបំផុតនោះគឺសួរទៅបុគ្គលនោះផ្ទាល់ពីអត្តសញ្ញាណរបស់គេ មុនពេលសន្មត ឬកំណត់ទិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ឬការបង្ហាញភេទរបស់ពួកគេ។

# ការយល់ឃើញអំពីការបាត់បង់ឱកាសផ្សេងៗ (ត)

*“មានផលប៉ះពាល់ជាច្រើននៅពេលដែលយើងបែកចែកការទទួលខុសត្រូវមិនស្មើភាពគ្នា។*

*នៅពេលដែលសង្គមបែងចែកទំនួលខុសត្រូវបែបនេះ ធ្វើស្ត្រីធំឡើងជាមួយការយល់ឃើញថា ពួកគាត់មិនចាំបាច់ខំប្រឹងរៀនទោះទេ ព្រោះថាពួកគេនៅតែត្រូវទទួលខុសត្រូវលើការងារមើលថែទាំ និងការងារផ្ទះដដែល។ ការមាន [ផ្នត់គំនិត] បែបនេះធ្វើឱ្យពួកគេបាត់បង់ឱកាសជាច្រើន ហើយក៏ប៉ះពាល់ដល់កម្លាំងចិត្តរបស់ពួកគាត់ក្នុងការចាប់យកឱកាសទាំងនោះ ក៏ដូចជាក្តីស្រមៃរបស់ពួកគេផងដែរ”*

(C២ ស្ត្រី )។

ដោយសារតែស្ត្រីគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការពង្រឹងសម្ថភាពខ្លួនឯង អ្នកចូលរួមបានរាយការណ៍ថា ស្ត្រីមិនអាចទទួលបានការសិក្សា ពេញលេញ និងមានគុណភាពនោះទេ។ ជាលទ្ធផល ពួកគេ មិនមានជម្រើសច្រើនក្នុងជីវិតនោះទេ ក្រៅតែពីការងារជាស្ត្រីមេផ្ទះ ហើយក៏ត្រូវផាត់ចេញពីវិស័យការងារផ្លូវការផងដែរ។[២]

អ្នកតបសម្ភាសន៍ជាបុសម្នាក់បានចូលរួមជាមតិដែរថា “ប្រសិនបើក្រុមគ្រួសារនៅតែបន្តប្រកាន់ភ្ជាប់នូវផ្នត់គំនិតដែលថា កូនស្រីត្រូវតែជាអ្នកធ្វើការងារផ្ទះ នោះពួកគេ (កូនស្រី) នឹងជាអ្នករងផលប៉ះពាល់... ពោលគឺការរៀនសូត្ររបស់ពួកគាត់នឹងធ្លាក់ចុះ។ នៅថ្ងៃអនាគត ប្រសិនបើពួកគេ រៀបការ ពួកគេនឹងបន្តអនុវត្តផ្នត់គំនិតនេះ” (M៦ បុរស)

ខណៈដែលបន្ទុកនៃការងារថែទាំគ្មានប្រាក់កម្រៃបង្អាក់ក្មេងស្រីមិនអាចទៅរៀនទៀងទាត់ និងគ្មានពេលវេលាគ្រប់គ្រាន់ សម្រាប់ធ្វើលំហាត់បន្ថែដោយសារតែបន្ទុកនេះទៀតសោត ត្រូវបានអ្នកចូលរួមបន្ថែមថាក៏ប៉ះពាល់ដល់ការពង្រឹងសម្ថភាព និងសុភមង្គលផ្ទាល់ខ្លួន ក៏ដូចជាការចូលរួមសកម្មភាពសង្គមផ្សេងៗផងដែរ។ ដូចដែលអ្នកចូលរួមយើងម្នាក់លើកឡើង “កូនស្រីត្រូវលាងចានធ្វើម្ហូប និងមើលថែទាំប្អូនប្រុសស្រីមុនពេលទៅរៀន រីឯកូនប្រុសមិនចាំបាច់ធ្វើរឿងទាំងនេះទេ ពួកគេគ្រាន់តែរំពូកមេរៀន និងទៅសាលាបានហើយ។ ប្រការនេះ ក្មេងស្រីមិនមានពេលទំនេរគ្រប់គ្រាន់ធ្វើរឿងដែលចូលចិត្ត និងទទួលបានភាពរីករាយផ្ទាល់ខ្លួននោះទេ” (Y១ ស្ត្រី)។ អ្នកចូលរួមម្នាក់ទៀតបានបន្ថែមថា “ក្មេងស្រីនឹងមិនអាចឈ្វេងយល់ពីសង្គម... ឬពិភពខាងក្រៅនោះទេ [ដូច្នេះ] ពួកគេមិនមានភាពរីករាយពេញលេញទេ” (M៥បុរស)

ផ្ទុយទៅវិញ អ្នកចូលរួមខ្លះទៀតបង្ហាញការយល់ឃើញថាការងារថែទាំគ្មានប្រាក់កម្រៃ មិនបង្កឱ្យមានផលប៉ះពាល់ដល់ឱកាសក្នុងការទទួលបានការអប់រំ ក៏ដូចជាទស្សនៈវិស័យរបស់ក្មេងស្រីៗលើការសិក្សាឡើយ។ ពួកគេយល់ឃើញថា ការងារផ្ទះគឺជាមធ្យោបាយមួយនៃការរៀនសូត្រ ដូចអ្នកចូលរួមជាបុរសវ័យក្មេងម្នាក់បានទាញទឡ្ហីករណ៍ថា “ការធ្វើការងារផ្ទះធ្វើឱ្យស្ត្រី និងក្មេងស្រីឆ្លាតជាងមុន ដោយសារតែពួកគេដឹងពីដំណើរការ និង ការធ្វើការងារទាំងនោះ” (បុរស Y១)។ អ្នកចូលរួមជាស្ត្រីចំណាស់ម្នាក់ទៀតក៏បានលើកឡើងស្រដៀងគ្នាដែរថា ការងារផ្ទះគឺជាបន្ទុកសម្រាប់ក្មេងស្រី “ដែលបង្រៀនពួកគេឱ្យមានទំនួលខុសត្រូវទៅថ្ងៃអនាគត” (ស្ត្រី O១២)

[២] វាជាការល្អដែលត្រូវធ្វើការអង្កេតមើលថា ការងារថែទាំគ្មានប្រាក់កម្រៃពេញម៉ោង ជាមធ្យោបាយនៃគោលដៅជីវិតមួយឆ្ពោះទៅរកការងារជាផ្លូវការ នឹងមិនមែនជាបញ្ហាទេ ប្រសិនបើត្រូវបានធ្វើការជ្រើសរើសដោយពិតប្រកដដោយស្ត្រីម្នាក់ៗ (ឬជាបុគ្គលមានយេនឌ័រផ្សេងទៀត)។ ការធ្វើជាអ្នកមើលថែទាំផ្ទះពេញម៉ោងអាចជាជម្រើសដ៏មានអត្ថន័យ និងជាមោទនភាពមួយក្នុងឆាកជីវិត ដែលមិនគួរត្រូវបានបន្ទាបតម្លៃឡើយ។ ទោះបីជាយ៉ាងណា ប្រសិនបើបទដ្ឋានសង្គមផ្អែកលើយេនឌ័រ និងការមានកង្វះខាតក្នុងការទទួលបានការអប់រំ ឬការគាំទ្រត្រូវបានកាត់បន្ថយពីភ្នាក់ងារស្ត្រី និងការធ្វើការសម្រេចចិត្តដោយខ្លួនឯង រហូតដល់កម្រិតដែលនាងមិនអាចសម្រេចចិត្តបាន ឬព្យាយាមបន្តគោលដៅជីវិតរបស់នាងបាន ក្រៅពីការបំពេញការងារពេញម៉ោងរបស់ការងារថែទាំគ្មានប្រាក់កម្រៃនោះវាអាចជាបញ្ហាចម្បងមួយ និងអាចរួមបញ្ចូលទាំងការបំពានទៅលើសិទ្ធិមនុស្សទៀតផង។

# ការយល់ឃើញអំពីការបាត់បង់ឱកាសផ្សេងៗ (ត)

បន្ទុកមិនស្មើគ្នានៃការងារថែទាំគ្មានប្រាក់កម្រៃនេះមិនត្រឹមតែផ្តល់ផលប៉ះពាល់ទៅលើលទ្ធផលនៃការសិក្សារបស់ក្មេងស្រីនោះទេ វាក៏អាចបន្តផ្តល់ផលប៉ះពាលដល់ការងាររបស់ពួកគេនៅថ្ងៃខាងមុខផងដែរ។ ពួកគេប្រហែលជាមិនអាចចូលរួមវគ្គសិក្សាបន្ថែមដើម្បីអភិវឌ្ឍខ្លួន និងសមត្ថភាពរបស់ពួកគេលើជំនាញវិជ្ជាជីវៈផ្សេងៗ។  ករណីពីរខាងក្រោមគឺឧទាហរណ៍ដែលគួពិចារណា៖

*“ខ្ញុំត្រូវឈប់រៀនថ្នាក់ភាសាអង់គ្លេសដែលក្រុមហ៊ុនបង់ប្រាក់ឱ្យរៀន ព្រោះប្តីរបស់ខ្ញុំតែងខលទូរស័ព្ទហៅត្រឡប់ទៅផ្ទះវិញ ដោយសារតែគាត់មិនអាចមើលថែកូនតែម្នាក់ឯងបាន” (Y១៧ ស្ត្រី )។*

*“ខ្ញុំជាម្តាយម្នាក់ ហើយខ្ញុំក៏ចង់បន្តថ្នាក់អនុបណ្ឌិតដែរ ប៉ុន្តែខ្ញុំត្រូវរៀននៅថ្ងៃចុងសប្តាហ៍ ហើយខ្ញុំមិនមានពេលគ្រប់គ្រាន់សម្រាប់ធ្វើការងារផ្ទះ និងមើលថែកូនឡើយ [ដូច្នេះការងារថែទាំគ្មានប្រាក់កម្រៃ] ប៉ះពាល់ដល់ [ស្ត្រី] ពេលវេលា ដែលធ្វើឱ្យពួកគាត់ពុំអាចអភិវឌ្ឍអាជីពការងាររបស់ពួកគាត់ទៅមុខបាន។ បុរសមិនដែលខ្វល់ខ្វាយអំពីរឿងទាំងនេះឡើយ ប្រសិនបើពួកគាត់ចង់ធ្វើអ្វីមួយ គាត់នឹងធ្វើវា” (Y១៦ ស្ត្រី )។*

ផ្នត់គំនិតដែលថាស្ត្រីត្រូវតែជាអ្នកលះបង់មុន ដែលជាទូទៅលើការបន្តការសិក្សាថ្នាក់ឧត្តមសិក្សាសម្រាប់វឌ្ឍនភាពការងាររបស់ពួកគេ ត្រូវបានរំលេចចេញនៅក្នុងបទសម្ភាសន៍ជាមួយអ្នកចូលរួមជាស្ត្រី (ដែលធ្លាប់ធ្វើការមានប្រាក់កម្រៃពីមុន) នៅពេលពិភាក្សាអំពីការបំពេញការងារទទួលបានប្រាក់កម្រៃដោយគ្មានការរំខានពីការងារថែទាំផ្ទះ៖

*"...ពេលខ្លះខ្ញុំត្រូវតែសុំច្បាប់ ដើម្បីចំណាយពេលវេលាមើលថែកូននៅពេលពួកគេឈឺ ប៉ុន្តែសម្រាប់ប្តីរបស់ខ្ញុំ វាពិបាកណាស់ គាត់សុខចិត្តធ្វើការងារជំនួស” (Y២ ស្ត្រី)*

ការងារថែទាំគ្មានប្រាក់កម្រៃ គឺជារនាំងដ៏ធំមួយដែលរារាំងស្ត្រីពីការចូលរួមក្នុងវិស័យការងារ និងអភិវឌ្ឍសមត្ថភាពពួកគេនៅក្នុងវិស័យនេះ [៣៦]។ នៅក្នុងប្រទេសកម្ពុជា ការចូលរួមរបស់ស្ត្រីនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចគឺមានសារៈសំខាន់ណាស់ ដែល ៨០% នៃស្ត្រីកម្ពុជាគឺធ្វើការក្រៅម៉ោង ឬ ពេញម៉ោង [៣៧]។ ប៉ុន្តែ ស្ត្រីនៅតែត្រូវបានរារាំងជាប្រព័ន្ធមិនឱ្យអភិវឌ្ឍន៍ខ្លួនទៅរកមុខតំណែងខ្ពស់ៗ ព្រោះតែការងារផ្ទះដែលគ្មានកម្រៃ [៣៨]។ អ្នកចូលរួមជាស្ត្រីជាច្រើនបានបង្ហាញថាបន្ទុក និងការទទួលខុសត្រូវលើការងារថែទាំក្នុងផ្ទះ បានប៉ះពាល់ដល់សមត្ថភាពក្នុងការជ្រើសរើស និងប្រកបអាជីពការងារដែលសមស្របតាមសមត្ថភាពរបស់ពួកគេ។

ចំណុចនេះនឹងពិភាក្សាបន្ថែមនៅក្នុងផ្នែកបន្ទាប់នៃរបាយការណ៍អំពី “បន្ទុកទ្វេគុណ” ការងារថែទាំគ្មានប្រាក់កម្រៃគឺជាការងារដែលត្រូវធ្វើជារៀងរាល់ថ្ងៃ ឥតឈប់ឈរ ហើយអ្នករ៉ាប់រងការងារនេះត្រូវចំណាយទាំងពេលវេលា និង កំលាំងកាយក្នុងការបំពេញ។ ការណ៍នេះរារាំងស្ត្រីមិនឱ្យបានទទួលបានតួនាទី ឬម្យ៉ាងទៀតការងារដែលសមស្របនៅក្នុងទីផ្សារ។ បើទោះបីជាស្ត្រីមានការងារធ្វើក៏ដោយ (ស្ត្រីភាគច្រើននៅកម្ពុជាមានការងារធ្វើ) ពួកគាត់នឹងត្រូវប្រឈមមុខទៅនឹងបញ្ហា “ការបន្ថយកម្រិតការងារ” ដែលពួកគាត់នឹងត្រូវធ្វើការងារដែលមានកម្រិតទាបជាងសមត្ថភាពដែលពួកគាត់អាចធ្វើបាន និង/ឬ លក្ខខណ្ឌការងារមិនល្អ។ អ្នកចូលរួមជាបុរសម្នាក់បានលើកឡើង ចំណុចដែលអ្នកចូលរួមជាស្ត្រីជាច្រើនបានបង្ហាញ “ការងារថែទាំគ្មានប្រាក់កម្រៃជាមូលហេតុដែលទាំឱ្យពួកគាត់មិនអាចស្វែងរកឱកាសការងារវិជ្ជាជីវៈបាន ដែលធ្វើឱ្យពួកគាត់ពិបាកក្នុងការកសាងអាជីពការងារដោយខ្លួនឯង” (C១ បុរស )។ ដូច្នេះ ស្ត្រីជាច្រើនមិនមានជម្រើសផ្សេងទេ គឺមានតែទទួលយកការងារដែលមានស្រាប់សម្រាប់ពួកគេ។

# បន្ទុកទ្វេគុណ

*“ការធ្វើជាបុគ្គលិកគម្រូ និង ជាដៃគូដ៏ល្អក្នុងពេលតែមួយគឺពិបាក និងហត់នឿយណាស់។ ប៉ុន្តែបើខ្ញុំមិនធ្វើ តើបានអ្នកណាជាអ្នកធ្វើ? ការងារទាំងនេះជាតួនាទីរបស់ស្ត្រី ទោះបីជាហត់នឿយប៉ុណ្ណា ក៏ស្ត្រីត្រូវតែធ្វើឱ្យបាន” (ស្ត្រី O២)។*

បន្តពីផ្នែកមុន អ្នកចូលរួមជាច្រើនបានឆ្លើយតបបែបគុណវិស័យជាច្រើន ក្នុងអំឡុងពេលសម្ភាសន៍ដែលផ្តោតលើបញ្ហាលំបាកដែលស្ត្រីជួបប្រទះនៅក្នុងការរកការងារធ្វើ ស្របពេលជាមួយនឹងការទទួលបន្ទុកដ៏ធ្ងន់ពីការងារថែទាំគ្មានប្រាក់កម្រៃដែលបែងចែកមិនស្មើភាពគ្នានៅផ្ទះ។ ជាការពិតណាស់ មិនមែនបុគ្គលគ្រប់រូបដែលត្រូវធ្វើការងារថែទាំគ្មានប្រាក់កម្រៃគឺទទួលបានការងារក្រៅពីការងារផ្ទះឡើយ ការឆ្លើយតបមួយចំនួនធំបានលើកឡើងថា ខណៈដែលបុរសត្រូវទៅធ្វើការនៅខាងក្រៅផ្ទះ ហើយស្ត្រី “អត់មានការងារ” គឺជារឿងយុត្តិធម៌ហើយ ដែលស្ត្រីត្រូវរ៉ាប់រងការងារថែទាំគ្មានប្រាក់កម្រៃនោះ (ទោះបីជាយ៉ាងណា យើងអាចឆ្លើយតបវិញថា វាអាចមានភាពស្មើគ្នាដែរ ប្រសិនបើការបំពេញតួនាទីការងារផ្ទះរបស់ស្ត្រី គឺធ្វើតែត្រឹមម៉ោងការងានោះ)។

ដោយមិនរាប់បញ្ចូលស្ត្រីមួយចំនួនតូចដែលគ្មានការងារអ្វីទាំងអស់ក្រៅពីការងារផ្ទះ ចំនួនបុគ្គលចូលរួមជាច្រើនដែលជាស្ត្រី រួមទាំងនៅតំបន់ប្រជុំជន និង ជនបទ និងមកពីវណ្ណៈសង្គមផ្សេងៗ បានរៀបរាប់អំពីបញ្ហាប្រឈម និងការលំបាកក្នុងការរស់នៅជាមួយជីវិតដែលមាន “បន្ទុកទ្វេគុណ” ដែលទទួលបាន និងមិនទទួលបានប្រាក់កម្រៃពីការងារ។




គំនូសសម្គាល់ទី ៤៖ តើស្ត្រីជាប្រពន្ធចំណាយពេលប៉ុន្មានម៉ោងក្នុងមួយថ្ងៃក្នុងការមើលថែគ្រួសារ?




គំនូសសម្គាល់ទី ៥៖ តើបុរសជាប្តីចំណាយពេលប៉ុន្មានម៉ោងក្នុងមួយថ្ងៃក្នុងការមើលថែគ្រួសារ?

*“ទោះបីជាយើងទាំងពីរទៅធ្វើការក្តី ក៏នៅពេលដែលយើងត្រឡប់មកវិញ ខ្ញុំនៅតែត្រូវធ្វើការងារផ្ទះដដែល។*

*ឧទាហរណ៍ ពួកយើងទាំងពីរធ្វើការសំណង់ដូចគ្នា។ នៅពេលដែលពួកយើងត្រឡប់មកផ្ទះ ខ្ញុំត្រូវតែជាអ្នកដាំបាយធ្វើម្ហូប តែគាត់អាចសម្រាក ហើយនៅពេលអាហាររួចរាល់ ពួកយើងក៏ញ៉ាំជុំគ្នា។*

*បន្ទាប់ពីញ៉ាំរួច យើងក៏ត្រូវត្រឡប់ទៅធ្វើការវិញ។ ដូច្នេះខ្ញុំមិនមានពេលសម្រាកឡើយ”*

(ស្ត្រី M១១)។

# បន្ទុកទ្វេគុណ (ត)

*“ទោះបីជាមានការងារ ឬ គ្មានការងារធ្វើក្តី [ការងារថែទាំគ្មានប្រាក់កម្រៃ] នៅតែជាកាតព្វកិច្ចរបស់ស្រ្តីជាជាងបុរស ដោយសារតែ... ស្រ្តីមានបទពិសោធន៍ក្នុងការធ្វើការងារផ្ទះ នៅពេលដែលអ្នកធ្លាប់ធ្វើវាពីមុន អ្នកត្រូវតែធ្វើវាបន្តទៀត។ គេប្រើឲ្យស្រ្តីបោសសម្អាតផ្ទះ ដូច្នេះពួកគេនៅត្រូវតែធ្វើការងារនេះដដែល បើទោះបីជាមានការងារ [ដែលទទួលបានប្រាក់កម្រៃ] ធ្វើក៏ដោយ។ នៅពេលដែលស្រ្តីត្រលប់មកពីធ្វើការងារវិញ ពួកគាត់ត្រូវចំអិនម្ហូប -ល- ការងារនេះនៅតែជាតួនាទីរបស់ពួកគាត់។”*

(បុរស Y៤)

ស្រ្តីជាច្រើនបានឆ្លុះបញ្ចាំងឱ្យឃើញអំពីភាពលំបាកដែលពួកគាត់ជួបប្រទះជាមួយនឹងបន្ទុកទ្វេគុណ ដែលនាំឲ្យប៉ះពាល់ដល់សុខភាព និងសុខុមាលភាពផងដែរ និងធ្វើឱ្យពួកគាត់មានអារម្មណ៍ថាខុស ដោយសារតែការបំពេញការងារមិនបានពេញលេញ ក៏ដូចជាបន្ទុកពីការងារថែទាំគ្មានប្រាក់កម្រៃជាការងារផ្ទះដែលពិបាកក្នុងការធ្វើការងារឱ្យបានល្អ។ កត្តានេះអាចនាំឱ្យពួកគាត់មានអារម្មណ៍ “នឿយហត់” និង “បារម្ភ” សម្រាប់អ្នកចូលជាច្រើន រាប់បញ្ចូលទាំងស្រ្តីវ័យចំណាស់ដែលចូលរួមខាងក្រោមផងដែរ៖

*“នៅក្នុងកន្លែងការងារ ខ្ញុំត្រូវការផ្តោតអារម្មណ៍... ខ្ញុំមិនអាចបណ្តោយអារម្មណ៍របស់ខ្ញុំប៉ះពាល់ដល់ការងារបានឡើយ។ យើងត្រូវតែបែងចែកឲ្យច្បាស់ ទោះបីជាយើងមិនសប្បាយចិត្តចំពោះអ្វីដែលកើតឡើងនៅផ្ទះក៏ដោយ។ វាមានសម្ពាធខ្លាំងណាស់ ហើយវានឿយហត់ណាស់... បន្ទាប់ពីបញ្ចប់ការងារ យើងត្រូវត្រឡប់ទៅធ្វើការងារផ្ទះវិញ ហើយខ្ញុំមានអារម្មណ៍ថាការងារជាច្រើនកំពុងរង់ចាំខ្ញុំទៅបំពេញ” (ស្រ្តី O៨)។*

អ្នកចូលរួមម្នាក់ទៀតបានគូសបញ្ជាក់ថា ការនឿយហត់នេះមានផលប៉ះពាល់អវិជ្ជមានដល់សមត្ថភាពស្រ្តីក្នុងការបំពេញការងាររបស់ពួកគាត់ឱ្យបានល្អ៖

*“គុណភាពការងាររបស់ស្រ្តីនឹងថយចុះ ព្រោះតែពួកគាត់មានការនឿយហត់ពី... ការងារផ្ទះ ពីការងារគ្រប់យ៉ាងដែលពួកគាត់ត្រូវធ្វើ... ឧទាហរណ៍ ប្រសិនបើគាត់មានការងារដែលត្រូវធ្វើដំណើរឆ្ងាយពីផ្ទះ នោះគុណភាពការងាររបស់ពួកគាត់នឹងថយចុះ ដោយសារតែបារម្ភថាគ្មានអ្នកណាធ្វើការងារផ្ទះ”*

ការមានអារម្មណ៍ថាបារម្ភបែបនេះជាប់ជានិច្ច និងទំនួលខុសត្រូវការងារផ្ទះក្នុងការគ្រប់គ្រងការងារថែទាំគ្មានប្រាក់កម្រៃគឺនឹងត្រូវពិភាក្សាបន្តនៅផ្នែក (៤.២) អំពី ‘បន្ទុកផ្លូវចិត្ត’។

***“ស្រ្តីអាចធ្វើការងារខាងក្រៅដើម្បីចិញ្ចឹមខ្លួនដូចជាបុរសដែរ ហើយពេលខ្លះពួកគាត់អាចរកចំណូលបានច្រើនជាងទៀតផង។***

***ពួកគេទាំងពីរនឿយហត់ពីការធ្វើការងារខាងក្រៅដូចគ្នា ប៉ុន្តែស្រ្តីត្រូវទទួលខុសត្រូវធ្វើការងារផ្សេងទៀតដើម្បីជាផលប្រយោជន៍ដល់គ្រួសារទាំងមូល។***

***តើមូលហេតុអ្វីបានជាបន្ទុកធ្លាក់ទៅលើតែពួកគាត់ម្នាក់ឯងដូច្នេះ? ការធ្វើបែបនេះគឺមិនយុត្តិធម៌ និងមិនមានសមភាពទេ ពេលគឺគ្មានភាពស្មើភាពគ្នាទាល់តែសោះ”***

(Y៤ Tomboy អ្នកស្រលាញ់ភេទដូចគ្នា)។

# ការគ្រប់គ្រងហិរញ្ញវត្ថុក្នុងគ្រួសារ

ការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារគឺជាផ្នែកមួយនៃការងារថែទាំគ្មានប្រាក់កម្រៃ/បន្ទុកផ្លូវចិត្ត ដែលមិនមែនជាលក្ខណៈពិសេសអ្វីនៅក្នុងការសាកសួរនោះឡើយ ប៉ុន្តែបានលេចឡើងដោយសារការឆ្លើយតបរបស់អ្នកចូលរួមជាច្រើន។ ដូចអ្នកសិក្សាស្រាវជ្រាវពីមុនមក [៣៩] បានកត់សម្គាល់ឃើញ នៅក្នុងប្រទេសកម្ពុជា ភាគច្រើននៃទំនួលខុសត្រូវធ្លាក់ទៅលើស្ត្រីជាអ្នកគ្រប់គ្រង។

ការនិយាយការពិតទាំងនេះជារឿយៗ គឺត្រូវបានបកស្រាយក្នុងន័យវិជ្ជមាន ក្នុងនោះក្រៅពីការរកចំនូលបានតិចជាងប្តី និងត្រូវគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារផងដែរនោះ ស្ត្រីអាចនឹងពេញចិត្តទៅលើសមត្ថភាពសម្រេចចិត្តផ្សេងៗមួយចំនួន [40]។ លើសពីនេះទៀត ជារឿយៗគេកត់សម្គាល់ថា ស្ត្រីមានទំនួលខុសត្រូវជាងនៅក្នុងការធានាទៅលើការចំណាយក្នុងគ្រួសារទៅលើអាហារ និងការមើលថែទាំសុខភាព។

អ្វីដែលមិនសូវបានពិភាក្សាគឺ ការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ គឺជាការងារដែលគ្មានចំនូល ចំណាយពេលច្រើន និងជាការងារដែលផ្អែកលើយេនឌ័រ ដែលស្ត្រីភាគច្រើនត្រូវទទួលរងបន្ទុកនេះ ភាគច្រើនមិនបានទទួលការគាំទ្រពីប្តីផង។ អ្នកចូលរួមជាបុរសមួយចំនួន លើកឡើងថា "ការគ្រប់គ្រងជីវិត" បែបនេះ តែងតែធ្វើឡើងដោយដៃគូររបស់ពួកគាត់ដោយគ្មានបញ្ហាអ្វីនោះឡើយ៖

*"ចំពោះខ្ញុំ ខ្ញុំគិតថាស្ត្រីត្រូវតែជាអ្នកធ្វើកិច្ចការនេះ ព្រោះពួកគាត់ដឹងថាធ្វើយ៉ាងមិច ហើយធ្វើបានល្អទៀតផង ប្រសិនបើបុរសធ្វើវា គាត់មិនដឹងចាប់ផ្តើមពីចំណុចណាទេ ព្រោះតែគាត់មិនដែលធ្វើវាពីមុនមកឡើយ"*
(Y៦ បុរស )។

ចំពោះស្ត្រីជាអ្នកចូលរួមមួយចំនួន ទោះយ៉ាងណា ពួកគាត់រៀបរាប់ថាបន្ទុកការងារទាំងអស់នោះគឺទាមទារការរៀបចំ និងត្រូវការតាមដានជានិច្ចនូវ "រាល់សកម្មភាពផ្សេងៗដែលកើតឡើងនៅក្នុងផ្ទះ" (O៨ ស្ត្រី)។ ស្ត្រីម្នាក់ទៀតបាននិយាយថា "ទោះបីជាបុរសត្រូវបានហៅថា អ្នករកស៊ីចិញ្ចឹមក៏ដោយ... ក៏ស្ត្រីគឺជាអ្នកដែលគ្រប់គ្រងប្រាក់ទាំងនោះ ជាមួយនឹងការងារផ្ទះតូចតាចទាំងនោះ ដូច្នេះពួកគាត់ទទួលរងសម្ពាធខ្លាំងជាង" (Y៥ ស្ត្រី)។

*"អ្នកមើលថែផ្ទះចម្បងគឺស្ត្រី តាមគំនិតរបស់ខ្ញុំ។*

*ព្រោះតែស្ត្រីគឺជាអ្នកដែលគ្រប់គ្រងថវិកា ហើយនៅពេលដែលមានរឿងអ្វីទាក់ទងនឹងការគ្រប់គ្រងថវិកាគឺពួកគាត់ត្រូវតែមានរបៀបរៀបរយ ពួកគាត់ត្រូវតែគ្រប់គ្រងអ្វីៗទាំងអស់ឱ្យបានជោគជ័យ។*

*យើងអាចនិយាយបានម្យ៉ាងទៀតថា ស្ត្រីភាគច្រើនគឺគ្រប់គ្រងទៅលើកិច្ចការទូទៅក្នុងគ្រួសារ"*

(ស្ត្រី O១)។

# តួនាទីរបស់ឪពុកម្ដាយ និង ជីដូនជីតា

*“នៅពេលព្រឹក ខ្ញុំក្រោកពីម៉ោង ៤ ហើយ បន្ទាប់មកធ្វើលំហាត់ប្រាណខ្លះៗ។ បន្ទាប់មកខ្ញុំបង្កាត់ភ្លើងដាំបាយ។ ខ្ញុំធ្វើអាហារពេលព្រឹកសម្រាប់កូនៗ និង ចៅៗរបស់ខ្ញុំ...*

*បន្ទាប់មកកូនៗរបស់ខ្ញុំទៅធ្វើការ ដូច្នេះខ្ញុំត្រូវយកចៅៗរបស់ខ្ញុំទៅរៀន។ បន្ទាប់មកខ្ញុំទៅផ្សារដើម្បីទិញម្ហូបយកមកចំអិនសម្រាប់អាហារថ្ងៃត្រង់នៅម៉ោង ១១។*

*ខ្ញុំគិតថាការមើលថែទាំចៅរបស់ខ្ញុំគឺត្រូវចំណាយពេលវេលាច្រើនណាស់ ព្រោះតែខ្ញុំត្រូវសិតសក់ឱ្យពួកគេ ងូតទឹកឱ្យពួកគេ រៀបចំពួកគេឱ្យចូលគេង និង បង្ហាត់បង្រៀនពួកគេ។ នៅពេលរសៀល ខ្ញុំបង្រៀនពួកគេឱ្យរៀនសរសេរអក្សរ និងចងចាំតារាងមេគុណ”*

(ស្ត្រី ០១៥)។

ទោះបីជាការសិក្សាស្រាវជ្រាវនេះផ្ដោតជាចម្បងទៅលើទិដ្ឋភាពអំពីការងារថែទាំគ្មានប្រាក់កម្រៃពាក់ព័ន្ធនឹងការងារផ្ទះក៏ដោយ ក៏អ្នកចូលរួមជាច្រើនបានលើកឡើងអំពីចំណុច តួនាទីក្នុងការមើលថែទាំកូនរវាងស្ត្រី និង បុរស (ក្មេងស្រី និង ក្មេងប្រុស) នៅក្នុងផ្ទះផងដែរ។

ទោះបីជាអ្នកចូលរួមមួយចំនួនមានលទ្ធភាពបញ្ជូនកូនទៅកាន់សេវាថែទាំកុមារបង់ថ្លៃក៏ដោយ ក៏ការឆ្លើយតបបានបង្ហាញថា ឪពុកម្ដាយភាគច្រើនពឹងផ្អែកជាខ្លាំងទៅលើការគាំទ្ររបស់សមាជិកគ្រួសារ ជាពិសេសយាយម្ដាយមីង ឬបងស្រីជាអ្នកជួយមើលថែកូនៗរបស់ខ្លួន។ អ្នកចូលរួមជាច្រើននិយាយថា បើគ្មានការជួយពីពួកគាត់ទេ ពួកគេនឹងមិនអាចទៅធ្វើការនៅខាងក្រៅបានឡើយ “ប្រសិនបើមានជីដូនជាអ្នកមើលថែកូននោះ អញ្ចឹងប្ដីប្រពន្ធអាចទៅធ្វើការងារបាន...” (ស្ត្រីY៩) ។

ការលើកឡើងនេះគឺពាក់ព័ន្ធជាមួយនឹងតម្រូវការសេវាថែទាំកុមារដែលមានភាពងាយស្រួល និងមានតម្លៃសមរម្យ ធ្វើដូច្នេះទើបឪពុកម្ដាយអាចទៅធ្វើការវិញបានដោយមានភាពបត់បែនខ្ពស់ ហើយជីដូនជីតា ជាពិសេសជីដូនមិនប្រឈមមុខដោយផ្ទាល់ជាមួយនឹងការក្លាយទៅជាអ្នកមើលថែពេញម៉ោងរបស់ចៅៗដោយគ្មានជម្រើស។ សរុបមក ការមើលថែក្មេងៗ ពេលខ្លះអាចនិយាយបានថាមានលាភ និងមានគេចូលចិត្តច្រើន ប៉ុន្តែវានឿយហត់ និងជាការងារប្រើកម្លាំង ហើយត្រូវទទួលយកដោយស្ត្រីវ័យចំណាស់ ព្រោះតែគាត់គ្មានជម្រើសការងារផ្សេងនោះទេ។

បើយើងសង្កេតមើលទៅ តួនាទីជាជីតានៅក្នុងមើលថែចៅគឺគ្មាននៅទិន្នន័យក្នុងការឆ្លើយតបឡើយ។ ចំណុចនេះគឺបានបញ្ជាក់ឱ្យឃើញអំពីការមិនមានភាពស្មើគ្នាក្នុងការចែកតួនាទី និងទំនួលខុសត្រូវមើលថែចៅរវាងជីដូនជីតា។

## ទស្សនៈរបស់អ្នកចូលរួមជាអ្នកស្រឡាញ់ភេទផ្ទុយគ្នាលើការបែងចែកតួនាទីការងារថៃទាំគ្មានប្រាក់កម្រៃរបស់ដៃគូស្និទ្ធស្នាលជាអ្នកស្រលាញ់ភេទដូចគ្នា

ទស្សនៈយល់ឃើញក្នុងចំណោមអ្នកចូលរួមដែលកំណត់អត្តសញ្ញាណជាអ្នកស្រឡាញ់ភេទផ្ទុយគ្នា ចំពោះការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃនៅក្នុងដៃគូអ្នកស្រលាញ់ភេទដូចគ្នាគឺមានភាពខុសគ្នា ប៉ុន្តែភាគច្រើនផ្តោតទៅលើចំណុចសំខាន់ពីរ។

ក្រុមទី១ គឺបានបង្ហាញពីការយល់ឃើញថា ដៃគូអ្នកស្រលាញ់ភេទដូចគ្នាដែលរស់នៅជាមួយគ្នា ភាគច្រើនគឺអាចជួយគ្នាទៅវិញទៅមកទាក់ទងទៅនឹងការងារថៃទាំគ្មានប្រាក់កម្រៃជាងដៃគូដែលស្រឡាញ់ភេទផ្ទុយគ្នា៖

*“តាមគំនិតរបស់ខ្ញុំ ការបែងចែកតួនាទីគឺល្អប្រសើរជាង ដៃគូដៃស្រឡាញ់ភេទផ្ទុយគ្នា ព្រោះតែផ្នត់គំនិតចាស់គំរឹលដែលគិតថាស្ត្រីត្រូវតែធ្វើការងារផ្ទះទាំងអស់... ដូច្នេះពួកគេប្រហែលជាអាចមានគំនិតល្អជាងដៃគូដែលស្រឡាញ់ភេទផ្ទុយគ្នាក្នុងការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃ” (ស្ត្រី C២) ។*

ជាការពិតណាស់ អ្នកចូលរួមជាច្រើនបានឆ្លុះបញ្ចាំងឱ្យឃើញថា ដៃគូដែលស្រឡាញ់ភេទផ្ទុយគ្នា ”ត្រូវរៀនសូត្រច្រើនណាស់” (បុរស C១) ពីដៃគូអ្នកស្រលាញ់ភេទដូចគ្នានៅក្នុងបញ្ហានេះ ហើយថា “ប្រសិនបើពួកគេអាចបែងចែកបាន យើងក៏ធ្វើបាន”។

ប្រធានបទទីពីរ គឺការលេចឡើងនូវគំនិតដែលថាដៃគូអ្នកស្រលាញ់ភេទដូចគ្នាគឺទំនងជាភាគច្រើនមានភាពស្មើគ្នាជាងក្នុងការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃដោយពួកគេប្រហែលជាមានភាពមិនស្មើភាពគ្នាខ្លះ ព្រោះការយល់ដឹងពីដៃគូម្ខាងអាចនឹងដើរតួនាទីជាបុរស និងដៃគូម្ខាងទៀតជាស្ត្រីតាមបែបប្រពៃណី៖ “ខ្ញុំបានកត់សម្គាល់ឃើញថា នៅពេលដែលយើងនិយាយអំពីការងារផ្ទះ [ដៃគូអ្នកស្រលាញ់ភេទដូចគ្នា] ចេះជួយគ្នាទៅវិញទៅមក បើទោះបីជាស្ត្រីដែលមានតួនាទីជាប្តី” (បុរស C៥)។ ទស្សនៈមួយនេះ គឺមានការលើកឡើងនៅក្នុងការឆ្លើយតបមួយចំនួន និងនិយាយដោយច្បាស់ដោយមានការកំណត់ និងមានការបង្ហាញនៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជា ឬជាទស្សនៈនិយមដែលប្រជាជនប្រកាន់ភ្ជាប់។

*“បើសម្លឹងមើលទៅដៃគូអ្នកស្រលាញ់ភេទដូចគ្នាយើងអាចរៀនសូត្របានថា យើងត្រូវរៀនបើកចំហចិត្ត និងយល់ដឹងថាការធ្វើការងារផ្ទះគឺមិនតម្រូវទៅតាមយេនឌ័ររបស់យើងនោះឡើយ។*

*វាមិនមែនជាអ្វីដែលគេឆ្លាក់ជាប់នៅលើជញ្ជាំងឡើយ”*

(ស្ត្រី C៣)។

# LGBTQ+ ទស្សនៈរបស់ក្រុមអ្នកស្រលាញ់ភេទដូចគ្នា

ចំពោះអ្នកចូលរួមដែលជាអ្នកស្រលាញ់ភេទដូចគ្នាផ្ទាល់ ទស្សនៈក៏ប្រែប្រួលផងដែរ។ គួរឱ្យសោកស្តាយ ទិន្នន័យគឺមានកម្រិត ដោយសារតែកង្វះវត្តមានរបស់បុរសដែលស្រលាញ់ភេទដូចគ្នា ឬស្ត្រីប្តូរយេនឌ័រចូលរួមនៅក្នុងការសិក្សានេះ។ ទោះជាយ៉ាងណាក៏ដោយ ដៃគូអ្នកស្រលាញ់ភេទដូចគ្នាចំនួនពីរគូរបានចូលរួមដោយសប្បុរសក្នុងការសម្ភាសន៍ស៊ីជម្រៅ និងបានផ្តល់ការយល់ឃើញ លម្អិតអំពីរបៀបដែលពួកគេ និងដៃគូរបស់ពួកគេរៀបចំការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃនៅក្នុងគ្រួសាររបស់ពួកគេ។ នៅក្នុងទំនាក់ទំនងដៃគូ ពីរនាក់កំណត់អត្តសញ្ញាណជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា (សព្វនាមនាង/របស់នាង) ហើយដៃគូរបស់ពួកគេកំណត់អត្តសញ្ញាណខ្លួនឯងថាជា Tomboys ហើយប្រើសព្វនាមគាត់/របស់គាត់។

*“វាខុសគ្នាទាំងស្រុង [ពីគូស្នេហ៍ភេទដូចគ្នា] តាមពិតក្នុងគ្រួសារយើង ដូចជាឪពុកម្តាយរបស់ខ្ញុំ ពេលឪពុកមកដល់ផ្ទះ ហើយម្ហូបមិនទាន់ឆ្អិន គាត់នឹងភ្ញាក់ផ្អើល។*

*ប៉ុន្តែតាមពិត ដៃគូរបស់ខ្ញុំមិនដូចនោះទេ។*

*ពេលខ្លះដៃគូរបស់ខ្ញុំហត់នឿយ ហើយអាហារមិនទាន់ចម្អិន ដូច្នេះខ្ញុំនឹងធ្វើវា [និងផ្ទុយមកវិញ]។*

*សម្រាប់ការទិញម្ហូប យើងនឹងគិតជាមួយគ្នា”*

(អ្នកស្រលាញ់ភេទដូចគ្នា Y៤ Tomboy)។

ចំពោះអ្នកចូលរួមម្នាក់ៗដែលកំណត់អត្តសញ្ញាណជាអ្នកស្រលាញ់ភេទដូចគ្នាបានបង្ហាញអំពីទស្សនៈថា ពួកគេ (និងដៃគូអ្នកស្រលាញ់ភេទដូចគ្នាជាទូទៅ) មានការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃបានល្អប្រសើរជាងដៃគូអ្នកស្រឡាញ់ភេទផ្ទុយគ្នា៖ "អ្នកស្រលាញ់ភេទផ្ទុយគ្នាខ្លះ ពួកគេមិនដែលដឹងថាស្ត្រីនឿយហត់ប៉ុណ្ណាទេ... ពួកគេជាបុរស ពួកគេឃើញស្ត្រី ជាអ្នកធ្វើការផ្ទះ ហើយថាវាមិននឿយហត់ទាល់តែសោះ” (អ្នកស្រលាញ់ភេទដូចគ្នា Y២ Tomboy)។ លើសពីនេះ "[អ្នកស្រលាញ់ភេទដូចគ្នា] មានទំនោរព្យាយាមស្វែងយល់អំពីអារម្មណ៍ ដៃគូរបស់ពួកគេ។ មានតែវិធីនេះទេ ដែលយើងអាចរស់នៅជាមួយគ្នាបានយ៉ាងមានសុភមង្គល និងយូរអង្វែង” (ស្ត្រីស្រលាញ់ភេទដូចគ្នា Y៣)។

ចំពោះទំនោរក្នុងចំណោមអ្នកឆ្លើយតបដែលជាអ្នកស្រឡាញ់ភេទផ្ទុយគ្នា (ថាមានតួនាទីយេនឌ័រចំពោះដៃគូអ្នកស្រលាញ់ភេទដូចគ្នាមួយចំនួនដែលជូនដំណឹងអំពីការបែងចែករបស់ពួកគេនៃការងារថែទាំគ្មានប្រាក់កម្រៃ) ចំណុចនេះត្រូវបានបង្ហាញម្តងទៀតនៅក្នុងបទសម្ភាសន៍អ្នកស្រលាញ់ភេទដូចគ្នា មួយជាមួយនឹងអ្នកចូលរួមជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នាម្នាក់បានលើកឡើងពីការពិភាក្សាអំពីសេណារីយ៉ូ ដែលដៃគូម្នាក់អាចមាន "តួនាទី ជាប្រពន្ធ" (ស្ត្រីអ្នកស្រលាញ់ភេទដូចគ្នា Y៣)។ ប៉ុន្តែជាការសំខាន់ណាស់ដែលគួរកត់សម្គាល់ថា អ្នកចូលរួមនេះបានប្រើពាក្យនេះក្នុងការពិភាក្សាអំពីរបៀបដែលអ្នកស្រលាញ់ភេទដូចគ្នាមានទំនោរ មិនរំពឹងថាដៃគូមួយនឹងធ្វើការងារក្នុងចំណែកមិនស្មើគ្នា៖

*"បុគ្គលមួយចំនួន ពួកគេស្រឡាញ់ដៃគូរបស់ពួកគេ ដូច្នេះពួកគេមិនអនុញ្ញាតឱ្យនាងធ្វើអ្វីតែម្នាក់ឯងទេ បើទោះបីជានាងមានតួនាទីជាប្រពន្ធក៏ដោយ... ឧទាហរណ៍ បុគ្គលម្នាក់អាចលាងចាន ហើយម្នាក់ទៀតប្រហែលជារៀបចំចម្អិនអាហារ... ការងារផ្ទះត្រូវបានបែងចែកស្មើៗគ្នាជាងគូស្នេហ៍ភេទផ្ទុយគ្នាភាគច្រើន"* (ស្ត្រីស្រលាញ់ភេទដូចគ្នា Y៣) ។

ប្រការនេះបង្ហាញថា ការសន្មតអំពីការបញ្ចេញមតិនៃលក្ខណៈតំណពូជដាក់ស្តែងចំពោះដៃគូអ្នកស្រលាញ់ភេទដូចគ្នាគួរតែត្រូវពិភាក្សាដោយប្រុងប្រយ័ត្ន ឬអាចនិយាយបានម្យ៉ាងទៀតថា ដៃគូអ្នកស្រលាញ់ភេទដូចគ្នាសំដៅទៅលើបុគ្គលម្នាក់ដែលមាន 'តួនាទីជាប្រពន្ធ/ប្តី' មិនចាំបាច់នាំឱ្យមានការរំពឹងទុកអំពីយេនឌ័រ ឬបទដ្ឋានការងារថែទាំគ្មានប្រាក់កម្រៃដែលមានលក្ខណៈគៀបសង្កត់ក្នុងទំនាក់ទំនងនោះទេ។

# ៤.២ បន្ទុកផ្លូវចិត្ត

*“ស្ត្រីត្រូវតែគិតអំពីការចំណាយ និងទុកដាក់ផ្ទះសម្បែងឱ្យបានស្អាតមានរបៀបរៀបរយ ចំអិនម្ហូប និងរៀបចំកម្មវិធីផ្សេងៗ ពួកយើងគឺគិតពីរឿងទាំងអស់នេះ ដូច្នេះខ្ញុំហៅវាថាជាតួនាទីប្រចាំថ្ងៃរបស់ស្ត្រី... ស្ត្រីដាច់ខាតត្រូវតែធ្វើវា ប្រសិនបើយើងមិនធ្វើវាទេ ផ្ទះរបស់យើងនឹងមិនស្អាតទេ”*
(ស្ត្រី Y៣)។

ដោយមានការកំណត់ថា ស្ត្រីនៅកម្ពុជា គឺតម្រូវឱ្យធ្វើការងារផ្ទះជាច្រើនលើសពីអ្វីដែលពួកគេអាចធ្វើបាន និងទំនួលខុសត្រូវក្នុងការថែទាំផ្ទះសម្បែង របាយការណ៍នេះពិនិត្យទៅលើបន្ទុកបន្ថែមនៃ “បន្ទុកផ្លូវចិត្ត”។ បន្ទុកផ្លូវចិត្តនេះគឺសំដៅទៅលើការគិតច្រើនអំពីការគ្រប់គ្រងនៅក្នុងផ្ទះ ដែលជាការងាររបស់ស្ត្រីកម្ពុជាតាំងពីយូរយារណាស់មកហើយ។

ដោយមានលក្ខណៈជាទម្រង់ការងារមួយដែលគ្មានបុគ្គលណាមើលឃើញ បន្ទុកផ្លូវចិត្តនេះភាគច្រើនគ្មានបុគ្គលណាចាប់អារម្មណ៍ឡើយ ជាពិសេសដៃគូដែលមានប្រពន្ធជាអ្នកធ្វើការងារនេះជំនួស។ វាគឺជាបន្ទុកដែលត្រូវតែចងចាំ ពិនិត្យមើល រៀបចំកាលវិភាគ និង រៀបចំទុកដាក់របហូត ដែលទាំងនេះគឺបង្ហាញថាវាប៉ះពាល់ទៅដល់សុខភាព និងសុខុមាលភាពរបស់ស្ត្រីជាខ្លាំង ដូចដែល Dean et al [២០២២,៤១] បានពិភាក្សា និងដូចសក្ខីកម្មរបស់អ្នកចូលរួមបានបង្ហាញនៅក្នុងផ្នែកនេះ។



## បន្ទុកផ្លូវចិត្ត (ត)

របាយការណ៍ជាច្រើនពីអ្នកចូលរួមជាបុរសបានបង្ហាញអំពីការគិតរបស់ពួកគេថា ការធ្វើការងារផ្ទះជាប្រចាំ គឺត្រូវតែបែងចែកឱ្យស្មើគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកចូលរួមជាច្រើនដែលជាបុរសដដែលនោះ ហាក់ដូចជាមិនគិតថា ការបែងចែកការងារផ្នែកបញ្ញាស្មារតីមិនស្មើភាពគ្នា (បន្ទុកផ្លូវចិត្ត) ថាជារឿងសំខាន់នោះទេ៖ “ខ្ញុំគិតថា វាជាគំនិតល្អដែលស្ត្រី គ្រប់គ្រងការងារផ្ទះ ប៉ុន្តែក្នុងការធ្វើបែបនេះ យើងត្រូវបែងចែកការងារនេះជាមួយនឹងសមាជិកក្នុងគ្រួសារ” (បុរស Y៦) ។

ករណីបែបនេះ គឺបានបង្ហាញឱ្យឃើញអំពីទស្សនៈដែលស្ត្រី គឺជាអ្នកគ្រប់គ្រងផែនការក្នុងគ្រួសារគឺជារឿងពីធម្មជាតិ និងបុរសត្រូវមានទំនួលខុសត្រូវទៅលើការងារដែលគេចាត់ទុកថា ជាការងារគិតគូរ មានកាលវិភាគច្បាស់លាស់ ផ្តល់ប្រាក់កាសទៅដល់សមាជិកគ្រួសារតាមរយៈប្រពន្ធ៖ ដូចជាការនិយាយមួយទៀតគឺ “ចំពោះការងារផ្ទះវិញ… យើងទាំងអស់គ្នាត្រូវតែចេះជួយគ្នា។ ប៉ុន្តែបើយើងនិយាយអំពី ការត្រួតពិនិត្យ និងរៀបចំការងារនៅក្នុងផ្ទះ វាគឺជាទំនួលខុសត្រូវរបស់ស្ត្រី” (បុរស O១) ។

ទោះបីជាយ៉ាងនេះក្តី ដូចការពិភាក្សានៅផ្នែកបន្ទាប់ ការចាត់តាំងតួនាទីជាអ្នកគ្រប់គ្រង គឺភ្ជាប់មកជាមួយនូវបញ្ហាប្រឈមនានា - វាជា “យុទ្ធសាស្ត្របែបបង្ហាញភាពអសមត្ថភាព” ហើយបុរសគឺជាអ្នកដែលទៅធ្វើការងារដែលធ្វើដោយមិនពេញដៃពេញជើង ដូច្នេះពួកគេនឹងមិនត្រូវបានចាត់តាំងឱ្យទៅធ្វើការងារទាំងនោះទៀតទេនៅថ្ងៃអនាគត (ស្ត្រីខ្លះបានរាយការណ៍ថា វាមានភាពងាយស្រួលជាងក្នុងការធ្វើខ្លួនឯង ឬបុរសមិនបានធ្វើការងារឱ្យបានល្អ ឬមិនធ្វើតែម្តងល្អជាង)។[៣] វាក៏ជាបន្ទុកផងដែរដែលត្រូវចងចាំរាល់ការងារ និងពេលណាត្រូវធ្វើការងារទាំងនោះ ហើយត្រូវតាមដាន និងប្រឈមមុខនឹងផលវិបាកតែម្នាក់ឯង (ពីការរិះគន់ក្នុងគ្រួសារ ក៏ដូចជាពីសង្គមខាងក្រៅ) ប្រសិនបើពួកគាត់ធ្វើការងារមិនបានល្អ។

**គំនូសសម្គាល់ទី ៦៖ តើសេចក្តីថ្លែងខាងក្រោមត្រឹមត្រូវកម្រិតណា៖ ស្ត្រីត្រូវបានគេមើលឃើញថាជា ‘អ្នកទទួលខុសត្រូវចម្បងក្នុង "ការរៀបចំជីវិត"’ មានតួនាទីរៀបចំចាត់ចែងការងារនៅក្នុងផ្ទះ (ការកក់ការណាត់ជួបរបស់កូនៗ ទិញសម្ភារៈជូតសំអាត ធ្វើតារាងទិញទំនិញ ចងចាំថ្ងៃកំណើតរបស់ឪពុកម្តាយ និងរៀបចំដំណើរកំសាន្តរបស់គ្រួសារជាដើម)**




[៣] “បើយើងពឹងឱ្យអ្នកដទៃធ្វើ វាពិបាកជាងខ្ញុំធ្វើវាដោយខ្លួនឯងទៀត ហើយខ្ញុំក៏មិនចង់និយាយច្រើនដែរ” (ស្ត្រី M៣)។

## ៤.២.១ បុរសជា “អ្នកជួយ” ធៀបនឹងជា “អ្នកធ្វើ”

*“អ្នកបានសួរខ្ញុំថាតើខ្ញុំយល់ស្របឬទេ...... ខ្ញុំយល់ស្របថា ស្ត្រីត្រូវតែជាអ្នកគ្រប់គ្រងផែនការ ហើយបុរសជាអ្នកជួយ” (បុរស Y៣) ។*

ពាក្យដែលនិយាយជាទូទៅទាំងស្ត្រី និង បុរស ដើម្បីពណ៌នាអំពីការអនុវត្តការងារថែទាំគ្មានប្រាក់កម្រៃរបស់បុរស គឺមានលក្ខណៈគ្រប់គ្រាន់ដើម្បីយកមកធ្វើការវាយតម្លៃ៖ ទំនោរដែលថាស្ត្រីជាអ្នក “ធ្វើ” ការងារផ្ទះ ហើយបុរសជាអ្នក “ជួយ” គឺប្រើប្រាស់យ៉ាងច្រើននៅក្នុងបណ្តុំទិន្នន័យបែបគុណវិស័យ៖ “នាងសប្បាយចិត្តយ៉ាងខ្លាំងនៅពេលដែលពួកយើងជួយនាង” (បុរស Y១)។

ដូចដែលបានលើកឡើងពីផ្នែកមុន ស្ត្រីកម្ពុជាភាគច្រើនធ្វើការងារនៅខាងក្រៅផ្ទះ ខ្លះធ្វើពេញម៉ោង ខ្លះទៀតធ្វើក្រៅម៉ោង មិនថាជាការងារក្នុងវិស័យផ្លូវការ ឬក្រៅផ្លូវការក្តី។ យ៉ាងណាមិញ ស្ត្រីជាអ្នកចូលរួមជាច្រើនបានកត់សម្គាល់ថា ពួកគាត់គឺមានតួនាទីជាអ្នកគ្រប់គ្រងផែនការការងារថែទាំគ្មានប្រាក់កម្រៃមិនថាពួកគាត់មានការងារខាងក្រៅឬក៏អត់នោះទេ “...នៅក្នុងប្រទេសកម្ពុជា ពួកគាត់បានមើលឃើញការងាររៀបចំផ្ទះ និងសមាជិកនៅក្នុងគ្រួសារ គឺជាភារកិច្ចរបស់ស្ត្រី មិនទាក់ទងនឹងឋានៈការងាររបស់ពួកគេឡើយ” (ស្ត្រី O១)។

តួនាទីជាអ្នករៀបចំ និងចាត់ចែងការងារគឺត្រូវបានបន្ថែមលើសពីអ្វីដែលតាមពិតស្ត្រីក៏បានរបាយការណ៍ផងដែរថាជា “ទំនួលខុសត្រូវខាងត្រួតពិនិត្យមើលថាតើការងារបានធ្វើល្អ ឬអត់” (ស្ត្រី O១០) និងស្ត្រីម្នាក់បាននិយាយថា វាគឺជាចំនេះដឹងមួយដែរដែលថា “ស្ត្រីត្រូវតែពឹងបុរសឱ្យជួយ បើមិនប្រាប់ទេ ពួកគេមិនជួយឡើយ” (ស្ត្រី Y១៧)។

ដូចជាស្ត្រីម្នាក់ទៀតបានឆ្លុះបញ្ចាំងឱ្យឃើញអំពីភាពចាំបាច់ដែលបានរាយការណ៍ឱ្យដឹងថា ការ ‘ប្រាប់’ ‘ដឹកនាំ’ ឬ ‘ដាក់ឱ្យធ្វើ’ គ្រប់ពេលសម្រាប់ដៃគូររបស់ពួកគាត់ដើម្បីឱ្យចូលរួមក្នុងការធ្វើការងារថែទាំគ្មានប្រាក់កម្រៃគឺប៉ះពាល់ទៅលើចំណងអាពាហ៍ពិពាហ៍ដោយស្មើភាព៖ “ខ្ញុំគិតថាវាមិនមានការបែងចែកដោយស្មើភាពទេ ខ្ញុំចង់បានភាពស្មើគ្នាក្នុងការងារនៅក្នុងជីវិត ប៉ុន្តែ... ខ្ញុំអាចនិយាយបានថាបុរសគឺមិនខ្វល់ខ្វាយពីការធ្វើការងារផ្ទះឡើយ ភាគច្រើនស្ត្រីយកចិត្តទុកដាក់ជាង... ប្រសិនបើយើងចង់ឱ្យដៃគូជួយយើងត្រូវបង្រៀនគាត់ និងត្រូវប្រាប់ពួកគាត់ចំពោះការងារពួកគាត់ត្រូវធ្វើ” (ស្ត្រី Y១៧)។

*“ពួកយើងញុំាអាហារជុំគ្នា។ ដូច្នេះនៅពេលញុំារួច ហេតុអ្វីបានជាស្ត្រីត្រូវតែលាងចាន និងហេតុអ្វីបានជាបុរសមិនចាំបាច់លាង?*

*ហេតុអ្វីបានជាយើងត្រូវតែប្រើពាក្យថា “ជួយ” ពេលយើងញុំាជាមួយគ្នាសោះ?*

*ឧទាហរណ៍ ប្រសិនបើស្ត្រីជាអ្នកចំអិនអាហារ ហើយនាងត្រូវលាងចានទៀត នោះគឺមិនសមហេតុផលហើយ ព្រមទាំងមិនស្មើភាពគ្នាទៀត”*

(ស្ត្រីស្រលាញ់ភេទដូចគ្នា Y១)។

# បុរសជា “អ្នកជួយ” ធៀបនឹងជា “អ្នកធ្វើ” (ត)

*“តាមពិតទៅ បុរសម្នាក់ធ្វើកិច្ចការផ្ទះ មិនមែនមានន័យថាគាត់ “ជួយ” នោះទេ ហើយក៏មិនត្រូវសរសើរគាត់ថាគាត់ល្អដែរ វាជាកាតព្វកិច្ចទូទៅ។ [ការប្រើពាក្យ 'ជួយ'] គឺដោយសារតែផ្ទត់គំនិតទូទៅរបស់យើងបានប្រាប់គាត់ថា វាជាការងាររបស់ស្ត្រី" (ស្ត្រី C៣) ។*




**គំនូសសម្គាល់ទី ៧៖ តើសេចក្តីថ្លែងខាងក្រោមនេះត្រឹមត្រូវកម្រិតណា៖ “ប្រពន្ធត្រូវបានគេមើលឃើញថាជាអ្នករៀបចំកិច្ចការផ្ទះ ចំណែកបុរស/ប្តីត្រូវបានគេមើលឃើញថាជាអ្នកជួយ”?**

ផ្ទុយទៅវិញ ទោះបីជាបុរសជាច្រើនបានដឹងយ៉ាងច្បាស់ថាពួកគេអនុវត្ត (ឬ 'ជួយ ') ការងារថែទាំគ្មានប្រាក់កម្រៃក្តី ក៏បុរសមួយចំនួនបានឆ្លុះបញ្ចាំងឱ្យឃើញអំពីការមិនចាំបាច់ក្នុងការ 'គិតអំពី' រឿងនេះតាមរបៀបដូចគ្នានឹងដៃគូរបស់ពួកគេ៖ “ប្រសិនបើនិយាយអំពីអ្វីដែលយើងគួរចំអិននៅថ្ងៃនេះ ខ្ញុំមិនគិតពីរឿងនេះទេ។ ប្រពន្ធរបស់ខ្ញុំតែងតែសួរថាខ្ញុំចង់ញ៉ាំអ្វី។ ពេលខ្លះខ្ញុំមិនឆ្លើយព្រោះខ្ញុំមិនដឹងថាចង់ញ៉ាំអ្វីដែរ” (បុរស Y៣)។

ការប្រើប្រាស់ពាក្យថា 'ជួយ' ស្របពេលដែលពិតជាមិនកំណត់ចំពោះបរិបទកម្ពុជាក្តី គឺកំពុងតែបង្ហាញថា បុរសជាច្រើនយល់ឃើញថា ជំនាញការរស់រានមានជីវិតរបស់មនុស្សពេញវ័យសំខាន់ៗ ដូចជាការចម្អិនអាហារ ការសម្អាត ការបោកគក់សម្លៀកបំពាក់ - គឺខុសពីសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេ លុះត្រាតែប្រពន្ធរបស់ពួកគេប្រគល់ភារៈកិច្ចបែបនេះឱ្យ (ជាធម្មតា មនុស្សម្នាក់ដែលមានអាយុប្រហាក់ប្រហែលនឹងពួកគេ)។ ដូចផ្នែកដែលនៅសល់នៃផ្នែកនេះនឹងបង្ហាញនៅចំណុចបន្ទាប់ ការទទួលបន្ទុកភាគច្រើននៃបន្ទុកបញ្ញាស្មារតីសម្រាប់គ្រួសារទាំងមូល គឺជាទម្រង់នៃពលកម្មឃេនឌ័រកម្រិតខ្ពស់ដែលមិនមានប្រាក់ឈ្នួល ដែលអាចប៉ះពាល់ដល់សុខុមាលភាពរបស់បុគ្គល ក៏ដូចជាសិទ្ធិទទួលបានពេលវេលាសម្រាករបស់ពួកគេផងដែរ។

*"នៅក្នុងសង្គមកម្ពុជា ជាទូទៅ បុគ្គលដែលត្រូវបានចាត់ទុកថាជាអ្នកទទួលខុសត្រូវគ្រប់គ្រង [ការងារថែទាំគ្មានប្រាក់កម្រៃ] ភាគច្រើនគឺជាស្ត្រី។ [នេះគឺ] ដោយសារតែឪពុកមិនដែលគិតពីការងារបែបនេះទេ មានតែម្តាយទេដែលប្រាប់គ្រប់គ្នាថាត្រូវធ្វើអ្វី" (ស្ត្រី Y៨)។*

# ៤.២.២ សុខភាពផ្លូវចិត្ត និង ភាពតានតឹង

ដូចដែលបានពិភាក្សា អ្នកចូលរួមភាគច្រើនក្នុងការសិក្សានេះរាយការណ៍អំពីទស្សនៈថា នៅក្នុងប្រទេសកម្ពុជាសម័យបច្ចុប្បន្ន ផ្នែកមួយនៃជីវិតអាពាហ៍ពិពាហ៍ និងភាពជាម្តាយសម្រាប់ស្ត្រីដែលស្រលាញ់ភេទដូចគ្នា គឺតែងតែព្រួយបារម្ភគ្រប់ពេលអំពីគ្រួសាររបស់ពួកគេ។ ប្រហែលជាដូចទៅក្នុងបរិបទទាំងអស់ដែរ ភាពជាម្តាយត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងទំនោរដ៏មានឥទ្ធិពលនៃ "ការពលី" និង 'ការលះបង់' តាមមធ្យោបាយដែលភាពជាឪពុកមិនមានទាល់តែសោះ។

ជាការពិតណាស់ មនុស្សដែលដាក់សេចក្តីត្រូវការរបស់អ្នកដទៃ រួមទាំងសមាជិកគ្រួសារផងដែរ ជាអាទិភាព គឺសក្តិសមនឹងទទួលបានការសរសើរ។ ទោះជាយ៉ាងណាក៏ដោយ ការលើកឡើងនានានៅក្នុងផ្នែកនេះបង្ហាញថា ចំពោះស្ត្រីមួយចំនួន ការរំពឹងទុកដែលរំពឹងលើពួកគេអាចមានភាពលើសលប់ខាងផ្លូវចិត្ត និងរាងកាយ។ ស្ត្រីមួយចំនួនរាយការណ៍ថារងបន្ទុកនៃការរំពឹងទុកដែលមិនប្រាកដប្រជាថា ដែលនៅពេលរៀបការហើយ ពួកគេនឹងផ្តល់ការងារថែទាំពេញម៉ោងបន្ថែមពីលើការងារដែលទទួលបានប្រាក់ខែ ហើយអនុវត្តការងារផ្នែកបញ្ញាស្មារតីក្នុងចំណែកដ៏ធំ ដែលត្រូវការជាចាំបាច់ដើម្បីឱ្យគ្រួសារដំណើរការទៅមុខបាន៖ "...នៅពេលដែលខ្ញុំសប្បាយចិត្ត [បន្ទុកសតិអារម្មណ៍] មិនប៉ះពាល់ដល់ខ្ញុំទេ... ប៉ុន្តែនៅពេលដែលខ្ញុំមិនសប្បាយចិត្តវិញ ខ្ញុំមានអារម្មណ៍តានតឹង និងរងបន្ទុក។ ខ្ញុំមានអារម្មណ៍ថា តាំងពីតូចមកទល់ពេលនេះ ខ្ញុំមិនអាចគេចចេញពីផ្ទះបាយបានទេ ពេលខ្លះខ្ញុំមានអារម្មណ៍មួម៉ៅ" (ស្ត្រី ០៧)។

ដោយបានបន្ទឺឡើងនូវអារម្មណ៍បែបនេះ អ្នកចូលរួមជាស្ត្រីវ័យចំណាស់ម្នាក់ទៀត (០៦) បានចង្អុលបង្ហាញថា "...យើងអស់កម្លាំង មានអារម្មណ៍ឆេវឆាវ និងងាយខឹង ដោយសារការងារហួសកម្លាំង" និងម្នាក់ទៀត (០១៣) បានបន្ថែមថា "... បន្ទុកសតិអារម្មណ៍ប៉ះពាល់ដល់ [សុខុមាលភាពផ្លូវចិត្ត] ដោយប្រយោល។ ខ្ញុំច្បាស់ណាស់វាមានឥទ្ធិពលដូច្នេះ។ ខ្ញុំឃើញថាវាតានតឹងខ្លាំងណាស់។ ប៉ុន្តែខ្ញុំត្រូវប្រាប់ខ្លួនឯងថា វាជាការទទួលខុសត្រូវរបស់ខ្ញុំ"។

គួរឱ្យសោកស្តាយ ផលប៉ះពាល់ផ្លូវចិត្តនៃការទទួលបន្ទុកភាគច្រើននៃការងារថែទាំគ្មានប្រាក់កម្រៃ និងបន្ទុកសតិអារម្មណ៍មិនត្រូវបានកំណត់ត្រឹមស្ត្រីដែលមានវ័យចំណាស់នោះទេ ដោយសារតែស្ត្រីវ័យក្មេងម្នាក់បានឆ្លើយតបទៅនឹងទិន្នន័យដ៏គួរឱ្យព្រួយបារម្ភដូចខាងក្រោម៖ "... ផលប៉ះពាល់គឺការគេងមិនលក់ ហើយខ្ញុំមិនអាចញ៉ាំអ្វីបាន។ ខ្ញុំស្រកទម្ងន់ ហើយខ្ញុំជាញឹកញាប់មិនមានអារម្មណ៍ល្អទេ។ រឿងនេះកើតឡើងរាល់ពេលដែលខ្ញុំគិតច្រើន ហើយមិនបានគេងជាច្រើនថ្ងៃ" (ស្ត្រី Y៤)។

*"...នៅពេលដែលយើងមិនបានធ្វើតាមផែនការរបស់យើង យើង[នឹងមាន] អារម្មណ៍តានតឹង។*

*នៅពេលដែលបញ្ហាកើតឡើងបន្តបន្ទាប់គ្នា យើងត្រូវគិតពីដំណោះស្រាយ។*

*ហេតុដូច្នេះ ប្រភពសំខាន់នៃបន្ទុកសតិអារម្មណ៍ គឺកើតចេញពីការគិតរហូត។*

*ប្រសិនបើមានបញ្ហា យើងជាស្ត្រីត្រូវទទួលខុសត្រូវ ដូច្នេះ ហើយយើងមានការតានតឹង និងព្រួយបារម្ភច្រើន"*

(ស្ត្រី Y៥)។

# ផ្នែកទី ៤
# សេចក្តីសន្និដ្ឋាន

ផ្នែកនៃរបាយការណ៍នេះ បានកំណត់អំពី 'មូលដ្ឋាន' ទាក់ទងនឹងរបៀបដែលប្រជាជនកម្ពុជាយល់ឃើញពីការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃនាពេលបច្ចុប្បន្ន ទាំងនៅក្នុងសង្គមទូទៅ និងក្នុងគ្រួសាររបស់ពួកគេ។

ការសិក្សានេះបានរកឃើញថា ទោះបីជាគូស្វាមីភរិយាមួយចំនួន (ជាពិសេសដៃគូអ្នកស្រលាញ់ភេទដូចគ្នា) ចែករំលែកការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃស្មើៗគ្នាក៏ដោយ ក៏ដៃគូជាច្រើន (ជាពិសេសគូស្វាមីភរិយាស្រឡាញ់ភេទផ្ទុយគ្នា) បន្ទុកនេះត្រូវបានគេរាយការណ៍ថាបន្តធ្លាក់ចុះដោយមិនស្មើភាពគ្នាមកលើបន្ទុករបស់ស្ត្រី មិនថាពួកគាត់មានការងារធ្វើ ឬអត់នោះទេ។

លើសពីនេះ ការសិក្សានេះបានរកឃើញថា 'បន្ទុកផ្លូវចិត្ត' នៃការត្រូវចងចាំ ការកំណត់ពេល និងការរៀបចំកិច្ចការ ហើយសមាជិកគ្រួសារប្រើប្រាស់ពេលវេលា និងថាមពលតតឈប់ឈរ បន្ថែមភាពតានតឹងបន្ថែម ហើយត្រូវបានគេរាយការណ៍ថាស្ត្រីមានភាពតានតឹងច្រើនជាងបុរសផងដែរ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺថា ក្រាហ្វខាងក្រោមបង្ហាញថា បុរសយល់ឃើញថាគម្លាតការងារផ្ទះមានលក្ខណៈតូចចង្អៀតជាងស្ត្រី ដោយមានស្ត្រីចំនួន ៣៣.៣% រាយការណ៍ថាការងារផ្ទះមិនត្រូវបានចែករំលែកដោយស្មើភាពនោះទេ ខណៈដែលបុរសត្រឹមតែ ១១.៩% បានរាយការណ៍ដូចគ្នា។

ទោះបីជាមានការរកឃើញទាំងនេះក៏ដោយ ក៏មានរឿងពីរដែលគួរកត់សម្គាល់៖ ស្ត្រី និងបុរសមួយចំនួនដែលត្រូវបានសម្ភាសន៍មានអារម្មណ៍ថា ការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃនិងការបែងចែកបន្ទុកផ្លូវចិត្តនៅក្នុងផ្ទះរបស់ពួកគេ គឺស្មើគ្នា ឬស្ទើរតែស្មើគ្នា ហើយអ្នកខ្លះយល់ថាវាមិនស្មើគ្នា ប៉ុន្តែវាដំណើរការល្អសម្រាប់ពួកគេនៅក្នុងគ្រួសាររបស់ពួកគេផ្ទាល់ និងស្ថានភាពផ្ទាល់ខ្លួន។

របាយការណ៍នេះនឹងបង្វែរការត្រួតពិនិត្យលើស្ថានភាព 'អ្វីខ្លះ' (អ្វីដែលអ្នកចូលរួមយល់ឃើញថាកំពុងកើតឡើងទាក់ទងនឹងការងារថែទាំគ្មានប្រាក់កម្រៃ) ទៅពិនិត្យមើល 'មូលហេតុអ្វីខ្លះ' ដែលជម្រុញឲ្យស្ថានភាពនេបន្តកើតឡើង។

**គំនូសសម្គាល់ទី ៨៖ ក្នុងគ្រួសាររបស់អ្នក តើការងារផ្ទះត្រូវបានចែករំលែកដោយស្មើភាពក្នុងចំណោមសមាជិកគ្រួសារទេ?**



# ៤

# ការយល់ឃើញរបស់អ្នកចូលរួម អំពីកត្តាជម្រុញ និងបុព្វហេតុនៃការ បែងចែកការងារថែទាំគ្មានប្រាក់កម្រៃ

# ៥
# កត្តាជម្រុញ និងបុព្វហេតុ
## (ផ្អែកលើទស្សនៈអ្នកចូលរួម)

នៅក្នុងផ្នែកនេះ របាយការណ៍នឹងឈ្វេងយល់អំពីកត្តាមួយចំនួនដែលអ្នកចូលរួមយល់ថាបានជះឥទ្ធិពលទៅលើការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃនៅក្នុងគ្រួសារកម្ពុជាបច្ចុប្បន្ន។

របាយការណ៍ផ្នែកនេះ ចាប់ផ្តើមដោយធ្វើការត្រួតពិនិត្យទៅលើការយល់ឃើញ របស់អ្នកចូលរួម អំពីផលប៉ះពាល់ផ្នែកទំនៀមទំលាប់ វប្បធម៌ និងប្រវត្តិសាស្ត្រ រួមទាំង 'ក្រមប្រតិបត្តិ' សម្រាប់ស្ត្រី និងបុរស (ច្បាប់ស្រី និង ច្បាប់ប្រុស) ផងដែរ។

បន្ទាប់មក របាយការណ៍នេះនឹងត្រួតពិនិត្យមើលកត្តាសង្គមដែលបានជះឥទ្ធិពលទៅលើការបែងចែកបរិមាណនៃការងារថែទាំគ្មានប្រាក់កម្រៃនៅក្នុងចំណោមដៃគូស្និទ្ធស្នាលដែលមានភេទផ្ទុយគ្នា។ ចំណុចទាំងនេះរួមបញ្ចូលការយល់ឃើញរបស់សង្គមអំពីតួនាទីយេនឌ័រថាជាតួនាទីពីកំណើត និងការយល់ឃើញអំពីសមត្ថភាពរបស់បុរស និងស្ត្រីក្នុងការដឹកនាំ និងគ្រប់គ្រងការងារថែទាំគ្មានប្រាក់កម្រៃ។

ចំណុចទីបីគឺឈ្វេងយល់ និងវិភាគលើការយល់ឃើញអំពីផលប៉ះពាល់នៃការចិញ្ចឹមកូនប្រុសស្រីតាំងពីកុមារភាពជាមួយនឹងកម្រិតនៃទំនួលខុសត្រូវផ្សេងៗគ្នា។

ចំណុចចុងក្រោយផ្តោតលើការឈ្វេងយល់ដោយសង្ខេប លើសំណួរថាតើគូស្វាមីភរិយានៅទីក្រុងបានបែងចែកការងារថែទាំគ្មានប្រាក់កម្រៃខុសពីអ្នកជនបទដែរទេ រួមជាមួយនឹងការយល់ឃើញអំពីសក្តានុពលនៃ កត្តាវណ្ណៈសង្គម និងកម្រិតវប្បធម៌។

**កត្តាវប្បធម៌ និង ប្រវត្តិសាស្ត្រ**

**កត្តាសង្គម និង គោលនយោបាយ**

**កត្តាអន្តរជំនាន់**

**កត្តាភូមិសាស្ត្រ**

# ៥.១ កត្តា វប្បធម៌ និងប្រវត្តិសាស្ត្រ

*“ខ្ញុំគិតថា តាមទំនៀមទម្លាប់របស់យើង មានឃ្លាមួយដែលមានន័យត្រង់ថា ស្ត្រីមិនអាចដកខ្លួនចេញពីចង្ក្រានបាយទេ។*

*ចំណែកបុរសវិញ កាលពីមុន បុរសជាអ្នកចេញទៅរកប្រាក់នៅក្រៅផ្ទះ ចំណែកស្ត្រីគឺជាអ្នកនៅផ្ទះធ្វើកិច្ចការផ្ទះ។*

*ឥឡូវនេះភាគរយនៃផ្នត់គំនិតនេះនៅតែមានកម្រិតខ្ពស់ណាស់”*

(ស្ត្រីស្រលាញ់ភេទដូចគ្នា M៣)។

"ស្ត្រីបង្វិលចង្ក្រានមិនជុំ" និង "ស្ត្រីមុជមិនជ្រៅ ទៅមិនឆ្ងាយ" គឺជាសុភាសិតបែបប្រពៃណី និងប្រវត្តិសាស្ត្រចំនួនពីរដែលនៅតែមានឥទ្ធិពលនៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន។ សុភាសិតនីមួយៗបញ្ជាក់ពីកង្វះការផ្លាស់ប្តូរទាក់ទងនិងការកំណត់តួនាទីយេនឌ័ររបស់ស្ត្រីដែលមានតាំងពីបុរាណមក៖ ប្រសិនបើទីកន្លែងរបស់ស្ត្រីគឺស្ថិតនៅតែក្នុងចង្ក្រានបាយនោះ ទោះបីជាជីវភាពជីវិតរបស់ពួកគេមានភាពរីកចម្រើនដល់កម្រិតណាក៏ដោយ ក៏ចុងក្រោយ ពួកគេនៅតែធ្វើការងារនៅក្នុងចង្ក្រានបាយដដែល។

ពាក្យសុភាសិតទាំងនេះត្រូវបានលើកយកមកអប់រំមនុស្សជាបន្តបន្ទាប់ពីមួយជំនាន់ទៅមួយជំនាន់អស់រយៈកាលរាប់រយឆ្នាំមកហើយ ហើយក៏បានក្លាយជាឧបករណ៍អប់រំបែបប្រវត្តិសាស្ត្រ - ដែលស្របជាមួយនិងក្រមប្រតិបត្តិសម្រាប់ស្ត្រី ក្រមច្បាប់ស្រី - ដែលបានបង្រៀនក្មេងស្រី និងស្ត្រីពីទីកន្លែងរបស់ពួកគេនៅក្នុងសង្គម។ ក្រមច្បាប់ស្រី គឺជា "ពាក្យកាព្យ ដែលត្រូវបានផ្ទេរដោយផ្ទាល់មាត់បន្តពីជំនាន់មួយទៅជំនាន់មួយ តាំងពីសតវត្សទី ១៤ ដល់ទី ១៩ ហើយបន្ទាប់មក ត្រូវបានសរសេរជាលាយលក្ខណ៍អក្សរ" ហើយស្ត្រីដែលជាម្តាយតែងតែលើកយកមកធ្វើការណែនាំដល់កូនស្រីដែលទើបនឹងរៀបការ រួមទាំងការកំណត់តួនាទីដែលនាងគួរតែជាអ្នក "រក្សាសន្តិភាពក្នុងនៅផ្ទះ បង្ហាប់ឲ្យមានកាយវិការដំណើរ និងការនិយាយស្តីប្រកបដោយភាពទន់ភ្លន់ ហើយចេះស្តាប់បង្គាប់ និងគោរពប្តីរបស់នាង” [៤២]។

នៅក្នុងការពិភាក្សាអំពីកត្តារួមចំណែកដែលបណ្តាលឲ្យមានវិសមភាពនៃការបែងចែកបន្ទុកការងារថែទាំគ្មានប្រាក់កម្រៃទៅលើស្ត្រី អ្នកចូលរួមជាច្រើនបានឆ្លុះបញ្ចាំងអំពី ក្រមច្បាប់ស្រី និងការអប់រំបែបប្រពៃណីផ្សេងទៀតដែលមាននៅក្នុងអក្សរសាស្ត្រខ្មែរ និងការបង្រៀនបែបព្រះពុទ្ធសាសនា។ កេរ្តិ៍ដំណែលពិសេសមួយរបស់ក្រមច្បាប់ស្រី គឺថាក្រមច្បាប់នេះ ត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សាអប់រំក្មេងស្រី (ដែលទើបតែត្រូវបានដកចេញជាផ្លូវការពីកម្មវិធីសិក្សាថ្នាក់ជាតិក្នុងឆ្នាំ២០០៧)[៤៣] និងត្រូវបានមើលឃើញថា បានបង្កើតនូវផ្នត់គំនិតដែលបង្រៀនក្មេងស្រីចេះធ្វើនិងចេះគ្រប់គ្រងការងារថែទាំគ្មានប្រាក់កម្រៃខណៈដែលគ្មានការតម្រូវឲ្យបង្រៀនក្មេងប្រុសពីកិច្ចការទាំងអស់នោះ។

# កត្តាវប្បធម៌ និងប្រវត្តិសាស្ត្រ (ត)

ទិដ្ឋភាពនេះ និងទិដ្ឋភាពផ្សេងទៀតនៃកត្តាវប្បធម៌ និងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាត្រូវបានលើកឡើងយ៉ាងលម្អិតដោយអ្នកចូលរួមម្នាក់៖ “មូលហេតុដំបូង [សម្រាប់ការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃមិនស្មើភាពគ្នា] គឺការអប់រំ។ ឧទាហរណ៍ នៅក្នុងសម័យកាលស្ថិតក្រោមរបបអាណានិគមនិយមបារាំង មានតែ ក្មេងប្រុសប៉ុណ្ណោះដែលអាចទៅវត្តដើម្បីរៀនសូត្រ ចំណែកក្មេងស្រីត្រូវនៅផ្ទះ។ នេះហើយជាមូលហេតុដែលប្រជាពលរដ្ឋទូទៅនៅតែប្រកាន់ទស្សនៈថា បុរសមានការអប់រំច្រើនជាងស្ត្រី ដូច្នេះហើយទើបបុរសអាចបំពេញតួនាទីរកប្រាក់កម្រៃបាន។ យើងក៏អាចឃើញឧទាហរណ៍មួយផ្សេងទៀតនៅក្នុងព្រះពុទ្ធសាសនា ដែលជាសាសនាជាតិរបស់យើងផងដែរ៖ ជាធម្មតាព្រះសង្ឃត្រូវបានមើលថៃដោយស្ត្រី មិនថាព្រះសង្ឃមានព្រះជន្មប៉ុន្មាននោះទេ ហើយនៅកម្ពុជាមិនមានវត្តមានភិក្ខុនីទេ” (បុរស C២)។

គួរកត់សម្គាល់ផងដែរថា ឥទ្ធិពលនៃអត្ថបទស្រដៀងគ្នាឬ 'សៀវភៅណែនាំស្ដីពីក្រមប្រតិបត្តិ'[៤] អាចរកបានដោយងាយស្រួលនៅក្នុងបរិបទលោកខាងលិច (ជាពិសេសក្នុងអំឡុងសតវត្សទី ១៨ និង ១៩) ក៏ដូចជានៅក្នុងតំបន់ផ្សេងទៀតនៃពិភពលោក។ ទោះជាយ៉ាងនេះក្ដី ប្រេវ៉ាឡង់នៃការឆ្លើយតបរបស់អ្នកចូលរួមផ្ដោតលើការបង្រៀនផ្នែកវប្បធម៌ សាសនា និងប្រវត្តិសាស្ត្រ ដែលមានលក្ខណៈជាក់លាក់ចំពោះបរិបទខ្មែរ ដែលបញ្ជាក់ថាកត្តាទាំងនេះគួរតែត្រូវបានលើកយកមកធ្វើការរពិចារណាថាជាកត្តាជម្រុញនាំឲ្យមានវិសមភាពនៅក្នុងការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។

បន្ថែមលើនេះ អ្នកចូលរួមដដែលក៏បានបន្តធ្វើការឆ្លុះបញ្ចាំងឱ្យឃើញថា៖ “អក្សរសិល្ប៍ខ្លះនៅក្នុងប្រព័ន្ធអប់រំរបស់យើងក៏បង្កប់នូវផ្នត់គំនិតបែបនេះដែរ។ ឧទាហរណ៍មួយគឺថា នៅក្នុងរឿង “រាមកេរ្តិ៍” ជារឿងដែលនិទានអំពីស្ត្រីម្នាក់ដែលមិនអាចគេចផុតពីការគ្រប់គ្រងរបស់ព្រះរាជាម្នាក់ជាបុរស" (បុរស C២)។

*“ខ្ញុំគិតថា [វិសមភាពនៃការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃ] អាចត្រូវបានផ្សារភ្ជាប់ទៅនឹងវប្បធម៌ខ្មែរវិញ។*

*តាំងពីបុរាណកាលរហូតមកទល់បច្ចុប្បន្ន មានការកំណត់និយមន័យថា ការងារផ្ទះជាការងាររបស់ស្ត្រី។*

*ប៉ុន្តែបច្ចុប្បន្ននេះ បុរសក៏អាចធ្វើការងារទាំងនោះបានដែរ។ ប៉ុន្តែបុរសភាគតិចប៉ុណ្ណោះដែលបានធ្វើការងារនេះ”*

(ស្ត្រី Y១២)។

[៤] សូមមើលឧទាហរណ៍ សុន្ទរកថាដ៏ពេញនិយមរបស់ Fordyce ឆ្នាំ ១៧៦៦ ព្រះបន្ទូលសម្រាប់ស្ត្រី ដែលស្ត្រីអង់គ្លេសត្រូវបានណែនាំអោយមានទំនួលខុសត្រូវ ស្តាប់បង្គាប់ មានអាកប្បកិរិយាសុភាពរាបសារ និងស្លៀកពាក់សមរម្យ៖ "ភាពស្លូតបូត ដែលផ្អែកលើគោលការណ៍ជាគ្រិស្តបរិស័ទគឺជា... ឧត្តមភាពខ្ពស់បំផុតរបស់ស្ត្រី"។ ទន្ទឹមនោះ Fordyce បានណែនាំថាស្ត្រី គួរតែបង្កើតភាពលេញធ្លោរនិងទាក់ទាញតាមដែលអាចធ្វើទៅបាន ព្រោះភាពស្រស់ស្អាតគឺជាអំណោយពីព្រះជាម្ចាស់ [៤៤] ។

# ៥.២ កត្តា សង្គម

## ៥.២.១ ការយល់ឃើញអំពីតួនាទីយេនឌ័រជាតួនាទី 'ពីកំណើត'

ផ្នែកនេះពិភាក្សាអំពីគំនិតដែលបានរាយការណ៍ដោយអ្នកចូលរួមមួយចំនួន ដែលថាស្ត្រីមានភាពប៉ិនប្រសប់ពីកំណើត និងចង់ធ្វើការងារថែទាំគ្មានប្រាក់កម្រៃ។ ការអះអាងបែបនេះ ដោយសារតែជាទូទៅគេឃើញថាស្ត្រីមានសន្តានចិត្តគិតគូរ និងយកចិត្តទុកដាក់ចំពោះសុខុមាលភាពគ្រួសារច្រើនជាងបុរស ដូច្នេះហើយទើបស្ត្រីហាក់ព្រមទទួលយកភារៈកិច្ចជាអ្នកបំពេញការងារថែទាំគ្មានប្រាក់កម្រៃ។

អ្នកចូលរួមបានឆ្លុះបញ្ចាំងឱ្យឃើញអំពីគំនិតនេះតាមរយៈការចែករំលែកទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេថា ស្ត្រីគឺត្រូវបានកំណត់តាម "លក្ខណៈធម្មជាតិ" ឱ្យទទួលយកការងារថែទាំគ្មានប្រាក់កម្រៃ ឬ អ្នកចូលរួមជាច្រើនបានអះអាងថាផ្នត់គំនិតបែបនេះបានចាក់ឫសគល់យ៉ាងទូលំទូលាយនៅក្នុងសង្គម (ទោះបីជាអ្នកចូលរួមមួយចំនួនបានអះអាងថា ការលើកឡើងបែបនេះគឺមិនស្របតាមទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេក៏ដោយ)។ ដូចដែលបាន ពិភាក្សាដោយបណ្ឌិតសភា Brickell [៤៥] ស្ត្រីខ្មែរត្រូវទទួលបន្ទុកថែរក្សាភាពសុខដុមរមនា និងសុភមង្គលនៅក្នុងគ្រួសារ។ លើសពីនេះ អ្នកចូលរួមឆ្លើយតបទាំងពីរភេទ បានបង្ហាញការយល់ឃើញជារួមថា ជាទូទៅស្ត្រីត្រូវបានមើលឃើញថាជាអ្នកដែលមាន "ការយកចិត្តទុកដាក់" ច្រើនជាងបុរស។ ក្នុងន័យនេះ 'ការយកចិត្តទុកដាក់' គឺសំដៅដល់ការ 'គិតគូរអំពីគ្រួសារច្រើន'។ ផ្ទុយទៅវិញ អ្នកចូលរួមក៏បានលើកឡើងដោយប្រយោលអំពីការដែលបុរសហាក់មិនសូវបង្ហាញការយកចិត្តទុកដាក់ចំពោះគ្រួសារផងដែរ ... " (ទំព័រ ១៣៦៣)។

ការឆ្លើយតបរបស់អ្នកចូលរួមជាច្រើនបានបង្ហាញជំហរឯកភាពលើទស្សនៈនៃការរក្សាភាពសុខដុមរមនា និងសុភមង្គលនៅក្នុងគ្រួសារ តាមរយៈការអនុវត្តការងារថែទាំគ្មានប្រាក់កម្រៃសម្រាប់សមាជិកគ្រួសារ ដូចដែលស្ត្រីវ័យចំណាស់ម្នាក់បានផ្តល់សក្ខីកម្មខាងក្រោមនេះ៖

"ខ្ញុំសប្បាយចិត្តនឹងធ្វើកិច្ចការផ្ទះនោះ។ ខ្ញុំធ្វើរាល់ថ្ងៃ ហើយខ្ញុំសប្បាយចិត្តនឹងការងារនោះ ព្រោះខ្ញុំចេះធ្វើម្ហូបសម្រាប់គ្រួសារខ្ញុំ។ ខ្ញុំសប្បាយចិត្តពេលឃើញគ្រួសារខ្ញុំចូលចិត្តម្ហូបរបស់ខ្ញុំ" (ស្ត្រី ០៧)។ ប្រការនេះបង្ហាញឱ្យឃើញអំពីសារៈសំខាន់នៃការទទួលស្គាល់ភាពរីករាយ និងមោទនភាពដែលស្ត្រីជាច្រើនមាននៅពេលចម្អិនម្ហូបអាហារ និងបំពេញការងារថែទាំផ្សេងទៀតសម្រាប់មនុស្សជាទីស្រឡាញ់របស់ពួកគាត់។

# ការយល់ឃើញអំពីតួនាទីយេនឌ័រជាតួនាទី 'ពីកំណើត' (ត)

*"...មនុស្សប្រុសមិនពូកែមើលថែកូនទេ ពួកគេឆាប់ខឹង មិនចេះលួងលោម [កូនៗ]។ ភាគច្រើនពួកគេប្រើកំហឹង... មិនចេះប្រើពាក្យសម្ដីធ្វើឱ្យកូនស្ងប់ចិត្តដូចម្ដាយនោះទេ។ ខ្ញុំគិតថាបុរស គឺកាចជាងយើង។ ស្ត្រីអាចគ្រប់គ្រងអារម្មណ៍របស់ពួកគេបានច្រើនជាងបុរស" (ស្ត្រី Y៩)។*

ទោះជាយ៉ាងណាក្តី ទិន្នន័យផ្សេងទៀតបានចង្អុលបង្ហាញស្ថានភាពដ៏ស្មុគស្មាញ ពាក់ព័ន្ធនិងការងារថែទាំគ្មានប្រាក់កម្រៃ និងតម្រូវឱ្យមានការឈ្វេងយល់បែបស៊ីជម្រៅបន្ថែមទៀត។ ឧទាហរណ៍ យុវតីម្នាក់ថ្លែងថា៖ "ក្នុងនាមជាស្ត្រី ពេលខ្លះយើងមិនចង់ញ៉ាំ [អាហារជាក់លាក់មួយ] ប៉ុន្តែស្វាមីចង់ញ៉ាំ ដូច្នេះយើងត្រូវតែចម្អិនម្ហូបនោះដើម្បីឱ្យគាត់សប្បាយចិត្ត" (ស្ត្រី Y៣)។ គួរកត់សម្គាល់ថា អ្នកចូលរួមរូបនេះ ក៏បានសង្កត់ធ្ងន់លើស្វ័យភាពនៅក្នុងការបំពេញការងារថែទាំគ្មានប្រាក់កម្រៃថា "យើងចង់ធ្វើម្ហូបនោះឱ្យប្តី ទោះបីជាយើងមិនចង់ញ៉ាំក៏ដោយ... យើងចាំបាច់ត្រូវចម្អិនម្ហូបនោះ ខ្ញុំ និងអ្នកដទៃដែលគិតដូចគ្នា" (Y៣)។ ទោះយ៉ាងណាក៏ដោយ ស្វ័យភាពនេះហាក់ទទួលរងផលប៉ះពាល់ខ្លះៗដែរ ជាក់ស្តែងដូចដែលនាងបន្តថា "ប្រសិនបើយើងប្រើពេលវេលាសម្រាប់គោលបំណងផ្ទាល់ខ្លួនយើងខ្លាចថាគាត់នឹងខឹងជាមួយយើង។"

ទោះបីជាការលើកឡើងនេះ អាចត្រូវបានបកស្រាយតាមការយល់ឃើញរៀងខ្លួនក៏ដោយ ផ្អែកលើសក្ខីកម្មរបស់នាង គេអាចចោទជាសំណួរអំពីមូលហេតុដែលជម្រុញទឹកចិត្តស្ត្រី ក្នុងការបំពេញការងារដ៏សំខាន់ និងគ្មានប្រាក់កម្រៃជាប្រចាំថ្ងៃសម្រាប់ដៃគូស្និទ្ធស្នាលរបស់ពួកគេ៖ នៅក្នុងបរិបទដែលអត្រានៃអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាលមានការកើនឡើងយ៉ាងខ្ពស់ [៤៦] អាចនឹងមានការបង្ខិតបង្ខំជាក់ស្តែង ឬការយល់ឃើញថាជាការបង្ខិតបង្ខំនៅក្នុងកម្រិតណាមួយ។ ជាលទ្ធផល ចំណុចនេះចោទជាសំណួរថា តើកម្រិតនៃការរក្សាតម្លៃខ្លួនឯងខ្លះអាចដើរតួនាទីសំខាន់នៅក្នុងការបំពេញការងារនេះដែរទេ។ បុរសវ័យចំណាស់ម្នាក់បានពោលថា៖ "... នៅក្នុងសហគមន៍របស់ខ្ញុំ នៅពេលដែលប្រពន្ធមិនធ្វើកិច្ចការផ្ទះដើម្បីបំពេញតាមការរំពឹងទុករបស់គ្រួសារ គាត់នឹងទទួលរងអំពើហិង្សាក្នុងគ្រួសារពីសំណាក់ដៃគូរបស់គាត់" (បុរស OFGD)។

*"[វិសមភាពនៃការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃ] មានឥទ្ធិពលយ៉ាងខ្លាំងទៅលើសុខភាពផ្លូវចិត្តរបស់ស្ត្រី។ ស្ត្រីមួយចំនួនមិនយកបញ្ហានេះមកពិភាក្សាទេ ពួកគាត់នៅតែបន្តធ្វើវាតែម្នាក់ឯងព្រោះពួកគាត់ខ្លាចថាការលើកឡើងអំពីបញ្ហានឹងនាំឱ្យមានជម្លោះក្នុងគ្រួសារ។*

*ស្ត្រីមួយចំនួនទាមទារសិទ្ធិស្មើគ្នា [ហើយនៅពេលដែលពួកគេ] យកបញ្ហានេះមកពិភាក្សានោះនឹងមានជម្លោះក្នុងគ្រួសារ ជួនកាលអាចឈានទៅដល់ការបែកបាក់គ្រួសារទៀតផង។*

*ស្ត្រីមួយចំនួនមិនហ៊ានលើកឡើងទេ ព្រោះខ្លាចបែកបាក់គ្រួសារ។ នេះហើយ ជាហេតុផលនៅពីក្រោយការតស៊ូរបស់ស្ត្រី”*

(ស្ត្រី C១)។

# ការយល់ឃើញអំពីសមត្ថភាពរបស់ស្ត្រី (ប៉ិនប្រសប់ក្នុងការបំពេញការងារថែទាំគ្មានប្រាក់កម្រៃ?)

*ទោះបីជាអ្នកចូលរួមមួយចំនួនបានឆ្លុះបញ្ចាំងថាស្ត្រីអាចអនុវត្តកម្រិតមិនសមាមាត្រនៃការងារថែទាំគ្មានប្រាក់កម្រៃ ដោយសារតែពួកគេមានការយកចិត្តទុកដាក់ ឬចិញ្ចឹមបីបាច់ពីកំណើតច្រើនជាងក៏ដោយ ក៏អ្នកផ្សេងទៀតបានចែករំលែកទស្សនៈខុសគ្នាបន្តិច។ គំនិតដែលថាស្ត្រីគឺគ្រាន់តែ 'ល្អប្រសើរជាង' ក្នុងការធ្វើការងារផ្ទះ គឺមានការកើនឡើងពេញទិន្នន័យក្នុងចំណោមក្រុមអាយុទាំងពីរនៃអ្នកចូលរួមជាបុរស និងស្ត្រីស្រឡាញ់ភេទផ្ទុយគ្នា៖ "...ស្ត្រីពូកែធ្វើការងារផ្ទះ... ដូច្នេះពួកគេត្រូវតែធ្វើការងារផ្ទះ។ មូលហេតុ គឺដោយសារតែពួកគេពូកែរៀបចំផ្ទះ" (បុរស Y៤)។*

ចំណុចនេះទំនងជាសំដៅដល់ដំណើរការនៃការបន្តវេនធ្វើកិច្ចការថែទាំគ្មានប្រាក់កម្រៃនៅក្នុងគ្រួសារពីមួយជំនានទៅមួយជំនាន់ទៀត ដែលស្ត្រីបានតម្រូវឲ្យទទួលយកតួនាទី និងបង្ហាញអាកប្បកិរិយាជាក់លាក់មួយ [៤៧]។ សញ្ញាណទ្រឹស្តីដែលអះអាងថា ស្ត្រីមាន "ភាពប៉ិនប្រសប់ជាង" តាំងពីកំណើតលើការងារថែទាំគ្មានប្រាក់កម្រៃ ក៏បានពង្រីកវិសាលភាពនៃបន្ទុកផ្លូវចិត្តផងដែរ ដែលតែងតែមានការលើកឡើងស្ត្រីពូកែចងចាំព្រឹត្តិការណ៍ និងកាលបរិច្ឆេទជាក់លាក់។ អ្នកចូលរួមជាបុរសមួយចំនួនបានអះអាងថា នេះគឺជាចរិតលក្ខណៈ និងជំនាញរបស់ភរិយាខ្លួនដែលមានទំនោរចង់គ្រប់គ្រងគ្រួសារ៖ "ប្រសិនបើយើងប្រើពាក្យ "គ្រប់គ្រង" ប្រពន្ធរបស់ខ្ញុំគឺជាអ្នកគ្រប់គ្រងគ្រួសារ។ គាត់ពូកែចងចាំកាលបរិច្ឆេទ ដូចជាថ្ងៃបុណ្យ ឬការប្រារព្ធពិធីណាមួយ" (បុរស C៥)។

ទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលអ្នកចូលរួមមួយរូបទៀតបានបន្ទឹទ្បើងនូវមនោសញ្ចេតនានេះ ដោយប្រើឃ្លាខុសគ្នាបន្តិចបន្តួច វាអាចបង្ហាញពីការយល់ឃើញជាមូលដ្ឋាននៅពីក្រោយហេតុផលដែលថា ស្ត្រីហាក់ដូចជា "ពូកែណាស់" ក្នុងការចងចាំ និងរៀបចំសកម្មភាពគ្រួសារ៖ "ការហូបចុក ការណាត់ជួប ការគេងមួយយប់ ថ្ងៃកំណើត និងអ្វីៗផ្សេងទៀតគឺជាកិច្ចការរបស់ស្ត្រី ដូច្នេះនាងអាចគ្រប់គ្រងកិច្ចការទាំងនោះបាន" (បុរស O១)។ ភាពតានតឹងរវាងគំនិតនៃជម្រើសសេរី ជំនាញ បុគ្គលិកលក្ខណៈ និងតួនាទីដែលត្រូវបានចាត់តាំង គឺមានភាពស្មុគ្រស្មាញ និងបត់បែនយ៉ាងជ្រាលជ្រៅ ដូច្នេះគួរតែមានការស្រាវជ្រាវបន្ថែមទៀតដើម្បីឈ្វេងយល់អំពីភាពប្រសព្វគ្នានេះឱ្យបានស៊ីជម្រៅជាងរបកគំហើញដែលបានរាយការណ៍នៅក្នុងរបាយការណ៍នេះ។

*"[...] ប្រសិនបើយើងប្រៀបធៀបចរិតលក្ខណៈមនុស្សរវាងស្ត្រី និងបុរស ស្ត្រីមានចរិតលក្ខណៈប៉ិនប្រសប់ពីធម្មជាតិ... មានន័យថា នៅពេលដែលនាងត្រូវបានចាត់តាំងឱ្យធ្វើការងារផ្ទះ នាងនឹងធ្វើការងារនោះបានល្អជាងបុរស។*

*ឧទាហរណ៍ ក្នុងការចម្អិនអាហារ... បុរសក៏អាចធ្វើម្ហូបឆ្ងាញ់ៗបានដែរ ប៉ុន្តែស្ត្រីចេះគ្រប់គ្រងរបស់របរ ទៅផ្សារ ទិញបន្លែ ឬរបស់របរផ្សេងៗពាក់ព័ន្ធនឹងការចម្អិនអាហារ។ នាងចេះសម្អាតយ៉ាងស្អាត...រៀបរយ... ល្អជាងមនុស្សប្រុស ប៉ុន្តែសម្រាប់មនុស្សប្រុសវិញ គាត់មិនចេះធ្វើរឿងតូចតាចទាំងនេះឡើយ"*

(ស្ត្រី Y១)។

# ការយល់ឃើញអំពីសមត្ថភាពរបស់ស្ត្រី (នៅមានកម្រិត ឬយ៉ាងណា?)

ជ្រុងម្ខាងទៀតនៃការយល់ឃើញដែលថាស្ត្រីមានភាពប៉ិនប្រសប់ជាងតាំងពីកំណើតទៅលើការងារថែទាំគ្មានប្រាក់កម្រៃគឺថា សមត្ថភាពរបស់ពួកគេក្នុងការបំពេញការងារផ្សេងៗទៀតគឺនៅមានកម្រិត។ ការយល់ឃើញនេះគឺមានការកើនឡើងនៅក្នុងក្រុមអាយុទាំងពីរនៃអ្នកចូលរួមជាបុរស និងស្ត្រី។ ដូចដែលបានលើកឡើងដោយអ្នកចូលរួមជាយុវតីម្នាក់ "[...] ស្ត្រីខ្លះការអប់រំ ឬឋានៈខ្ពស់... ដូច្នេះអ្វីដែលពួកគេអាចធ្វើបានគឺនៅផ្ទះ ធ្វើការងារផ្ទះ និងមើលថែកូន" (ស្ត្រី Y២)។

អ្នកចូលរួមជាស្ត្រីផ្សេងទៀតក៏បានចង្អុលបង្ហាញអំពីកម្លាំងរាងកាយរបស់ស្ត្រីដោយពោលថា "ការងារខ្លះត្រូវការកម្លាំងពលកម្មច្រើន ស្ត្រីមិនអាចលើករបស់ធ្ងន់ៗបានទេ... ឬស៊ូទ្រាំនឹងការងារធ្ងន់ ហើយបុរសគឺខ្លាំងជាង" (YSW ៩)។ ជាការពិតណាស់ ក្នុងកំឡុងពេលសម្ភាសន៍ ការយល់ឃើញដែលថាសមត្ថភាពរបស់ស្ត្រីនៅមានកម្រិត លើសពីការងារផ្ទះ គឺផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងទស្សនៈថា ស្ត្រីគឺទន់ខ្សោយ។ ដូចដែលអ្នកចូលរួមម្នាក់បាននិយាយថា៖

*"...មនុស្សមួយចំនួនជឿថា... ស្ត្រីគឺទន់ខ្សោយ - ពួកគេមិនអាចធ្វើការងារអ្វីបានក្រៅពីនៅផ្ទះ លាងចាន ធ្វើម្ហូប និងមើលថែទាំកូននោះទេ។ ប្រការនេះបណ្ដាលឱ្យមានសម្ពាធរវាងបុរស និងស្ត្រី ដោយសារតែការធ្វើការនៅក្នុងផ្ទះ គឺសម្រាប់ស្ត្រី ហើយការងារក្រៅផ្ទះគឺសម្រាប់បុរស។ កត្តានេះ គឺដោយសារតែពួកគេគិតថាយើងមិនអាចធ្វើអ្វីផ្សេងបានក្រៅពីមើលថែកូន ឬចម្អិនអាហារ សម្អាត និងបោសជូតផ្ទះ"* (ស្ត្រី O៣)។

ការសម្ភាសន៍ក៏បង្ហាញឱ្យឃើញផងដែរអំពីការយល់ឃើញក្នុងចំណោមអ្នកចូលរួមមួយចំនួនថា សមត្ថភាពស្ត្រីនៅមានកម្រិត និងមិនអាចធ្វើកិច្ចអ្វីក្រៅពីការងារផ្ទះ គឺទាក់ទងយ៉ាងខ្លាំងទៅនឹងការទទួលបានការអប់រំរបស់ពួកគេ។ អ្នកចូលរួមជាបុរសវ័យក្មេងម្នាក់បាននិយាយថា "ស្ត្រី [ធ្វើការងារថែទាំគ្មានប្រាក់កម្រៃ] ដោយសារតែពួកគេមិនមានការអប់រំល្អ ហើយពួកគេគ្មានឱកាសដើម្បីអភិវឌ្ឍខ្លួនឯង... " (បុរស Y៦)។ ទោះជាយ៉ាងណាក៏ដោយ អ្នកចូលរួមជាបុរសវ័យចំណាស់ម្នាក់បាននិយាយថា "នៅពេលដែលយើងបង្រៀន [តែស្រីៗ] ឱ្យចេះលាងចាន និងសម្អាតផ្ទះសម្បែង ពួកគេនឹងមិនអាចគេចផុតពីការងារទាំងនេះបានឡើយ។ ពួកគេនឹងគិតថា ទោះបីជាពួកគេបន្តការសិក្សាដល់កម្រិតណាក៏ដោយ ក៏នៅតែជាស្ត្រីដដែល ហើយត្រូវតែក្លាយជាស្ត្រីមេផ្ទះសម្រាប់កូនរបស់ពួកគេ" (បុរស O២)។

នៅពេញមួយរយៈពេលពិភាក្សា យើងអាចមើលឃើញថា អ្នកចូលរួមសម្ភាសន៍ជាច្រើនបានរាយការណ៍ពីការយល់ឃើញរបស់សង្គមថាសមត្ថភាពស្ត្រីនៅមានកម្រិតនិងមិនអាចធ្វើកិច្ចការអ្វីក្រៅពីការងារផ្ទះ។ ចំពោះសំណួរអំពីការទទួលបានការអប់រំមានឥទ្ធិពលលើលទ្ធផលសម្រាប់ស្ត្រី ក្នុងន័យនេះ អ្នកខ្លះបានរាយការណ៍អំពីការយល់ឃើញថា ការទទួលបានការអប់រំខ្ពស់នឹងនាំឱ្យមានការបែងចែកការងារផ្ទះស្មើភាពគ្នា ខណៈពេលដែលអ្នកផ្សេងទៀតបានអះអាងថា ការអប់រំឧត្តមសិក្សាមិនផ្លាស់ប្តូរអ្វីនោះទេ ដោយសារផ្នត់គំនិតត្រូវបានបណ្ដុះរួចហើយ ទៅតាមជំនាន់នីមួយៗតាំងពីកុមារភាពមកម្ល៉េះ។

## ការយល់ឃើញអំពីសមត្ថភាពរបស់បុរស (មិនសូវមានសមត្ថភាពលើការងារថៃទាំគ្មានប្រាក់កម្រៃ?)

*“ទេ ខ្ញុំមិនដឹងពីរបៀប [ធ្វើការងារផ្ទះ] ដោយគ្មានជំនួយពីប្រពន្ធរបស់ខ្ញុំទេ។ ខ្ញុំមិនចេះស្ទាត់ដូចស្ត្រីទេ” (បុរស ០១)។*

ទោះបីជាអ្នកចូលរួមបានរាយការណ៍ថា ស្ត្រីត្រូវបានគេមើលឃើញនៅក្នុងសង្គមថា "ប៉ិនប្រសប់ជាង" លើការងារផ្ទះក៏ដោយ ក៏ផ្ទុយមកវិញ បុរសត្រូវបានគេរាយការណ៍នៅក្នុងសង្គមថាមិនសូវមានសមត្ថភាព និងមិនសូវមានទំនុកចិត្តនៅពេលធ្វើការងារថៃទាំគ្មានប្រាក់កម្រៃណាមួយ។

អ្នកចូលរួមជាបុរសខ្លះ បានរាយការណ៍ថាពួកគេអាចធ្វើការងារថៃទាំគ្មានប្រាក់កម្រៃបាន ប៉ុន្តែ 'មិនល្អ' ដូចស្ត្រីឡើយ។ ដូចដែលបានលើកឡើងដោយអ្នកចូលរួមម្នាក់នៃក្រុមគោលដៅបុរស "ទោះបីជាយើងអាចធ្វើការងារ [ផ្ទះ] ទាំងអស់បានក៏ដោយ ក៏យើងមិនអាចធ្វើការងារផ្ទះបាន ១០០% ដែរ ដូចជាការមើលថៃទាំកូនជាដើម" (ការពិភាក្សាក្រុមគោលដៅបុរស)។ បុរសម្នាក់បានរាយការណ៍ពីការយល់ឃើញអំពីហេតុផលនៃកង្វះសមត្ថភាពរបស់បុរសក្នុងការបំពេញការងារថៃទាំគ្មានប្រាក់កម្រៃគឺជាកង្វះបទពិសោធន៍ និងការចូលរួមពីមុនរបស់ពួកគេក្នុងការអនុវត្ត។ យុវជនម្នាក់ដែលចូលរួមបាននិយាយថា៖

*“ខ្ញុំគិតថា ស្ត្រីគឺជាអ្នកដែលធ្វើការងារ [ការងារថៃទាំគ្មានប្រាក់កម្រៃ] ព្រោះពួកគេចេះបែងចែកកិច្ចការយ៉ាងមានប្រសិទ្ធភាព ហើយនាងក៏ពូកែខាងនោះដែរ។ ប្រសិនបើបុរសធ្វើការងារនោះ គាត់មិនដឹងថាត្រូវចាប់ផ្តើមពីណាទេ ព្រោះគាត់មិនដែលធ្វើការងារនោះពីមុនមកសោះ” (បុរស Y៦) ។*

ស្រដៀងគ្នានេះដែរ អ្នកចូលរួមជាស្ត្រីមួយចំនួនក៏បានរាយការណ៍អំពីការយល់ឃើញដូចគ្នា ដោយជឿថាសមត្ថភាពបុរសនៅមានកម្រិតចំពោះការងារផ្ទះ។ នៅពេលសួរថា តើនាងគិតថាដៃគូរបស់នាងមានសមត្ថភាពធ្វើកិច្ចការផ្ទះដោយខ្លួនឯង ឬអត់នោះ អ្នកចូលរួមជាស្ត្រីវ័យចំណាស់ម្នាក់បានឆ្លើយថា “ទេ។ បើខ្ញុំមិនធ្វើកិច្ចការផ្ទះទេ គ្រួសារនេះនឹងច្របូកច្របល់ដោយសារប្តីរបស់ខ្ញុំមិនដឹងពីរបៀបទិញរបស់របរនៅឯផ្សារនោះទេ” (OSW ៧)។

# ការយល់ឃើញអំពីភាពសមស្របរបស់បុរសដែលបំពេញការងារថៃទាំគ្មានប្រាក់កម្រៃ

**គំនូសសម្គាល់ទី ៩៖ តើមនុស្សគិតយ៉ាងណានៅពេលដែលឃើញបុរសធ្វើការងារផ្ទះ?**




ទស្សនៈមួយទៀតដែលកើតចេញពីទិន្នន័យទាំងគុណវិស័យ និងបរិមាណវិស័យ គឺការយល់ឃើញរបស់សង្គមដែលថាបុរសអនុវត្តការងារថៃទាំគ្មានប្រាក់កម្រៃគឺខុសពីធម្មតា៖ ជាការពិត មានតែ ១០.៤% នៃអ្នកឆ្លើយតបការស្ទង់មតិប៉ុណ្ណោះដែលបង្ហាញថាបុរសធ្វើការងារផ្ទះត្រូវបានគេមើលឃើញថាជារឿងធម្មតា ឬមិនគួរឱ្យកត់សម្គាល់។ ក្រៅពីនោះ អ្នកចូលរួមជាច្រើន (៦៦.៤%) មានអារម្មណ៍ថាបុរសដែលធ្វើការងារផ្ទះត្រូវបានគេកោតសរសើរថាជាដៃគូដ៏ល្អ៖ អ្នកចូលរួមសម្ភាសន៍ម្នាក់ (បុរស C៣) បានលើកឡើងពីនិទ្នាការបុរសខ្មែរដែលបង្ហោះលើហ្វេសប៊ុកនៅពេលពួកគេបំពេញការងារផ្ទះ ដើម្បីព្យាយាមប្រមូល អ្នកចូលចិត្ត និងការសរសើរ។

ទោះជាយ៉ាងនេះក្តី ស្ទើរតែមួយភាគបួន (២៣.២%) នៃអ្នកចូលរួមបានរាយការណ៍ថាបុរសបែបនេះអាចត្រូវបានសើចចំអកដោយអ្នកដ៏ទៃថាកំពុងតែធ្វើចរិកដូចស្ត្រី ឬធ្វើការងារផ្ទះ ដោយសារតែត្រូវបានប្រពន្ធគ្រប់គ្រង។ ការយល់ឃើញនេះអាចឆ្លុះបញ្ចាំងពីបទដ្ឋានសង្គមដែលផ្តល់តម្លៃដល់ការបង្ហាញភាពជាបុរសបែបប្រពៃណី ដែលបុរសបង្ហាញលក្ខណៈដូចជា អំណាច កម្លាំង សទិទានភាព ការទាក់ទាញភេទផ្ទុយគ្នា ហ៊ានប្រថុយប្រថាន ការត្រួតត្រា ភាពជាអ្នកដឹកនាំ ការគ្រប់គ្រង និងការទប់អារម្មណ៍ ត្រូវបានចាត់ទុកថាជាបុរស ឬសញ្ញាណនៃបុរសពិត [៤២] ។ អ្នកចូលរួមបានលើកឡើងអំពីផលវិបាកផ្នែកសង្គម ចំពោះបុរសដែលបានដើរចេញពីព្រំដែននៃការកំណត់ភាពជាបុរសដ៏តឹងរ៉ឹងទាំងនេះ និងបានទទួលយកការងារថៃទាំគ្មានប្រាក់កម្រៃ ដូចជា ការនិយាយដើម ការបង្អាប់ និងត្រូវបានគេចាត់ទុកថាមានសូវមានតម្លៃ៖ “បទពិសោធន៍របស់ខ្ញុំគឺថា នៅពេលដែលអ្នកជិតខាងរបស់ខ្ញុំឃើញខ្ញុំហាលខោអាវជាញឹកញាប់ ពួកគេមើលងាយខ្ញុំ ហើយខ្ញុំអាចមានអារម្មណ៍ដឹង” (បុរស Y៥)។

សម្ពាធនេះត្រូវបានគេនិយាយថាដំណើរការជាប្រព័ន្ធដែលបុរសជាច្រើននឹងឈប់ធ្វើការងារផ្ទះដោយសារពួកគេមានអារម្មណ៍ភ័យព្រួយចំពោះការវិនិច្ឆ័យពីសាច់ញាតិ និងអ្នកជិតខាង។

*"ប្រសិនបើបុរសជួយការងារស្ត្រី ពួកគេនឹងត្រូវបានគេមើលងាយ ដូចជាត្រូវបានគេមើលឃើញថាទន់ជ្រាយ ឬដូចស្រី។*

*ឧទាហរណ៍ មនុស្សអាចនិយាយថា "ហេតុអ្វីបានជាអ្នកមិនព្យាយាមរកប្រាក់ឱ្យច្រើនជំនួសឱ្យការជួយប្រពន្ធរបស់អ្នក អ្នកពិតជាទន់ខ្សោយណាស់"*

(ស្ត្រី Y៥)។

## ៥.៣ កត្តា អន្តរជំនាន់

*“មនុស្សស្រីធ្វើការផ្ទះភាគច្រើន ព្រោះពួកគេចិត្តល្អ ហើយពួកគេចង់ជួយ...... ខ្ញុំមិនគិតថាមានផលប៉ះពាល់អវិជ្ជមានអ្វីទេ ព្រោះពួកគេអាចរៀនសូត្របាន (ការងារក្នុងផ្ទះ) សម្រាប់គ្រួសារនាពេលអនាគត" (ស្ត្រី ០១៤)។*

ដូចមានចែងក្នុងផ្នែកទី ៤.១ នៃរបាយការណ៍នេះ តួនាទីមាតាបិតា និងជីដូនជីតា គឺជាកត្តាកំណត់ដ៏សំខាន់នៅក្នុងរបៀបដែលការងារថៃទាំគ្មានប្រាក់កម្រៃត្រូវបានចែករំលែករវាងសមាជិកគ្រួសារ។ ឪពុកម្តាយ និងជីដូនជីតាធ្វើជាគំរូសម្រាប់កូនៗ ដើម្បីធ្វើតាម និងកំណត់បទដ្ឋានក្នុងគ្រួសារដែលកូនៗរបស់ពួកគេនឹងអនុវត្តបន្តបន្ទាប់ពីពួកគេ។ ការចូលរួមមិនស្មើភាពគ្នានៅក្នុងការបំពេញការងារថៃទាំគ្មានប្រាក់កម្រៃដោយកុមារតូចៗត្រូវបានលេចឡើងជាថ្មីថាជាកត្តាជះឥទ្ធិពលដល់ការអនុវត្តបន្តនៃវិសមភាពបន្ទុកការងារថៃទាំគ្មានប្រាក់កម្រៃ ដែលនឹងក្លាយជាបន្ទុករបស់ស្ត្រីនៅពេលក្រោយក្នុងជីវិត។

អ្នកចូលរួមជាច្រើនក៏បានឆ្លុះបញ្ចាំងផងដែរថា នៅពេលដែលសកម្មភាពដដែលៗត្រូវបានបង្ហាញជារៀងរាល់ថ្ងៃមានលទ្ធភាពខ្ពស់នៃការធ្វើឱ្យមានលក្ខណៈធម្មតា។ ដោយមើលឃើញម្តាយ និងជីដូនកំពុងទទួលបន្ទុកការងារផ្ទះ កូនស្រីលូតលាស់ធំឡើងដោយគិតថាជារឿងធម្មតា ហើយថ្ងៃណាមួយពួកគេក៏នឹងទទួលបន្ទុកនេះផងដែរ៖ "...ពួកគេ... គិតថាការងារនេះ [ការងារផ្ទះ] ជារបស់ស្ត្រី ហើយផ្ទត់គំនិតនេះ [ផ្ទេរ] ពីមួយជំនាន់ទៅមួយជំនាន់" (បុរស Y៤)។

ម្យ៉ាងវិញទៀត ក្មេងប្រុសក៏ទៅធ្វើតាមតួនាទី និងអាកប្បកិរិយាដែលពួកគេឃើញឪពុក និងជីតារបស់ពួកគេបានធ្វើ។ ការយល់ឃើញរបស់បុរសជា 'អ្នករកលុយចិញ្ចឹមគ្រួសារ' ហើយការផ្តល់ហិរញ្ញវត្ថុសម្រាប់គ្រួសារ ត្រូវបានគេមើលឃើញថាជាកាតព្វកិច្ចស្នូលរបស់បុរស។ ក្មេងប្រុសក៏ត្រូវបានចាត់តាំងឱ្យធ្វើការងារថៃទាំគ្មានប្រាក់កម្រៃតិចជាងបងប្អូនស្រីរបស់ពួកគេ។ ក្មេងប្រុសក៏ត្រូវបានគេនិយាយថាទទួលបានពេលវេលាទំនេរច្រើន ក្រៅម៉ោងសិក្សាផ្លូវការរបស់ពួកគេជាងក្មេងស្រី ដែលត្រូវបានគេដឹងថាត្រូវបានផ្សារភ្ជាប់ទៅនឹងការស្ទាក់ស្ទើររបស់បុរសក្នុងការទទួលយកការងារថៃទាំគ្មានប្រាក់កម្រៃនៅចុងបញ្ចប់នៃម៉ោងធ្វើការ។ ដូចដែលអ្នកចូលរួមម្នាក់បានសង្កេតឃើញថា៖

*“នៅពេលធ្វើការងារផ្ទះ... មិនថាស្ត្រីមានការងារធ្វើ ឬក្មេងស្រីត្រូវរៀននោះទេ ឱ្យតែនៅពេលត្រឡប់មកផ្ទះវិញ នាងត្រូវចេះ និងរៀនធ្វើការងារទាំងអស់ក្នុងផ្ទះ។ ប៉ុន្តែក្មេងប្រុសមានសេរីភាពពីទំនួលខុសត្រូវនេះ។ ពេលត្រឡប់មកផ្ទះវិញ គេអាចទៅលេងបាល់ជាមួយមិត្តភក្តិ។ ប៉ុន្តែបើក្មេងស្រីត្រឡប់មកវិញ ត្រូវទទួលខុសត្រូវការងារផ្ទះហើយ ពេលខ្លះនាងទៅធ្វើម្ហូបជាមួយម្តាយរបស់នាង" (អ្នកស្រលាញ់ភេទដូចគ្នា Y៤ Tomboy) ។*

# កត្តាអន្តរជំនាន់ (ត)

*«ខ្ញុំគិតថាការបែងចែកអាច [កើតឡើង] ពីអ្វីដែលយើងបានឃើញ។ យើងឃើញម្តាយរបស់យើង - នៅក្នុងគ្រួសារដែលមានកូនប្រុសស្រី ... ក្នុងនាមយើងជាស្ត្រី នឹងធ្វើតាមម្តាយរបស់យើងនៅពេលយើងធំឡើង។*

*ជាមួយគ្នានេះដែរ ប្រសិនបើប្តីរបស់យើងធំឡើងក្នុងគ្រួសារដែលមានម្តាយធ្វើការងារ [ការងារថែទាំគ្មានប្រាក់កម្រៃ] បែបនេះ គាត់នឹងចងចាំថាប្រពន្ធជាអ្នកធ្វើនៅពេលគាត់ធំឡើង ប្រពន្ធត្រូវចេះធ្វើការងារដូចម្តាយរបស់គាត់។*

*ដូច្នេះការបែងចែកគឺផ្អែកលើយេនឌ័រ។ ជនជាតិខ្មែរតែងតែនិយាយថា ពេលក្មេងឃើញរឿងដដែលៗម្តងហើយម្តងទៀត ពួកគេនឹងចាំរឿងនោះដូចជាកាតព្វកិច្ច"។*

(ស្ត្រី Y៣)។

ទោះបីជាមនុស្សជាច្រើនបានបង្ហាញថា ការផ្លាស់ប្តូរទៅតាមជំនាន់ទៅលើការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃគឺពិតជាកើតឡើង (ដូចនឹងបានពិភាក្សានៅក្នុងផ្នែកទី ៧) ក្តី ក៏អ្នកចូលរួមមួយចំនួនបានលើកឡើងថា បុរស និងស្ត្រី នៅតែអាចទទួលរងឥទ្ធិពលពីរបៀបដែលឪពុកម្តាយរបស់ពួកគេ បានបង្ហាត់បង្រៀន និង ធ្វើអន្តរកម្មតាំងពីវ័យកុមារភាព។

ឧទាហរណ៍ អ្នកចូលរួមជាយុវតីម្នាក់បានពន្យល់ថា នៅក្នុងទំនាក់ទំនងរបស់នាងផ្ទាល់ «យើងធ្វើតាមអ្វីដែលបានកើតឡើងកាលពីអតីតកាល។ ដូចជារបៀបដែលយើងបានឃើញឪពុកម្តាយរបស់យើង៖ 'ពួកគាត់គឺបែបនេះ' ដូច្នេះយើងគិតដូចគ្នា។ ប្តីរបស់ខ្ញុំ នៅពេលគាត់នៅក្មេង គាត់ [ឃើញអ្វីៗធ្វើតាមរបៀបជាក់លាក់មួយ] ដូច្នេះពេលគាត់ពេញវ័យ គាត់ក៏ប្រកាន់យកបុគ្គលិកលក្ខណៈដូចគ្នានោះដែរ អញ្ចឹងពេលគាត់មានគ្រួសារ វានៅតែដដែល» (ស្ត្រី Y៣)។

អ្នកចូលរួមជាបុរសមួយចំនួនបាននិយាយថា ពួកគេបានលើកទឹកចិត្តកូនប្រុស ឬក្មួយប្រុសរបស់ពួកគេដោយជោគជ័យ ក្នុងការទទួលយកការងារថែទាំគ្មានប្រាក់កម្រៃឱ្យបានច្រើនជាងអ្វីដែលពួកគេបានអនុវត្តកាលពីកុមារភាព។ អ្នកផ្សេងទៀតបានជួបប្រទះលទ្ធផលចម្រុះ ដែលនាំឱ្យស្ត្រីវ័យក្មេងម្នាក់ដែលចូលរួមធ្វើការសន្និដ្ឋានថា៖ “ជារួម ក្មេងប្រុសមិនពូកែធ្វើកិច្ចការផ្ទះទេ បើទោះបីជាឪពុកម្តាយបានបង្រៀនពួកគេហើយក៏ដោយ - អ្នកខ្លះយកចិត្តទុកដាក់ធ្វើ ប៉ុន្តែអ្នកខ្លះមិនធ្វើ។ ជាធម្មតាក្មេងស្រីធំឡើងជួយម្តាយរបស់ពួកគេ ឬម្តាយរបស់ពួកគេពឹង ឬមិនបានពឹងឱ្យជួយ។ ពួកគេនៅតែយល់អំពីភារកិច្ចដែលពួកគេត្រូវការដើម្បីជួយម្តាយរបស់ពួកគេ (ស្ត្រី Y៨)។

# ៥.៤ កត្តា ភូមិសាស្ត្រ និងវណ្ណៈ

ក្នុងកំឡុងពេលសម្ភាសន៍ អ្នកចូលរួមជាច្រើនបានលើកឡើងអំពីទស្សនៈថា ស្ត្រីដែលរស់នៅក្នុងតំបន់ជនបទអាចប្រឈមមុខនឹងបន្ទុកខ្ពស់នៃការងារថែទាំគ្មានប្រាក់កម្រៃជាងស្ត្រីនៅទីក្រុង។ គួរឱ្យសោកស្តាយ សំណុំទិន្នន័យនៃការសិក្សានេះគឺតូចពេកក្នុងការ 'បញ្ជាក់ជាភស្តុតាង' នៃសម្មតិកម្មនេះតាមមធ្យោបាយមួយ ឬមួយផ្សេងទៀត។[៥] អ្វីដែលអាចឈ្វេងយល់បាន គឺការយល់ឃើញដែលអ្នកចូលរួមកម្ពុជាមានចំពោះការអនុវត្តការងារថែទាំគ្មានប្រាក់កម្រៃនៅតាមទីជនបទធៀបនឹងតំបន់ទីក្រុង។ ប្រការនេះ គឺជាចំណុចសំខាន់ដែលនឹងត្រូវសិក្សាឈ្វេងយល់នៅក្នុងរបាយការណ៍ផ្នែកនេះ។

អ្នកចូលរួមមិនថាក្មេង ឬចាស់ បុរស ឬស្ត្រី បានរាយការណ៍ស្របគ្នាអំពីការយល់ឃើញថានៅតែមានទំនាក់ទំនងយ៉ាងរឹងមាំរវាងគ្រួសារនៅតំបន់ជនបទ និងការថែរក្សាតួនាទីប្រពៃណីកាន់តែច្រើនរបស់ស្ត្រីជាអ្នកអនុវត្ត និងអ្នកគ្រប់គ្រងការងារថែទាំគ្មានប្រាក់កម្រៃ។

អ្នកចូលរួមជាបុរសវ័យចំណាស់ម្នាក់អះអាងថា គាត់បានព្យាយាមផ្លាស់ប្តូរផ្នត់គំនិតប្រពន្ធគាត់ឱ្យឆ្ងាយពីការផ្តល់កម្រិតមិនស្មើគ្នានៃការងារថែទាំគ្មានប្រាក់កម្រៃនៅក្នុងទំនាក់ទំនងរបស់ពួកគេ ដោយបញ្ជាក់ថានាងមានអារម្មណ៍ថា នាងមានទំនួលខុសត្រូវនេះដោយសារតែនាង "រស់នៅជនបទមុនពេលយើងរៀបការ" (បុរស O២)។

ទោះបីជាហាក់មានការឯកភាពជាទូទៅដែលចាត់ទុកតំបន់ជនបទថាជាតំបន់អភិរក្សនិយម និងបែបបុរាណ ហើយស្ត្រីបន្តបំពេញការងារថែទាំគ្មានប្រាក់កម្រៃភាគច្រើន ក៏មានអ្នកចូលរួមមួយចំនួនមិនបានបង្ហាញការយល់ស្របដូច្នេះដែរ។ ឧទាហរណ៍ អ្នកឆ្លើយតបជាបុរសបម្រើការងារក្នុងអង្គការសង្គមស៊ីវិល បានលើកទឡ្ហីករណ៍ថា៖ "ខ្ញុំមិនគិតថាមានភាពខុសគ្នាច្រើនរវាងអ្នករស់នៅក្នុងទីក្រុង និងអ្នករស់នៅតាមជនបទទេ ទោះបីជានៅតំបន់ជនបទអាចមានករណីលេចធ្លោរខ្លះក៏ដោយ។ អ្វីដែលខ្ញុំបានឃើញគឺថា សូម្បីតែអ្នកមានអំណាចក៏គេនៅតែប្រកាន់គំនិតបែបនេះដែរ" (បុរស C៣)។

*"ជាធម្មតា បទដ្ឋាន ឬផ្នត់គំនិតរបស់ប្រជាជនកម្ពុជា... គឺស្ត្រីជាស្ត្រីមេផ្ទះ។ ពួកគេតែងតែនិយាយថាស្ត្រីត្រូវនៅក្នុងផ្ទះបាយ ដូច្នេះពួកគេមិនមានពេលចេញទៅក្រៅទេ។*

*នេះជាទស្សនៈរបស់ប្រជាជនកម្ពុជាដែល បានប្រកាន់យក ជាពិសេសសម្រាប់អ្នកដែលរស់នៅតាមតំបន់ជនបទ។ ពួកគេតែងតែអនុវត្តផ្នត់គំនិតនេះ ដែលពួកគេតែងតែធ្វើតាមមកជានិច្ច។*

*ស្ត្រីនៅជនបទភាគច្រើន តែងតែទទួលយកកិច្ចការនេះ ហើយមិនដែលធ្វើអ្វីហួសពីនេះឡើយ។*

*សម្រាប់បុរសវិញ ពួកគេប្រើកម្លាំងពលកម្មធ្ងន់ៗ ប៉ុន្តែសម្រាប់ការងារដូចជាធ្វើម្ហូប... និងមើលថែកូនៗ ការងារទាំងអស់នេះជាការងាររបស់ស្ត្រី"។*

(បុរស O២)។

[៥] ទិន្នន័យស្ទង់មតិមិនបានបង្ហាញអំពីភាពលម្អៀងគ្នារវាងទស្សនៈដែលប្រកាន់ខ្ជាប់ដោយអ្នកឆ្លើយតបនៅតាមជនបទ និងទីក្រុងនោះទេ។ ប្រធានបទនេះផ្តល់ឱកាសសម្រាប់ការស្រាវជ្រាវស៊ីជម្រៅបន្ថែមទៀតដើម្បីសិក្សាអំពីវិសាលភាពដែលទីតាំងភូមិសាស្ត្រ និងវណ្ណៈដើរតួនាទីនៅក្នុងការយល់ឃើញ និងបទពិសោធន៍ទៅលើការងារថែទាំគ្មានប្រាក់កម្រៃ។

*"ស្ត្រីដាច់ខាតត្រូវតែធ្វើវា បើយើងមិនធ្វើវា ផ្ទះរបស់យើងមិនស្អាតនោះទេ។ យើងមិនអាចគ្រាន់តែជួលអ្នកបំរើបានទេ" (ស្ត្រី Y៣)។*

*«ជាពិសេស នៅតំបន់ជនបទ ផ្នត់គំនិត [ស្ត្រីជាស្ត្រីមេផ្ទះ និងបុរសជាអ្នករកស៊ីចិញ្ចឹម] នៅមានច្រើន [រីករាលដាល] ប៉ុន្តែនៅទីក្រុងគឺតិចជាង។*

*ជាពិសេសនៅក្នុងបរិបទដែលមានប្រជាជនក្រីក្រច្រើន ពួកគេបានយកផ្នត់គំនិតនេះទៅអនុវត្ត។ នេះគឺដោយសារពួកគេក្រីក្រ ពួកគេមិនអាចមានលទ្ធភាពឱ្យកូនស្រីទៅរៀន ឬទៅឆ្ងាយពីផ្ទះបាន។ ពួកគេ [ប្រើការងារថែទាំគ្មានប្រាក់កម្រៃ] ជាហេតុផលមិនបញ្ជូនកូនៗទៅសាលារៀន – ពួកគេគ្រាន់តែនៅផ្ទះ និងធ្វើការងារផ្ទះ។*

*វាអាស្រ័យលើកត្តាភូមិសាស្ត្រ និងជីវភាពរស់នៅរបស់ពួកគេ។*

*ប្រសិនបើពួកគេភាគច្រើនមានជីវភាពល្អ ពួកគេមានការអប់រំល្អ ការអនុវត្តផ្នត់គំនិតនេះនឹងមិនកើតឡើងច្រើនទេ”។*

(អ្នកស្រលាញ់ភេទដូចគ្នា Y៤ Tomboy)។

ស្ត្រីនៅតាមជនបទមួយចំនួនបានពិភាក្សាអំពីរបៀបនៃការបំពេញការងារថែទាំគ្មានប្រាក់កម្រៃរបស់ពួកគេឱ្យមានប្រសិទ្ធភាពសម្រាប់ពួកគេ ដោយសារតែពួកគេបានធ្វើការងារនៅផ្ទះ និងនៅកសិដ្ឋាន ខណៈដែលប្តីរបស់ពួកគេធ្វើការងារនៅកន្លែងផ្សេង។ ឧទាហរណ៍ ស្ត្រីម្នាក់មកពីភូមិមួយក្នុងខេត្តកំពង់ឆ្នាំងបាននិយាយថា៖ «ខ្ញុំគិតថា បើយើងមិនចែកគ្នាបែបនេះ យើងនឹងមិនដូចជាគ្រួសារទេ... គាត់ខំប្រឹងធ្វើការ ហើយនៅពេលគាត់ត្រឡប់មកវិញ គាត់នឹងសប្បាយចិត្ត ប្រសិនបើបានរៀបចំអាហារសម្រាប់គាត់ និងកូនៗហើយស្រេច" (ស្ត្រី Y១០)។

ស្ត្រីវ័យចំណាស់ម្នាក់ទៀតរស់នៅជនបទបាននិយាយថា ប្តីរបស់គាត់ជាកម្មករចំណាកស្រុក ដូច្នេះហើយគាត់ប្រឈមមុខនឹងបន្ទុកការងារថែទាំគ្មានប្រាក់កម្រៃទាំងមូលតែម្នាក់ឯង៖ "ខ្ញុំគឺជាអ្នកមើលថែគ្រួសាររបស់ខ្ញុំ។ ប្តីរបស់ខ្ញុំមានការងារធ្វើផ្ទាល់ខ្លួន គាត់មកផ្ទះតែ២-៣ថ្ងៃក្នុងមួយខែប៉ុណ្ណោះ។ [ខ្ញុំធ្វើ] អាហារ បោកគក់ ទៅផ្សារ មើលផ្ទះ - អ្វីគ្រប់យ៉ាង ជារៀងរាល់ថ្ងៃ រួមទាំងការសិក្សារបស់កូនខ្ញុំ"។

រឿងរ៉ាវទាំងនេះ នៅពេលដែលប្រៀបធៀបទៅនឹងការសម្ភាសន៍មួយចំនួនដែលបានធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញ នាំឱ្យមានការចោទសួរបន្ថែមទៀតអំពីភាពពាក់ព័ន្ធនៃវណ្ណៈ និងប្រវត្តិសេដ្ឋកិច្ច។ ឧទាហរណ៍ អ្នកចូលរួមនៅទីក្រុងមួយចំនួនបានស្នើថា ប្រសិនបើស្ត្រីមិនសប្បាយចិត្តនឹងការងារផ្ទះ ឬមើលថែទាំកុមារទេនោះ អញ្ចឹង "មានសាលារៀនជាច្រើនដែលស្ត្រីអាចបញ្ជូនកូនរបស់ពួកគេទៅ ឬពួកគេអាចជួលអ្នកថែទាំឱ្យមើលថែទាំកូនបាន" YSW ១៦)។ ជាក់ស្តែង ការជួយថែទាំកុមារ ឬការងារផ្ទះដែលមានប្រាក់កម្រៃ គឺជាអ្វីដែលមិនអាចទទួលបានសម្រាប់គ្រួសារកម្ពុជាភាគច្រើន៖ គម្លាតក្នុងតម្លៃសមរម្យនៃសេវាថែទាំកុមារត្រូវបានអ្នកចូលរួមមួយចំនួនលើកឡើងថាជាបញ្ហាគោលនយោបាយដែលគួរតែត្រូវបានដោះស្រាយដើម្បីកាត់បន្ថយបន្ទុកការងារថែទាំគ្មានប្រាក់កម្រៃរបស់ស្ត្រី។

# ៥.៥ សេចក្តីសន្និដ្ឋាន

**គំនូសសម្គាល់ទី ១០៖ តើអ្នកគិតថាមានការបែងចែកការងារផ្ទះដោយអយុត្តិធម៌រវាងសមាជិកគ្រួសារជាទូទៅនៅកម្ពុជាដែរឬទេ?**




នៅក្នុងផ្នែកនេះនៃរបាយការណ៍ បានឈ្វេងយល់អំពីកត្តាដែលបានរាយការណ៍ដោយអ្នកចូលរួម ថាបានជះឥទ្ធិពលលើការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃនៅក្នុងគ្រួសារកម្ពុជាបច្ចុប្បន្ន។ ផ្នែកនេះចាប់ផ្តើមពីការពិនិត្យមើលអំពីរបៀបដែលអ្នកចូលរួមយល់ឃើញអំពីផលប៉ះពាល់នៃប្រពៃណីវប្បធម៌ និងប្រវត្តិសាស្ត្រ មុនពេលត្រួតពិនិត្យមើលកត្តាសង្គមដែលជះឥទ្ធិពលលើបរិមាណការងារថែទាំគ្មានប្រាក់កម្រៃដែលដៃគូនីមួយៗធ្វើ។

បន្ទាប់មកទៀត នឹងត្រួតពិនិត្យមើលការយល់ឃើញអំពីផលប៉ះពាល់នៃការចិញ្ចឹមកូនប្រុសស្រីតាំងពីកុមារភាព ដែលមានកម្រិតទំនួលខុសត្រូវខុសៗគ្នា និងផ្តល់សេចក្តីសង្ខេបចុងក្រោយថាតើការរស់នៅតាមជនបទ និងការមានប្រាក់ចំណូលជាក់លាក់ប៉ះពាល់ដល់ការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃដែរឬទេ។

ជាចុងក្រោយ ជាការសំខាន់ណាស់ក្នុងការគូសបញ្ជាក់ម្តងទៀតថា (ទោះបីជាមានលទ្ធផលរកឃើញនៅក្នុងក្រាហ្វខាងលើក៏ដោយ) មិនមែនអ្នកចូលរួមទាំងអស់សុទ្ធតែបានរាយការណ៍ថាមានការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃមិនស្មើភាពគ្នានៅក្នុងគ្រួសាររបស់ពួកគេទេ ហើយមិនមែនអ្នកចូលរួមទាំងអស់សុទ្ធតែយល់ឃើញថាការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃមិនស្មើគ្នាគឺជារឿងអវិជ្ជមាននោះទេ។ ឧទាហរណ៍ អ្នកចូលរួមជាបុរសម្នាក់បានចែករំលែកអំពីរឿងរ៉ាវដូចតទៅ៖ “សម្រាប់គ្រួសារខ្ញុំ កិច្ចការមួយដែលនាងមិនអាចអនុញ្ញាតឱ្យអ្នកផ្សេងទៀតធ្វើគឺការងារចង្ក្រានចានឆ្នាំង។ ព្រោះខ្ញុំមិនហ៊ានធ្វើនោះទេ ដោយសារតែនាងមិនគិតថាម្ហូបរបស់ខ្ញុំឆ្ងាញ់នោះទេ" (ការពិភាក្សាក្រុមគោលដៅបុរស)។

ប្រការនេះរំឭកយើងថា ចំពោះស្ត្រីជាច្រើន ការចម្អិនអាហារ និងទម្រង់ផ្សេងៗទៀតនៃការងារថែទាំគ្មានប្រាក់កម្រៃគឺជាកិច្ចការសំខាន់ដែលពួកគេមានមោទនភាពយ៉ាងខ្លាំងក្នុងការអនុវត្តបានល្អ។ បើគិតពីទស្សនៈបុគ្គលស្ត្រីនិយម និងសិទ្ធិមនុស្ស បញ្ហានេះមិនស្ថិតនៅក្នុងការអនុវត្តការងារថែទាំគ្មានប្រាក់កម្រៃនោះទេ។ ផ្ទុយទៅវិញ វាស្ថិតនៅក្នុងកង្វះខាតការសម្រុះសម្រួលគ្នាដើម្បីចែករំលែកការងារទាំងនោះដោយស្មើភាពគ្នាជាមួយសមាជិកគ្រួសារផ្សេងទៀត ឧទាហរណ៍ ប្រសិនបើស្ត្រីម្នាក់មិនចូលចិត្តធ្វើម្ហូប និង/ឬយល់ថានាងមិនសូវពូកែ ឬយល់ថាការធ្វើម្ហូបដាក់កម្រិតលើពេលវេលារបស់នាងសម្រាប់ការខិតខំប្រឹងប្រែងផ្សេងទៀតដែលនាងគិតថាអត្ថន័យកាន់តែច្រើនជាងនេះ ឬគ្រាន់តែរីករាយជាមួយបន្ថែមទៀត។

# ៦

# នៅក្នុងពិភពដែលឥតខ្ចោះ... ការយល់ឃើញអំពីស្ថានភាពនៃការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃដែលសមស្រប

# ៦
# នៅក្នុងពិភពដែលឥតខ្ចោះ...

***"ខ្ញុំគិតថាគួរតែចែករំលែកការងារផ្ទះ ការងារផ្ទះមិនមែនជាការងារសម្រាប់មនុស្សម្នាក់នោះទេ។ យើងរស់នៅក្រោមដំបូលតែមួយ យើងគួរតែធ្វើការងារនោះជាមួយគ្នា។ ខ្ញុំគិតថាការងារផ្ទះ ជាការងាររួម... ការងារផ្ទះគឺជាទំនួលខុសត្រូវរបស់ប្រពន្ធ និងប្តី។ វាមិនមែនគ្រាន់តែ 'ការជួយ' នោះទេ" (ស្ត្រី Y៨)។***

រហូតមកដល់ផ្នែកនេះ លទ្ធផលរបកគំហើញនៃការសិក្សាស្រាវជ្រាវនេះ បានផ្តោតការយកចិត្តទុកដាក់ទៅលើស្ថានភាពបច្ចុប្បន្ន - ជាក់ស្តែងនៅក្នុងផ្នែកទី ៤ អ្នកចូលរួមបានឆ្លុះបញ្ចាំងចំពោះស្ថានភាពអ្វីខ្លះដែលកំពុងកើតឡើងនាពេលបច្ចុប្បន្នទាក់ទងនិងការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃ បន្ទាប់មកនៅក្នុងផ្នែកទី ៥ អ្នកចូលរួមបានធ្វើការឆ្លុះបញ្ចាំងអំពីមូលហេតុនានា ដែលនាំឲ្យស្ថានភាពទាំងអស់នោះកើតមានឡើង។ របកគំហើញនៅក្នុងផ្នែកទាំងពីរនេះ បានចង្អុលបង្ហាញថាបើទោះបីជាមានការប្រែប្រួលជាវិជ្ជមានខ្លះក៏ដោយ ក៏ការរ៉ាប់រងបន្ទុកនៃការងារថៃទាំគ្មានប្រាក់កម្រៃ នៅតែធ្លាក់ទៅលើស្ត្រីច្រើនជាងបុរសដដែល ហើយកត្តាជម្រុញឲ្យបន្តនិន្នាការនៃការបែងចែកបែបនេះគឺ កត្តាវប្បធម៌ សង្គម អន្តរជំនាន់ និងស្ថានភាពតំបន់ភូមិសាស្ត្រ។

នៅក្នុងផ្នែកនេះ របាយការណ៍នឹងបង្វែរទៅត្រួតពិនិត្យ និងឈ្វេងយល់អំពីការយល់ឃើញរបស់អ្នកចូលរួមអំពីអ្វីដែលពួកគេមានអារម្មណ៍ថា គួរតែកើតឡើង ទាក់ទងនឹងការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។

ការឆ្លើយតបទាំងនេះ ដោយមិនគិតពីភេទ អាយុ ឬនិន្នាការភេទ ត្រូវបានគាំទ្រយ៉ាងច្រើនលើសលប់ថា ការបែងចែកបន្ទុកនៃការងារថៃទាំគ្មានប្រាក់កម្រៃគួរតែមានសមភាពជាងស្ថានភាពក្នុងពេលបច្ចុប្បន្ននេះ។

ដូចយុវជនម្នាក់បានសង្ខេបថា៖ "ខ្ញុំមិនគិតថា [ការបែងចែកការងារផ្ទះក្នុងសង្គមកម្ពុជាបច្ចុប្បន្ន] គឺល្អនោះទេ ព្រោះការងារទាំងអស់គួរធ្វើទាំងបុរស និងស្ត្រី។ ទាំងប្តី និងប្រពន្ធមានទំនួលខុសត្រូវក្នុងការគ្រប់គ្រងរួម ទាំងជំនួញ ឬការងារផ្ទះ។ សូម្បី...ការលាងចាន និងធ្វើម្ហូប ក៏ប្តីអាចជួយបានដែរ... យើងមិនគួរណាបណ្តោយឱ្យការងារផ្ទះធ្លាក់ទៅលើមនុស្សតែម្នាក់នោះទេ វាមិនមែនជាការល្អឡើយ" (បុរស Y៧)។

*«ជាការសំខាន់ណាស់ដែលត្រូវអប់រំបុរសថា ការធ្វើការងារផ្ទះមិនប៉ះពាល់ដល់ភាពជាបុរសទេ ហើយការងារផ្ទះជាទំនួលខុសត្រូវរបស់មនុស្សគ្រប់រូប...*

*ពួកគេចាំបាច់ត្រូវតែយល់ថា ការធ្វើការងារផ្ទះគឺជាទំនួលខុសត្រូវដ៏ធំមួយ ហើយមិនគួរណាទម្លាក់ទៅលើមនុស្សតែម្នាក់នោះទេ។ នៅក្នុងសង្គមគួរតែមានការតស៊ូមតិបន្ថែមទៀតក្នុងចំណោមគ្រួសារ ដើម្បីលុបបំបាត់ផ្នត់គំនិតបែបប្រពៃណីចាស់ដែលបុរសគួរតែជាអ្នករកប្រាក់ដើម្បីផ្គត់ផ្គង់គ្រួសាររបស់គាត់។*

*ផ្នត់គំនិតនេះគួរតែផ្លាស់ប្តូរ ជាពិសេសសម្រាប់បុរសឱ្យដឹងពីសារៈសំខាន់នៃការជួយធ្វើការងារផ្ទះប្រពន្ធ»*

(ស្ត្រី Y៥)។

# នៅក្នុងពិភពដែលឥតខ្ចោះ ... (ត)
## ទំនាក់ទំនងដែលមានផាសុខភាព និងភាពសុខដុមរមនា

*យើងមិនគួរបែងចែកកាតព្វកិច្ចដោយផ្អែកលើយេនឌ័រនោះទេ... យើងត្រូវជួយគ្នាទៅវិញទៅមកព្រោះយើងរស់នៅក្រោមដំបូលផ្ទះតែមួយ។ [ប្រសិនបើអ្នកគិតថាអ្នក] ជួយគ្រួសារខាងផ្នែកហិរញ្ញវត្ថុ ដូច្នេះអ្នកមិនចាំបាច់លើកម្រាមដៃទៅធ្វើការងារផ្ទះនោះ ផ្នត់គំនិតនេះនឹងមិនជួយឱ្យអ្នករស់នៅប្រកបដោយសុភមង្គលជាមួយគ្រួសារអ្នកឡើយ...*
*ទង្វើនេះនឹងនាំឱ្យមានការខឹងសម្បារ ឬថែមទាំងការបែកបាក់គ្នាទៀតផង ... បើយើងចង់ឱ្យចំណងអាពាហ៍ពិពាហ៍គង់វង្សបានយូរអង្វែងជាមួយប្រពន្ធរបស់យើង យើងត្រូវជួយធ្វើការងារផ្ទះនាង" (បុរស Y១)*

*"បុរស និងស្ត្រីគួរតែស្មើគ្នា។*

*យើងត្រូវចេះជួយគ្នាទៅវិញទៅមក ដូច្នេះយើងទាំងអស់គ្នានឹងមានសុភមង្គល។ យើងអាចញ៉ាំអាហារជាមួយគ្នាដោយរីករាយ។*

*សាររបស់ខ្ញុំទៅកាន់អ្នកទាំងអស់គ្នាគឺថា ការបែងចែកដែលស្ត្រីត្រូវធ្វើការងារផ្ទះ គួរតែដល់ពេលត្រូវបញ្ចប់ហើយ ហើយស្ត្រីក៏គួរតែអាចចេញទៅក្រៅផ្ទះ បង្កើតទំនាក់ទំនងសង្គម និងទទួលបានការអប់រំដូចបុរសដែរ។*

*កុំគិតថាស្ត្រីនៅពីក្រោយបុរស ប្រការនេះឆ្លុះបញ្ចាំងពីវិសមភាព [ដែលបង្ហាញឡើង] នៅពេលដែលយើងឈានជើងលើជញ្ជីង ហើយវាផ្អៀងយ៉ាងខ្លាំងទៅម្ខាង - ទៅរកភាគីខាងស្ត្រី ខណៈដែលភាគីបុរសកាន់តែស្រាល។ ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាចេះបែងចែកឱ្យច្បាស់៖ កុំគិតថាការងារនេះនឹងធ្វើឱ្យបន្ថយតម្លៃអ្នក ឬអ្នកនឹងដូចជាស្ត្រីនៅពេលអ្នកធ្វើការងារនេះ។*
*សូមកុំគិតបែបនេះ"*

(ស្ត្រីស្រលាញ់ភេទដូចគ្នា Y១)។

នៅផ្នែកខាងដើមនៃរបាយការណ៍នេះ គំនិតស្តីពីវិសមភាពនៃការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃ និងវិសមាមាត្រទៅលើស្ត្រី ត្រូវបានវែកញែកដោយផ្អែកលើទិដ្ឋភាពជាក់ស្តែងដែលថា ការបង្កើត និងថែរក្សា 'ភាពសុខដុមរមនា' និង 'សុភមង្គល' ក្នុងគ្រួសារគឺកាតព្វកិច្ចរបស់ស្ត្រី។

ទោះជាយ៉ាងនេះក្តី អ្នកចូលរួមជាច្រើនអះអាង - ផ្ទុយទៅវិញថា - សុភមង្គលគ្រួសារកើតមានយ៉ាងល្អបំផុត នៅពេលប្តីប្រពន្ធចេះចែករំលែកការងារផ្ទះ និងភារៈកិច្ចការងារថែទាំផ្សេងទៀតដោយស្មើភាពគ្នា។ អ្នកចូលរួមម្នាក់ថែមទាំងបានផ្តល់យោបល់ថា ការស្វែងរកតុល្យភាពនេះគឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះទំនាក់ទំនងដ៏ជោគជ័យមួយដែល "មុនពេលរៀបការ ប្តីប្រពន្ធគួរពិភាក្សាអំពីការងារផ្ទះដែលពួកគេម្នាក់ៗគួរធ្វើ" (ស្ត្រីទី C១)។

ការឆ្លើយតបដែលឱ្យយោបល់ថា ការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃប្រកបដោយយុត្តិធម៌លើកកម្ពស់សុភមង្គលអាពាហ៍ពិពាហ៍ ក៏បានមកពីបុរសជាច្រើនផងដែរ ជាពិសេសពីអ្នកចូលរួមជាបុរសវ័យក្មេង។ ទោះជាយ៉ាងនេះក្តី សូម្បីតែបុរសវ័យចំណាស់មួយចំនួន ក៏បានបង្ហាញពីការយល់ឃើញដូចគ្នានេះដែរ ដូចជាឧទាហរណ៍ខាងក្រោមបង្ហាញថា៖ "សព្វថ្ងៃនេះ ខ្ញុំគិតថា ការទទួលខុសត្រូវគួរត្រូវបានចែករំលែករវាងសមាជិកក្នុងគ្រួសារ។ អ្វីដែលខ្ញុំចង់និយាយគឺ យើងមិនគួររំពឹងអ្នកផ្សេងឱ្យធ្វើការងារផ្ទះឡើយ។ ការបែងចែកការផ្ទះ ជួនកាលអាចប្រែទៅជាការពិភាក្សាដ៏ក្តៅគគុកនៅក្នុងគ្រួសារ នៅពេលដែលការបែងចែកនោះគឺផ្អែកលើផ្នត់គំនិតបែបប្រពៃណីរបស់យើង ហើយភាគីម្ខាងទទួលខុសត្រូវទាំងស្រុងចំពោះការងារផ្ទះតែម្នាក់ឯង" (បុរស O៧)។

របកគំហើញនេះមានសារៈសំខាន់ ដោយបង្ហាញថា ការយល់ឃើញអំពីយុទ្ធសាស្ត្រដ៏ល្អបំផុតក្នុងការលើកកម្ពស់សុភមង្គលគ្រួសារ ភាពសុខដុមរមនា និងសុខុមាលភាពគ្រួសារ គឺកំពុងតែមានការផ្លាស់ប្តូរ ហើយអាចនឹងឈានទៅបញ្ឈប់នូវស្ថានភាពដែលបានព្យាករណ៍កន្លងមកថា ស្ត្រីត្រូវតែបូជាសុភមង្គលផ្ទាល់ខ្លួនដើម្បីគ្រួសារផងដែរ។

# នៅក្នុងពិភពដែលឥតខ្ចោះ... (ត)

## បន្ទុកផ្លូវចិត្ត

*“ការណ៍ដែលមនុស្សភាគច្រើន [យល់ថា ការរៀបចំទុកដាក់ និងការថែទាំមនុស្សនៅក្នុងផ្ទះគឺជាកាតព្វកិច្ចរបស់ស្ត្រី] នៅតែជាតថភាពពិត។ ប៉ុន្តែខ្ញុំមិនយល់ស្របជាមួយនឹងការយល់ឃើញបែបនេះទេ។ ខ្ញុំមិនយល់ស្របដែលស្ត្រីគួរគ្រប់គ្រងរឿងទាំងអស់នោះទេ ព្រោះអ្នករាល់គ្នានៅក្នុងផ្ទះគួរតែដឹងពីអ្វីដែលពួកគេត្រូវធ្វើ" (អ្នកស្រលាញ់ភេទដូចគ្នា Y៤ Tomboy) ។*

**គំនូសសម្គាល់ទី ១១៖ តើអ្នកគិតថាបុរសគួរតែចូលរួមរ៉ាប់រ៉ង 'បន្ទុកផ្នែកផ្លូវចិត្ត' បន្ថែមទៀតក្នុងការរៀបចំផែនការ 'គ្រប់គ្រងជីវិត' គ្រួសារ (រៀបចំការណាត់ជួបរបស់កូនៗ ការបំផ្លាស់ប្តូរ និងបំពេញបន្ថែមសម្ភារៈ អនាម័យជាដើម) ដែរទេ?**




អ្នកចូលរួមជាច្រើនក៏បានឆ្លុះបញ្ចាំងផងដែរថា គួរតែមានការផ្លាស់ប្តូរបរិមាណនៃបន្ទុកផ្លូវចិត្ត ដែលត្រូវបានរ៉ាប់រងដោយមិនស្មើភាពដោយស្ត្រីនៅក្នុងទម្រង់នៃការបែងចែក និងការគ្រប់គ្រងការងារថែទាំគ្មានប្រាក់កម្រៃ។ លើសពីនេះ ទិន្នន័យស្ទង់មតិបានបង្ហាញថា តិចជាង ៥% នៃអ្នកឆ្លើយតប មានអារម្មណ៍ថា ស្ត្រីគួរតែជាអ្នកគ្រប់គ្រងកិច្ចការទាំងនេះដោយគ្មានជំនួយ ខណៈដែលស្ទើរតែ ២ ភាគ ៣ យល់ថាបុរសគួរតែទទួលយកការងារផ្នែកពលកម្មបញ្ញានេះបន្ថែមទៀត។ ចំណុចនេះត្រូវបានលើកជាទឡ្ហីករណ៍ថា ស្ត្រីមិនគួរទៅពឹងប្តីរបស់ពួកគេឱ្យបំពេញកិច្ចការសំខាន់ៗនោះទេ ហើយបន្ទាប់មក ត្រូវតាមដានការបំពេញការងាររបស់ប្តី ហើយត្រូវចងចាំថាត្រួតពិនិត្យបន្ថែមដើម្បីធានាការបំពេញការងារនោះបានចប់សព្វគ្រប់៖ "តាមពិតទៅ យើងមិនគួរចាំបាច់ត្រូវការសំណើពីស្ត្រីដើម្បីឱ្យជួយធ្វើការងារនោះទេ" (អ្នកស្រលាញ់ភេទដូចគ្នា Y៤ Tomboy)។

អ្នកចូលរួមជាបុរសបានទទួលស្គាល់ និងសង្កត់ធ្ងន់ផងដែរទៅលើទំនាក់ទំនងរវាងបន្ទុកការងារថែទាំគ្មានប្រាក់កម្រៃដែលមិនយុត្តិធម៌សម្រាប់ស្ត្រី និងលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានពេលវេលាទំនេរ និងការសម្រាក ដោយគូបញ្ជាក់ថា "យើង [ជាស្វាមី] ចាំបាច់ត្រូវជួយការងារផ្ទះពួកគេ [ប្រពន្ធ] ... ពីព្រោះពួកគេក៏ត្រូវការពេលវេលាសម្រាប់សម្រាកដែរ" (បុរស O២) ។

ចុងក្រោយ អ្នកចូលរួមជាស្ត្រីមួយចំនួនបានជំទាស់ចំពោះការប្រើប្រាស់ពាក្យថា 'អ្នកជួយ' ដែលមានការកើនឡើងយ៉ាងខ្លាំងនៅទូទាំងសំណុំទិន្នន័យ ដែលសំដៅដល់បុរសដែលធ្វើការងារថែទាំគ្មានប្រាក់កម្រៃនៅក្នុងផ្ទះរបស់ពួកគេ។ ដូចស្ត្រីវ័យក្មេងម្នាក់បាននិយាយថា “យើង [ទាំងពីរ] ត្រូវដឹងពីរបៀបធ្វើការងារនេះជាមួយគ្នា មិនមែនជាអ្នកជួយទេ – អ្នកជួយមានន័យថាមាននរណាម្នាក់ជួយពីពេលមួយទៅពេលមួយ។ យើងត្រូវចែករំលែកការងារនេះស្មើៗគ្នា" (ស្ត្រី Y៤)។

# នៅក្នុងពិភពដែលឥតខ្ចោះ ... (ត)
## អន្តរជំនាន់

*«នៅពេលដែលនិយាយពីទំនួលខុសត្រូវការងារផ្ទះ បើខ្ញុំមានកូនខ្លួនឯងផ្ទាល់ ខ្ញុំនឹងមិនបែងចែកតាមយេនឌ័រនោះទេ ដូចជា៖ ក្មេងប្រុសមិនគួរលាងចានទេ ហើយគួរតែផ្តោតតែទៅលើការរៀនសូត្រ ចំណែកខាងកូនស្រីត្រូវលាងចាន។ ខ្ញុំមិនចង់ឱ្យសេណារីយ៉ូនេះកើតឡើងទេ។ ខ្ញុំចង់ឱ្យពួកគេរៀនពីរបៀបធ្វើកិច្ចការទាំងនេះ ហើយចែករំលែកគ្នាទៅវិញទៅមក។ ដូច្នេះនៅពេលដែលពួកគេមានគ្រួសារផ្ទាល់ខ្លួននោះ ពួកគេមិនប្រកាន់ផ្នត់គំនិតថា 'ការងារនេះគឺសម្រាប់ក្មេងប្រុស ហើយការងារនេះគឺសម្រាប់ក្មេងស្រី'" នោះទេ (អ្នកស្រលាញ់ភេទដូចគ្នា Y៤ Tomboy) ។*

ផ្នែកមួយទៀតដែលអ្នកចូលរួមបានបង្ហាញអំពីបំណងប្រាថ្នាយ៉ាងខ្លាំងសម្រាប់ការផ្លាស់ប្តូរ គឺនៅក្នុងការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃក្នុងចំណោមកុមារ ដើម្បីបំបែកការរៀនសូត្រអន្តរជំនាន់ដែលថាការងារផ្ទះ ការចម្អិនអាហារ និងការថែទាំកុមារ គឺសម្រាប់តែក្មេងស្រី និងស្ត្រីតែប៉ុណ្ណោះ។

*“ខ្ញុំចង់ឱ្យបុរសមានទំនួលខុសត្រូវនេះហើយជាមូលហេតុដែលខ្ញុំបង្រៀនកូនរបស់ខ្ញុំទាំងអស់អំពីការងារផ្ទះ។*

*មិនថាអ្នកជាយេនឌ័រអ្វីទេ អ្នកអាចធ្វើការងារទាំងនេះបាន ដូច្នេះកូនរបស់ខ្ញុំទាំងអស់ត្រូវទទួលខុសត្រូវលើការងាររបស់ខ្លួន។*

*ចំពោះខ្ញុំ ខ្ញុំចង់បានទំនួលខុសត្រូវស្មើៗគ្នា ព្រោះក្នុងសង្គមបច្ចុប្បន្នស្ត្រីក៏ទៅធ្វើការដូចបុរសដែរ»។*

(ស្ត្រី ០១៣)។

អ្នកចូលរួមនៅទូទាំងទិន្នន័យបានលើកទឡ្ហីករណ៍ថា ការបង្រៀនកុមារទាំងអស់ឱ្យចេះទទួលខុសត្រូវលើការងារផ្ទះ និងការជួយគ្នាទៅវិញទៅមកដោយ -មិនគិតពីយេនឌ័រ - គួរតែត្រូវបានបណ្តុះចំពោះក្មេងប្រុស និងក្មេងស្រីជំនាន់ថ្មី។ ដូចគេនិយាយថា “បើខ្ញុំមានកូនស្រី ខ្ញុំមិនទុកឱ្យនាងនៅផ្ទះ ហើយបន្តការងារផ្ទះទៀតទេ។ ខ្ញុំនឹងរៀបចំនាងឱ្យចូលរួមនៅក្នុងសង្គមខាងក្រៅ ដោយសារតែសង្គមមានការផ្លាស់ប្តូរ [យ៉ាង] ឆាប់រហ័ស" (ស្ត្រី ០៥)។

អ្នកចូលរួមជាបុរសជាច្រើនក៏បានយល់ស្របថា ត្រូវបង្រៀនកុមារថាការងារផ្ទះ គឺជាទំនួលខុសត្រូវរួម និងមិនជាក់លាក់ចំពោះយេនឌ័រនោះទេ។ កិច្ចការសាមញ្ញៗដូចជាការបោសសម្អាត ត្រូវបានលើកឡើងថាមានតម្លៃសម្រាប់កុមារ ព្រោះពួកគេអាចចាប់ផ្តើមរៀនតាំងពីក្មេង។ អ្នកចូលរួមបានសង្កត់ធ្ងន់ថា វាមានសារៈសំខាន់ណាស់សម្រាប់កុមារក្នុងការយល់ដឹងពីតម្លៃពិតនៃកាតព្វកិច្ចគ្រួសារដែលត្រូវធ្វើរួមគ្នា និងមិនផ្អែកលើយេនឌ័រ៖ "យើងគួរឱ្យទាំងកូនប្រុស និងកូនស្រីធ្វើការងារផ្ទះដោយ មិនគិតពីយេនឌ័រ" (បុរស ០១)។

ជាចុងក្រោយ អ្នកចូលរួមម្នាក់បានលើកឡើងអំពីទំនាក់ទំនងដ៏សំខាន់រវាងការងារថែទាំគ្មានប្រាក់កម្រៃ និងការទទួលបានសិទ្ធិមនុស្ស ដោយលើកទឡ្ហីករណ៍ថា៖ "...យើងគួរតែប្រគល់ភារៈកិច្ចដែលពួកគេអាចធ្វើបានឱ្យពួកគេ មិនថាពួកគេជាក្មេងប្រុស ឬក្មេងស្រីនោះទេ ដោយការធ្វើបែបនេះផ្តល់ឱ្យពួកគេនូវសិទ្ធិស្មើគ្នា" (ស្ត្រី ០៩) ។

# នៅក្នុងពិភពដែលឥតខ្វោះ ... (ត)

## សេចក្ដីសន្និដ្ឋាន

**គំនូសសម្គាល់ទី ១២៖ តាមគំនិតរបស់អ្នក តើការបែងចែកឲ្យស្ត្រីជាអ្នកធ្វើកិច្ចការផ្ទះភាគច្រើនបែបនេះ ជាការបែងចែកទំនួលខុសត្រូវក្នុងគ្រួសារដោយស្មើរភាពទេ?**




ផ្នែកនេះបានស្វែងយល់អំពីការយល់ឃើញរបស់អ្នកចូលរួម និងអ្នកឆ្លើយតបការស្ទង់មតិទាក់ទងនឹងអ្វីដែលពួកគេមានអារម្មណ៍ថា ការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃនៅកម្ពុជានាពេលបច្ចុប្បន្ននេះគួរតែប្រព្រឹត្តទៅបែបណា។ របាយការណ៍នេះបានរកឃើញថា អ្នកចូលរួមជាច្រើនមានអារម្មណ៍ថា គួរតែមានការបែងចែកការងារនេះដោយយុត្តិធម៌រវាងសមាជិកគ្រួសារដែលមានយេនឌ័រខុសៗគ្នា ជាពិសេសទាំងប្ដី និងប្រពន្ធដែលកំពុងធ្វើការនៅខាងក្រៅផ្ទះ។ របកគំហើញនេះ ត្រូវបានគាំទ្រដោយគំនូសតាងខាងលើ ដែលអ្នកឆ្លើយតបភាគច្រើនបានបង្ហាញថា ការងារផ្ទះគួរតែត្រូវបានចែករំលែកស្មើៗគ្នារវាងសមាជិកគ្រួសារ ដោយមិនគិតពីយេនឌ័រ។

ទោះជាយ៉ាងណាក៏ដោយ អ្នកចូលរួមមួយចំនួនបានរាយការណ៍អំពីការយល់ឃើញថា ការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃបច្ចុប្បន្នគួរតែរក្សាទុកដដែល។ ឧទាហរណ៍ មនុស្សជាច្រើនមានអារម្មណ៍ថា ទោះបីជាបុរសគួរតែ 'ជួយ' ក្ដី ក៏ស្ត្រីគួរនៅតែជាអ្នកគ្រប់គ្រងផែនការគ្រួសារ៖ “ស្ត្រីគួរតែនាំមុខ" (ស្ត្រី ០១៦)។ "ខ្ញុំគិតថាស្ត្រីជាអ្នកគ្រប់គ្រងផែនការ ប៉ុន្តែ... នៅពេលដែលខ្ញុំរវល់ ឬត្រូវទៅស្រែ គាត់គួរតែជួយ... ការងារដែលជារបស់ស្ត្រី ប៉ុន្តែបុរសក៏អាចធ្វើបានដែរ" (ស្ត្រី ០១០)។

អ្នកចូលរួមម្នាក់បានណែនាំថា ទស្សនៈបែបប្រពៃណីនិងប្រវត្តិសាស្ត្រ ដែលចាត់ទុកថាស្ត្រីជាអ្នកបំពេញការងារថៃទាំគ្មានប្រាក់កម្រៃនៅក្នុងផ្ទះ នៅតែបន្តមានឥទ្ធិពលជាប់លាប់រហូតមក៖ "ចំពោះខ្ញុំ ខ្ញុំគិតថារបៀបនៃការបែងចែកការងារក្នុងសង្គមកម្ពុជាមិនល្អទេ។ ប៉ុន្តែខ្ញុំមិនបដិសេធទេ ព្រោះនេះជារឿងដែលបានធ្វើកន្លងមកទាំងពីអតីតកាល - យើងមានទម្លាប់នេះ" (បុរស ០២)។

ទោះបីជាមានមតិខុសៗគ្នាក៏ដោយ អ្នកដែលឆ្លើយតបការស្ទង់មតិ និងសម្ភាសន៍ភាគច្រើន បានរាយការណ៍ថា គួរតែមានការផ្លាស់ប្ដូរឆ្ពោះទៅរកសមធម៌ឲ្យកាន់តែច្រើននៅក្នុងការបែងចែក និងការគ្រប់គ្រងការងារនេះ។ នៅផ្នែកបន្ទាប់នេះជាផ្នែកចុងក្រោយនៃរបាយការណ៍ ដែលនឹងត្រួតពិនិត្យមើលថាតើការផ្លាស់ប្ដូរបរិបទសង្គមនេះបានកើតឡើងនៅក្នុងកម្រិតណារហូតមកដល់ពេលនេះ។

# ៣

# ការវិវត្តនៃបរិបទសង្គម... ការផ្លាស់ប្តូរទស្សនៈ ទៅតាមជំនាន់

# ៧
# ការវិវត្តនៃបរិបទសង្គម

*"សម្រាប់... ស្ត្រីដូចជាបងស្រីរបស់ខ្ញុំ គាត់មានឱកាសទៅធ្វើការនៅខាងក្រៅ និងជួបជុំមិត្តភក្តិ ក៏ដូចជាបើកអាជីវកម្ម និងបង្កើតទំនាក់ទំនងជាមួយអ្នកដទៃ... ឥឡូវនេះ ស្ត្រីភាគច្រើនមានសិទ្ធិទាំងនេះ។ ទោះបីយើងមិនទាន់ស្មើនិងបុរសក្តី ក៏នៅតែល្អជាងមុនដែរ" (អ្នកស្រលាញ់ភេទដូចគ្នា ស្ត្រី Y១)។*

នៅក្នុងផ្នែកចុងក្រោយនៃរបាយការណ៍នេះ អ្នកចូលរួមបានឆ្លុះបញ្ចាំងអំពីអារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគេ ថាតើបរិបទសង្គមបានផ្លាស់ប្តូររួចហើយឬនៅ នៅក្នុងការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃរវាងបុរស និងស្ត្រីនៅក្នុងប្រទេសកម្ពុជា។

ដូចផ្នែកមុនដែរ ការយល់ឃើញជាទូទៅគឺច្បាស់ថា៖ អ្នកឆ្លើយសំណួរភាគច្រើនបានរាយការណ៍ថា មានការផ្លាស់ប្តូរយ៉ាងសំខាន់នៅក្នុងរបៀបដែលគូស្វាមីភរិយាបែងចែកការងារផ្ទះ និងទម្រង់ការងារថែទាំផ្សេងទៀត។ មនុស្សជាច្រើនបានសម្តែងការលើកឡើងនេះក្នុងន័យថាមានការរំពឹងទុកខុសគ្នាទៅលើគូស្វាមីភរិយា ជំនាន់ខុសៗគ្នាដោយបញ្ជាក់ថា៖ «សម្រាប់គ្រួសារវ័យក្មេងដែលដៃគូកើតក្នុងទសវត្សរ៍ឆ្នាំ៩០ ជាធម្មតាអ្នករាល់គ្នាក្នុងគ្រួសារចេះជួយគ្នាធ្វើការងារផ្ទះគ្នា។ ប៉ុន្តែសម្រាប់ [គូស្វាមីភរិយា] វ័យចំណាស់ ដូចជាជីដូនជីតា ភាគច្រើនពួកគាត់គិតថា ស្ត្រីគឺជាអ្នកទទួលខុសត្រូវលើការធ្វើការងារផ្ទះភាគច្រើន” (ស្ត្រី Y១៤)។

រួមជាមួយនឹងទិន្នន័យស្ទង់មតិ លទ្ធផលរបកគំហើញទាក់ទងនឹងការផ្លាស់ប្តូរបរិបទសង្គមយ៉ាងឆាប់រហ័ស ដែលការយល់ឃើញនេះ នឹងត្រូវលើកមកបង្ហាញនៅលើទំព័រជាច្រើនបន្ទាប់ទៀត។ ដើម្បីឱ្យមានភាពច្បាស់លាស់ការយល់ឃើញទាំងនោះត្រូវបានបំបែករវាងការឆ្លើយតបដែលបង្ហាញអំពីភាពអវិជ្ជមាន (ការងារថែទាំគ្មានប្រាក់កម្រៃនៅតែដដែល) និងអ្នកដែលគិតវិជ្ជមាន ដែលបានអះអាងថាពេលវេលា និងការរំពឹងទុកលើចំណងអាពាហ៍ពិពាហ៍ពិតជាបានផ្លាស់ប្តូរ ទោះបីជាមានកិច្ចការតស៊ូមតិច្រើនទៀតដែលត្រូវធ្វើក៏ដោយ។

## ការផ្លាស់ប្តូរទស្សនៈទៅតាមជំនាន់?

# ការវិវត្តនៃបរិបទសង្គម (ត)

## ទស្សនៈអវិជ្ជមាន

*"ខ្ញុំគិតថាវានៅតែដដែល បុរសធ្វើការខាងក្រៅផ្ទះរកលុយ ស្ត្រីធ្វើការខាងក្នុងផ្ទះ" (ស្ត្រី ០៦)។*

ទោះបីជាអ្នកចូលរួមសម្ភាសន៍ និងអ្នកឆ្លើយតបការស្ទង់មតិភាគច្រើនបានរាយការណ៍អំពីទស្សនៈថា បរិបទសង្គមពិតជាមានការផ្លាស់ប្តូរ ហើយថាគូស្វាមីភរិយាកម្ពុជានាពេលបច្ចុប្បន្នកំពុងចែករំលែកបន្ទុកការងារថែទាំគ្មានប្រាក់កម្រៃទៅវិញទៅមកដោយស្មើភាពក៏ដោយ ក៏មានអ្នកចូលរួមមួយចំនួន បានបង្ហាញការយល់ឃើញផ្ទុយពីនេះដែរ។

*“តាមការសង្កេតជារួមរបស់ខ្ញុំ ព្រមទាំងបទពិសោធន៍នៃការធ្វើការជាមួយស្ត្រីរងគ្រោះដោយអំពើហិង្សា យើងឃើញថា ការបែងចែកការងាររវាងការងារក្នុង និងក្រៅផ្ទះ រវាងបុរស និងស្ត្រីនៅមិនទាន់មានការបែងចែកស្មើភាពគ្នានៅឡើយទេ។*

*ជាទូទៅ ការងារនៅក្នុងផ្ទះ គឺនៅតែជាបន្ទុកដ៏ធ្ងន់សម្រាប់ស្ត្រី ជាពិសេសនៅតាមជនបទ។*

*មានការផ្លាស់ប្តូរជាច្រើន ដោយមានការចូលរួមពីភាគីពាក់ព័ន្ធពីសង្គមស៊ីវិល ហើយសាលាក៏បានបញ្ជ្រាបបញ្ហានេះដែរ វាគ្រាន់តែនៅមិនទាន់រីកសាយភាយដល់ថ្នាក់មូលដ្ឋាននៅឡើយ»*

(ស្ត្រី C២)។

អ្នកចូលរួមទាំងនេះបានឆ្លុះបញ្ចាំងថា អាចមានកម្រិតនៃការបែងចែកឡើងវិញមួយចំនួន ប៉ុន្តែការបែងចែក មិនគ្រប់គ្រាន់ទាំងស្រុងទេ។ ឧទាហរណ៍ អ្នកចូលរួមជាយុវជនម្នាក់បានលើកឡើងថា មានប្រជាជនកម្ពុជា "ភាគរយតិចតួច" ប៉ុណ្ណោះ ដែលបានបែងចែកការងារថែទាំគ្មានប្រាក់កម្រៃស្មើៗគ្នា៖ "ខ្ញុំគិតថា មនុស្សម្នានៅតែគិតបែបនេះ [ថាបុរសជាអ្នករកស៊ីចិញ្ចឹម ហើយស្ត្រីជាស្ត្រីមេផ្ទះ]។ មានភាគរយតិចតួចណាស់ដែលឱ្យតម្លៃស្ត្រីស្មើនឹងបុរសក្នុងការបែងចែកការងារ ប៉ុន្តែស្ត្រីនៅតែធ្វើកិច្ចការផ្ទះច្រើនជាងបុរស” (បុរស Y៤)។

អ្នកចូលរួមផ្សេងទៀតបានលើកឡើងថា "មិនថាប្រព័ន្ធអប់រំមានការវិវឌ្ឍន៍ប៉ុណ្ណាក៏ដោយ" វានៅតែជាករណីដែល "ផ្នត់គំនិតនេះនៅតែមាន" ។ អ្នកចូលរួមដដែលបានរាយការណ៍ថា "មនុស្សជាច្រើននៅតែប្រកាន់ខ្ជាប់នូវផ្នត់គំនិតថាស្ត្រីគួរតែជាស្ត្រីមេផ្ទះ" ខណៈដែល "មានមនុស្សតិចតួចប៉ុណ្ណោះដែលបានផ្លាស់ប្តូរទស្សនៈនេះលើស្ត្រី" (បុរស ០៧)។

ជាចុងក្រោយ អ្នកចូលរួមជាស្ត្រីម្នាក់បានរាយការណ៍ថា បទដ្ឋានសង្គមប្រពៃណីមិនងាយនឹងឱ្យគេមើលរំលងនោះទេ ហើយថា [ស្ត្រីធ្វើការងារផ្ទះភាគច្រើន] ដោយសារតែផ្នត់គំនិតរបស់មនុស្សដែលប្រកាន់យកតាំងពីអតីតកាល [ដែល] បុរសជាអ្នកកំណត់ ឬដាក់ស្លាកថាការងារផ្ទះជារបស់ស្ត្រី។ ទោះបីជាសង្គមបានផ្លាស់ប្តូរក៏ដោយ ក៏មនុស្សនៅតែគិតថាវាជាការងាររបស់ស្ត្រី” (ស្ត្រី ០១)។

## ការវិវត្តនៃបរិបទសង្គម (ត)

ទស្សនៈបង្ហាញនូវក្ដីសង្ឃឹម៖ ‘ការអភិវឌ្ឍសមត្ថភាព និងផ្នត់គំនិត’

*«សម្រាប់គ្រួសារខ្ញុំ កាលពីយើងទើបតែរៀបការរួច គាត់មិនបានជួយធ្វើការផ្ទះទេ។ ប៉ុន្តែបីទៅបួនឆ្នាំក្រោយមក គាត់បានចាប់ផ្ដើមជួយការងារផ្ទះ ព្រោះខ្ញុំបានពន្យល់គាត់អំពីអ្វីទៅជាជីវិតគ្រួសារ - ពូថាយើងគួរជួយគ្នាទៅវិញទៅមក។ ដូច្នេះ គាត់បានផ្លាស់ប្ដូរឥរិយាបថ ដោយជួយខ្ញុំធ្វើកិច្ចការផ្ទះ។ ខ្ញុំបានពន្យល់គាត់ថា បើគាត់មកផ្ទះមុន គាត់គួរជួយដាំបាយ ឬធ្វើម្ហូប ហើយខ្ញុំនឹងធ្វើការងារផ្ទះនៅពេលដែលខ្ញុំមកមុន" (ការពិភាក្សាក្រុមគោលដៅរបស់ស្ត្រី)។*

សម្រាប់អ្នកដែលបានលើកទឡ្ហីករណ៍ថា មានការផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់ឆ្ពោះទៅរកយុត្តិធម៌កាន់តែច្រើននៅក្នុងការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃរវាងស្ត្រី និងបុរសនៅកម្ពុជា មនុស្សជាច្រើនបានពិភាក្សាអំពីការបង្កើតទម្រង់ចំណេះដឹងថ្មីៗតាមយេនឌ័រនីមួយៗ៖ ឧទាហរណ៍ ស្ត្រីពិតជាបានទទួលបានការអប់រំ និងការបណ្ដុះបណ្ដាលជំនាញកាន់តែច្រើន (ការស្រាវជ្រាវអ្វីដែលខ្លួនឯងចូលចិត្តផ្សេងទៀត) ប៉ុន្តែ ជាសំខាន់ បុរសក៏បានអភិវឌ្ឍសមត្ថភាពរបស់ពួកគេផ្ទាល់ទាក់ទងនឹងការងារថែទាំគ្មានប្រាក់កម្រៃផងដែរ៖ "កាលពីអតីតកាលមនុស្សស្រី... ត្រូវតែទទួលខុសត្រូវលើការងារផ្ទះទាំងអស់។ ប៉ុន្តែឥឡូវបុរសមានចំណេះដឹងកាន់តែច្រើន ហើយពួកគេបានរៀនពីរបៀបចែករំលែកការងារផ្ទះ។ ដូច្នេះឥឡូវនេះ បុរសក៏អាចបោកគក់ និងមើលថែទាំកូនដូចស្ត្រីដែរ" (ការពិភាក្សាក្រុមគោលដៅបុរស)

ស្រដៀងគ្នានេះដែរ អ្នកផ្សេងទៀតបានលើកទឡ្ហីករណ៍ថា អ្វីដែលបានកើតឡើងគឺជាការផ្លាស់ប្ដូរផ្នត់គំនិតជាមូលដ្ឋាន។ ចំណុចនេះគឺទាក់ទងនឹងស្ត្រី៖ "[អ្វីដែល] នាំទៅរកការផ្លាស់ប្ដូរ គឺការបង្កើនការយល់ដឹងរបស់ស្ត្រី" (ការពិភាក្សាក្រុមគោលដៅស្ត្រី) ឬបុរស៖ “ក្នុងបរិបទសព្វថ្ងៃនេះ ខ្ញុំគិតថាមនុស្ស ជាពិសេសបុរសមិនគិតថាវាជាការងាររបស់ស្ត្រីទេនៅពេលនិយាយអំពីការងារផ្ទះ។ នេះក៏ព្រោះតែបុរសមានការបើកចំហចិត្តទូលាយជាងមុន។ ខ្ញុំអាចនិយាយបានថាមានតែ ៥០% ប៉ុណ្ណោះដែលនៅតែគិតបែបនេះ” (ស្ត្រី Y១៦)។

អ្នកឆ្លើយតបជាបុរសម្នាក់បានឆ្លុះបញ្ចាំងឱ្យឃើញអំពីផលប៉ះពាល់ដែលការបណ្ដុះបណ្ដាលសមភាពយេនឌ័រមានមកលើទស្សនៈផ្ទាល់ខ្លួនរបស់គាត់ ដែលចំពោះគាត់ "បុរសធម្មតាធ្វើការងារផ្ទះ" (បុរស C៥) ខណៈពេលដែលម្នាក់ទៀតពន្យល់ថាស្ត្រីគួរធ្វើការងារថែទាំគ្មានប្រាក់កម្រៃទាំងអស់ "... គឺជា ផ្នត់គំនិតចាស់គំរឹលតាំងពីបុរាណមក ប៉ុន្តែក្នុងសង្គមទំនើប យើងមិនចាំបាច់ពឹងតែលើស្ត្រីធ្វើកិច្ចការផ្ទះទេ បុរសក៏អាចធ្វើបានដែរ” (បុរស O៥)។

# ការវិវត្តនៃបរិបទសង្គម (ត)

## ទស្សនៈបង្ហាញនូវក្តីសង្ឃឹម៖ ផ្នែកអប់រំ

*"ស្ត្រីមានសិទ្ធិ។ វាបានផ្លាស់ប្តូរហើយ... ក្នុងជំនាន់របស់ខ្ញុំ យើងមិនបានទទួលការអប់រំ ដូច្នេះយើងក៏នៅផ្ទះ... ប៉ុន្តែឥឡូវនេះ ស្ត្រីបានទទួលការអប់រំ ពួកគេអាចរកប្រាក់បានដោយខ្លួនឯង... ស្ត្រីវ័យក្មេងអាចទៅធ្វើការនៅរោងចក្រ ប៉ុន្តែសម្រាប់ស្ត្រីវ័យចំណាស់ គឺពួកយើងនៅផ្ទះ" (ស្ត្រី O៦)។*




**គំនូសសម្គាល់ទី ១៣៖ តើអ្នកណាធ្វើការងារផ្ទះច្រើនជាងគេក្នុងគ្រួសាររបស់អ្នក, រវាងបងប្អូនបង្កើត?**




**គំនូសសម្គាល់ទី ១៤៖ តើអ្នកណាធ្វើការងារផ្ទះច្រើនជាងគេក្នុងគ្រួសាររបស់អ្នក រវាងជីដូនជីតា?**

អ្នកឆ្លើយតបមួយចំនួនធំបានអះអាងថា បុរសកំពុងធ្វើការងារផ្ទះច្រើនជាងអ្វីដែលពួកគេធ្លាប់ធ្វើកាលពីជំនាន់មុន ដោយសារតែស្ត្រី និងក្មេងស្រីមានលទ្ធភាពទទួលបានការអប់រំកើនឡើង។ អ្នកខ្លះបានឆ្លុះបញ្ចាំងអំពីការបាត់បង់ការសិក្សារបស់ម្តាយពួកគេដែលបណ្តាលឱ្យពួកគេបំពេញការងារថៃទាំពេញម៉ោងដោយមិនមានឱកាសស្វែងរកជម្រើសផ្សេងទៀត៖ “ឥឡូវនេះ វាខុសគ្នា ស្ត្រីមានសិទ្ធិ និងទទួលបានការអប់រំ។ ស្ត្រីអាចចេញទៅធ្វើការដូចបុរសបាន។ [ប៉ុន្តែ] ជំនាន់ម្តាយខ្ញុំ ពួកគាត់មិនចេះអក្សរទេ។ ម្តាយរបស់ខ្ញុំគ្រាន់តែនៅផ្ទះ ហើយគាត់មិនអាចអាន ឬសរសេរអក្សរបានទេ។ ខ្ញុំមិនវិនិច្ឆ័យម្តាយរបស់ខ្ញុំទេ - នៅពេលនោះ គាត់មិនមានសិទ្ធិទៅសាលារៀនទេ ហើយគាត់គ្រាន់តែនៅផ្ទះដើម្បីធ្វើកិច្ចការផ្ទះ។ ទោះយ៉ាងណាក៏ដោយ វាមានភាពល្អប្រសើរឡើងនៅក្នុងជំនាន់របស់ខ្ញុំ" (ស្ត្រី Y៨) ។

អ្នកចូលរួមជាបុរសក៏បានសង្កត់ធ្ងន់លើតួនាទីនៃការអប់រំក្នុងការផ្លាស់ប្តូររបៀបនៃការទំនាក់ទំនងឆ្ពោះទៅរកតុល្យភាពនៃការងារដែលមានប្រាក់កម្រៃ និងគ្មានប្រាក់កម្រៃ៖ "កាលពីអតីតកាល ស្ត្រីផ្តោតលើការងារផ្ទះ [ប៉ុន្តែ] ឥឡូវនេះទាំងបុរស និងស្ត្រីទទួលបានការអប់រំយ៉ាងល្អប្រសើរ" (បុរស O៤)។

ទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលអ្នកចូលរួមយល់ឃើញថាមានវឌ្ឍនភាពក៏ដោយ ហើយ "ក្មេងជំនាន់ក្រោយហាក់ដូចជាជួយច្រើនទៅលើ... ទំនួលខុសត្រូវក្នុងគ្រួសារ" (ស្ត្រី O១) គំនូសតាងខាងលើបង្ហាញថាក្មេងស្រីនៅតែត្រូវបានគេមើលឃើញថាមានទំនួលខុសត្រូវខ្ពស់ក្នុងការបំពេញការងារផ្ទះជាងក្មេងប្រុស។

# ការវិវត្តនៃបរិបទសង្គម (ត)

## ទស្សនៈបង្ហាញនូវក្តីសង្ឃឹមៈ ផ្នែកមុខរបរ




**គំនូសសម្គាល់ទី ១៥៖ តើអ្នកគិតថាគូស្វាមីភរិយាវ័យក្មេង (អាយុក្រោម ៣៥ ឆ្នាំ) កំពុងចែករំលែកកិច្ចការផ្ទះស្មើៗគ្នាជាងឪពុកម្តាយរបស់ពួកគេដែរឬទេ?**

ទន្ទឹមនឹងការផ្លាស់ប្តូរផ្នត់គំនិត និងលទ្ធភាពទទួលបានការអប់រំ ប្រធានបទទីបីដែលបានពិភាក្សាដោយអ្នកចូលរួមដែលបានអះអាងថា គូស្វាមីភរិយាកម្ពុជាកំពុងតែចែករំលែកការងារថៃទាំគ្មានប្រាក់កម្រៃដោយស្មើភាពជាងនោះ គឺជាឱកាសការងារ។ ឧទាហរណ៍ អ្នកចូលរួមសម្ភាសន៍ជាស្ត្រីវ័យចំណាស់ម្នាក់បានរាយការណ៍ថា៖ "សព្វថ្ងៃនេះ យើងឃើញថា សូម្បីតែស្ត្រីក៏រកការងារ និងឱកាសដែរ... [ពួកគេ] អាចទទួលបានការអប់រំប្រកបដោយគុណភាព ការបណ្តុះបណ្តាល និងឱកាសពង្រឹងសមត្ថភាពផ្សេងទៀត។ ដូច្នេះ មានការផ្លាស់ប្តូរដោយគ្មានការសង្ស័យ... សូម្បីតែស្ត្រីនៅជនបទក៏កំពុងស្វែងរកការងារធ្វើដែរ។ ដូច្នេះខ្ញុំគិតថាមានការផ្លាស់ប្តូរខ្លះ [នៅឆ្ងាយពីគំនិតដែលថា] ស្ត្រីគួរតែជាស្ត្រីមេផ្ទះ ហើយបុរសជាអ្នករកស៊ីចិញ្ចឹម" (ស្ត្រី O១)។

ចំណុចនេះត្រូវបានគេមើលឃើញថាជានិន្នាការវិជ្ជមាន សូម្បីតែស្ត្រីដែលមើលឃើញខ្លួនឯងថាចាស់ពេកមិនអាចទទួលបានប្រយោជន៍ពីការងារនេះ៖ "មនុស្សសព្វថ្ងៃនេះទទួលបានឱកាសកាន់តែប្រសើរឡើង ស្ត្រីក៏អាចរកប្រាក់បានដែរ ដែលខុសពីជំនាន់របស់ខ្ញុំ យើងគ្រាន់តែធ្វើការក្នុងផ្ទះបាយ" (ស្ត្រី O៦)។

ទោះជាយ៉ាងណាក៏ដោយ ជាថ្មីម្តងទៀត វាជារឿងសំខាន់ដែលត្រូវកត់សម្គាល់ថា ទោះបីជាអ្នកចូលរួមភាគច្រើនបានរាយការណ៍ថាបរិបទសង្គមកំពុងតែផ្លាស់ប្តូរយ៉ាងឆាប់រហ័សទាក់ទងនឹងការបែងចែកការងារថៃទាំគ្មានប្រាក់កម្រៃប្រកបដោយយុត្តិធម៌ក៏ដោយ ក៏យុត្តិធម៌ និងសមភាពពិតប្រាកហាក់នៅឆ្ងាយពីការពិតនៅឡើយ ដោយមានជាង ២/៣ (៦៨%) នៃអ្នកឆ្លើយតបការស្ទង់មតិប៉ុណ្ណោះ ដែលបង្ហាញថា នៅក្នុងគូស្វាមីភរិយាវ័យក្មេងរបស់កម្ពុជា ស្ត្រីនៅតែបំពេញការងារថៃទាំគ្មានប្រាក់កម្រៃច្រើនជាងបុរស

# សេចក្ដីសន្និដ្ឋាន

# ៨
# សេចក្តីសន្និដ្ឋាន

របាយការណ៍នេះមានគោលបំណងធ្វើការឈ្វេងយល់អំពីការយល់ឃើញនាពេលបច្ចុប្បន្នរបស់បុរស និងស្ត្រីកម្ពុជាដែលមានអាយុ យេនឌ័រ ស្ថានភាពសេដ្ឋកិច្ច និងនិន្នាការភេទខុសៗគ្នា ចំពោះការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃ និងបន្ទុកផ្លូវចិត្ត។

ទោះបីជាឯកសារផ្នែកសិក្សាធិការនិងការសិក្សាស្រាវជ្រាវបែបគុណវិស័យទ្រង់ទ្រាយធំពីមុនៗបានចង្អុលបង្ហាញថា ស្ត្រីដែលស្ថិតក្នុងទំនាក់ទំនងផ្លូវភេទភេទផ្ទុយគ្នា បានចំណាយពេលវេលាប្រចាំថ្ងៃដើម្បីបំពេញការងារថែទាំគ្មានប្រាក់កម្រៃច្រើនលើសលុបជាបុរសក្តី ក៏ការសិក្សាស្រាវជ្រាវនេះធ្វើការឈ្វេងយល់ពីការយល់ឃើញរបស់ប្រជាជនកម្ពុជាចំពោះបញ្ហានេះ។ តើវិសមភាពនៃការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃក្នុងចំណោមស្ត្រី និងក្មេងស្រី ត្រូវបានចាត់ទុកថាជាបញ្ហាដែរឬទេ? តើការងារផ្ទះគួរតែចែករំលែកដោយរបៀបណារវាងសមាជិកគ្រួសារនៅក្នុងពិភពដែលឥតខ្ចោះនោះ? តើបន្ទុកផ្លូវចិត្តមានផលប៉ះពាល់អ្វីខ្លះដល់ស្ត្រីកម្ពុជា ហើយតើបុរសទទួលស្គាល់ពលកម្មបញ្ញាជាបញ្ហាយេនឌ័រដែរឬទេ?

សំណួរទាំងអស់នេះ និងសំណួរជាច្រើនទៀតទាក់ទងនឹងការយល់ឃើញអំពីការងារថែទាំគ្មានប្រាក់កម្រៃ និងបន្ទុកផ្លូវចិត្តត្រូវបានឈ្វេងយល់នៅក្នុងរបាយការណ៍នេះទាំងស្រុង។ ទោះបីជាអ្នកចូលរួមបានទទួលស្គាល់យ៉ាងច្រើនលើសលប់ថា ការងារថែទាំគ្មានប្រាក់កម្រៃបច្ចុប្បន្នមិនត្រូវបានចែករំលែកដោយស្មើភាពរវាងគូស្វាមីភរិយាក្តី ក៏ពួកគេបានរាយការណ៍អំពីការយល់ឃើញមួយដែលបង្ហាញថា ក្មេងជំនាន់ក្រោយបានផ្លាស់ប្តូរឆ្ពោះទៅរកតុល្យភាពកាន់តែស្មើគ្នា ហើយថានេះគឺជារឿងល្អ។

អ្នកចូលរួមបានពណ៌នាអំពីកត្តាជម្រុញចម្បងៗដែលពួកគេយល់ថាបានរួមចំណែកក្នុងការរក្សាអតុល្យភាពបច្ចុប្បន្ននៅក្នុងការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃ ក្នុងនោះរួម កត្តាវប្បធម៌ សង្គម អន្តរជំនាន់ និង/ឬភូមិសាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលត្រូវបានសាកសួរ មានតែអ្នកចូលរួមចំនួនតូចប៉ុណ្ណោះដែលបង្ហាញអំពីអារម្មណ៍គាំទ្រដល់ការរក្សាស្ថានភាពបច្ចុប្បន្ន ជុំវិញការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃ។ ប្រការនេះក៏ជាករណីទាក់ទងនឹងបន្ទុកផ្លូវចិត្តផងដែរ នៅពេលសាកសួរអំពីយោបល់អ្នកចូលរួមលើតួនាទីរបស់ស្ត្រីនៃ 'អ្នកគ្រប់គ្រងផែនការ' - ខណៈដែលអ្នកខ្លះយល់ថា តួនាទីនេះគួរតែត្រូវបានរក្សា អ្នកខ្លះទៀតមិនយល់ស្របយ៉ាងខ្លាំងដូចការដកស្រង់ខាងក្រោម៖

*"ការងារផ្ទះគឺជាការងារផ្ទះ៖ វាមិនបញ្ជាក់អំពីយេនឌ័រទេ វាមិនមែនសម្រាប់យេនឌ័រមួយដើម្បីធ្វើ និងម្ខាងទៀតគ្រាន់តែ 'ជួយ' នោះទេ។ <u>ជាធម្មតា អ្នកគ្រប់គ្រងគឺហត់នឿយជាងអ្នកជួយ</u> នេះហើយជាមូលហេតុដែលខ្ញុំចង់ឱ្យផ្នត់គំនិតនេះផ្លាស់ប្តូរ។ ខ្ញុំចង់ឱ្យបុរសធ្វើការផ្ទះផងដែរ មិនមែនគ្រាន់តែជាអ្នកជួយទេ។ ខ្ញុំចង់បានការបែងចែកការងារស្មើភាពគ្នា" (ស្ត្រី Y២)។*

# សេចក្តីសន្និដ្ឋាន (ត)

របកគំហើញនៃសិក្សាស្រាវជ្រាវនេះបានកំណត់យ៉ាងច្បាស់ថា ប្រជាជនកម្ពុជាភាគច្រើនគាំទ្រឱ្យបែងចែកការងារថែទាំគ្មានប្រាក់កម្រៃមានស្មើភាពគ្នាជាងនេះ តើមានអ្វីខ្លះដែលអាចធ្វើបាន? អ្នកចូលរួមជាបុរសមកពីអង្គការសង្គមស៊ីវិល បានចែករំលែកគំនិតជាច្រើនក្នុងរឿងនេះ ចាប់ពីផ្តើមដោយ ការផ្តួចផ្តើមគំនិតគោលនយោបាយដោយរដ្ឋាភិបាល "បុរសឆ្នើម [ដែលអាច] ជួយជំរុញរបៀបវារៈសមភាពយេនឌ័រ [ហើយ] នឹងផ្លាស់ប្តូរឥរិយាបថរបស់បុរសបានយ៉ាងមានឥទ្ធិពល" (បុរស C៥) ទៅរកវិធានការកាន់តែមានភាពសមស្របគ្រប់ជ្រុងជ្រោយជាងនេះទៅទៀត៖

“ខ្ញុំគិតថា យើងគួរតែលើកកម្ពស់តម្លៃនៃការអប់រំ និងធ្វើជាគំរូល្អសម្រាប់មនុស្សជំនាន់ក្រោយ ដើម្បីធានាថាពួកគេយល់ថាការងារផ្ទះមិនមែនជាទំនួលខុសត្រូវរបស់យេនឌ័រតែមួយនោះទេ។ យើងជាបុរសគួរតែធ្វើការងារផ្ទះជាធម្មតា... ហើយ [ក្នុងនាមជាអ្នកតស៊ូមតិ] បង្កើតការផ្សាយពាណិជ្ជកម្មសម្រាប់វីដេអូអប់រំ ឬការពិភាក្សាជាក្រុមសហគមន៍។ ខ្លួនខ្ញុំផ្ទាល់បានលើកកម្ពស់ការពិភាក្សាជាក្រុមជាមួយមិត្តភក្តិនៅសកលវិទ្យាល័យរបស់ខ្ញុំពីមុនមក ហើយវាមានឥទ្ធិពលខ្លាំងណាស់ក្នុងការផ្លាស់ប្តូរសកម្មភាពរបស់ពួកគេ នៅពេលដែលយើងចែករំលែកដំបូន្មានដោយស្មោះត្រង់ និងការពិតដល់គ្នាទៅវិញទៅមក” (បុរស C៣)។

អ្នកឆ្លើយតបជាបុរសម្នាក់ទៀតមកពីអង្គការសង្គមស៊ីវិល បានគូសបញ្ជាក់ថា ជាការសំខាន់ណាស់មិនត្រឹមតែលើកទឹកចិត្តស្ត្រីឱ្យបន្តក្តីសុបិនរបស់ពួកគេ - ទាំងក្នុង និងក្រៅផ្ទះ -ប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងឱ្យស្ត្រីទាំងនោះធ្វើការជាអ្នកផ្តល់សេវាការងារថែទាំគ្មានប្រាក់កម្រៃពេញម៉ោង អ្នកតស៊ូមតិគួរតែធ្វើយ៉ាងណាធានាថា ស្ត្រីទាំងនោះ អាចមានសិទ្ធិច្រើននៅក្នុងខ្លួន និងក្នុងគ្រួសាររបស់ពួកគេ ដើម្បីជៀសវាងការកេងប្រវ័ញ្ច និងភាពងាយរងគ្រោះ។

អ្នកឆ្លើយតបជាស្ត្រីមកពីអង្គការសង្គមស៊ីវិល ក៏បានផ្តល់គំនិតលម្អិតអំពីរបៀបដែលអ្នកតស៊ូមតិសមភាពយេនឌ័រអាចជំរុញឱ្យមានការផ្លាស់ប្តូរ រួមទាំងការលើកទឹកចិត្តដល់ភ្នាក់ងាររដ្ឋដែលមានកាតព្វកិច្ចដូចជា ក្រសួងកិច្ចការនារី ឱ្យអភិវឌ្ឍន៍ តាមដាន និងអនុវត្តសកម្មភាពដើម្បីផ្លាស់ប្តូរឥរិយាបថ និងផ្នត់គំនិតអំពីការងារថែទាំគ្មានប្រាក់កម្រៃ។ អ្នកផ្តល់ការអប់រំ និងតួអង្គពាក់ព័ន្ធរបស់រដ្ឋាភិបាលក៏គួរតែ "ផ្តល់ការអប់រំតាំងពីថ្នាក់មត្តេយ្យសិក្សា ដើម្បីផ្លាស់ប្តូរផ្នត់គំនិតក្មេងជំនាន់ក្រោយ ដើម្បីឱ្យកុមារយល់ដឹងអំពីទំនួលខុសត្រូវទាំងនេះ និងតម្លៃនៃការងារ ទាំងការងារទទួលបានប្រាក់កម្រៃ និងការងារគ្មានប្រាក់កម្រៃ... នៅក្នុងកម្មវិធីសិក្សាតួនាទីទាំងអស់ត្រូវតែពន្យល់ពួកគេថាជាកាតព្វកិច្ចរួម... [ព្រោះ] ត្រូវតែមានការផ្លាស់ប្តូរ” (ស្ត្រី C២)។

អ្នកចូលរួមដែលបានណែនាំថា ក៏ដូចជាបុរសដែលមានទំនោរ និងទទួលយកការងារថែទាំគ្មានប្រាក់កម្រៃដែរ ស្ត្រីត្រូវតែចែករំលែក និងទំនាក់ទំនងជាមួយដៃគូរបស់ពួកគេ។ នេះគឺដោយសារតែការដាក់បញ្ចូលបទដ្ឋានសង្គមដែលអាចនាំឱ្យស្ត្រីទទួលយកយ៉ាងសកម្មលើការងារថែទាំគ្មានប្រាក់កម្រៃភាគច្រើន ទោះបីជាពួកគេមានកាលវិភាគមមាញឹកក៏ដោយ៖ "ប្រសិនបើយើងមិននិយាយពីក្តីកង្វល់របស់យើងជាមួយដៃគូរបស់យើង ហើយយើងនៅតែកាន់ទំនួលខុសត្រូវនោះតែខ្លួនឯង [ស្ត្រីអាច] នឹងកាន់តែនឿយហត់ខ្លួនឯង។ ពេលខ្លះ ការពិភាក្សាជាមួយដៃគូអាចធ្វើឱ្យប្តីមើលឃើញអំពីស្ថានភាពពិត ឃើញថាហេតុអ្វីបានជាយើងលើកឡើងអំពីតម្រូវការជាក់លាក់របស់យើង ហើយអាចផ្លាស់ប្តូររបៀបនៃការគិតរបស់យើងបាន។"

ជាចុងក្រោយ សេចក្តីបញ្ចប់ខាងក្រោមនេះ ក៏មានសម្រង់សម្តីដ៏សាមញ្ញដែលសង្ខេបការឆ្លើយតបជាច្រើនដោយអ្នកចូលរួមជាស្ត្រីចំពោះសំណួរអំពីរបៀបដែលសមធម៌នៅក្នុងការបែងចែកការងារថែទាំគ្មានប្រាក់កម្រៃអាចសម្រេចបាននៅទីបំផុត៖

***"យើងគ្រាន់តែត្រូវការឱ្យមនុស្សបោះបង់ជំនឿ និងផ្នត់គំនិតដែលថា "ការងារនេះជារបស់ស្ត្រី" និង "ការងារនោះជារបស់បុរស" (ស្ត្រី Y៨)។***

# ឯកសារយោង

1. ILO (2018) 'ILO: នៅអាស៊ី និងប៉ាស៊ីហ្វិក ស្ត្រីធ្វើការងារថែទាំគ្មានប្រាក់កម្រៃ ច្រើនជាងបុរស ៤ ដង'

2. Ibid.

3. OECD (2019) 'ហេតុអ្វីបានជាយើងគួរខ្វល់ខ្វាយអំពីការងារថែទាំគ្មានប្រាក់កម្រៃ'

4. ActionAid International (2015) 'ការងារថែទាំគ្មានប្រាក់កម្រៃ ៣- ការងារថែទាំ និងសិទ្ធិមនុស្ស'

5. Ibid.

6. អង្គការ ស្ត្រីដើម្បីសន្តិភាព (2020) 'រក្សាភាពសុខដុមរមនា ឬរារាំងភាពយុត្តិធម៌?'

7. UN ESCAP (2022) 'ការឲ្យតម្លៃ និងការវិនិយោគលើការងារថែទាំគ្មានប្រាក់កម្រៃ និងការងារក្នុងផ្ទះ៖ កម្ពុជា។'

8. UNDP (2013) 'ភាពជាដៃគូសម្រាប់សមភាពយេនឌ័រ ដំណាក់កាលទី៤'

9. Dean, L., Churchill, B. & Ruppanner, L. (2022) 'បន្ទុកផ្លូវចិត្ត៖ ការកសាងការយល់ដឹងផ្នែកទ្រឹស្តីឲ្យកាន់តែស៊ីជម្រៅទៅលើរបៀបដែលពលកម្មខួរក្បាល និងអារម្មណ៍បន្ថែមបន្ទុកលើសលប់លើស្ត្រី និងម្តាយ។' សហគមន៍, ការងារ & គ្រួសារ, 25(1), pp.13-29

10. Cambodia Knits, (2020) 'គ្មានកម្លាំងណាខ្លាំងជាងការតាំងចិត្តងើបឡើងវិញរបស់ស្ត្រីនោះទេ។'

11. APWLD (2018) 'ការស្រាវជ្រាវតាមបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម (FPAR)', APWLD

12. Braun, V. & Clarke, V. (2013) 'ការស្រាវជ្រាវបែបគុណវិស័យ៖ ការណែនាំសម្រាប់អ្នកចាប់ផ្តើមដំបូង.' London: Sage Publications

13. ILO (2018b), 'ការងារថែទាំ និងមុខរបរថែទាំសម្រាប់អនាគតនៃការងារសមរម្យ'

14. The Nation (2022) 'Anne Hathaway អំពាវនាវដល់សហគមន៍ធុរកិច្ចពិភពលោកឱ្យដាក់ស្ត្រីជាអាទិភាព,' The Nation

15. Anton, M. (2020) 'ចែករំលែកការយកចិត្តទុកដាក់! ធ្វើឱ្យការងារថែទាំជាការងារមានតម្លៃ,' កាសែតភ្នំពេញប៉ុស្តិ៍

16. Heng, M. (2022) 'សម្រាប់ស្ត្រីកម្ពុជា សមភាពចាប់ផ្តើមនៅក្នុងផ្ទះ', The Diplomat

17. UNESCAP (2022) 'ការឲ្យតម្លៃ និងការវិនិយោគលើការងារថែទាំគ្មានប្រាក់កម្រៃ និងការងារក្នុងផ្ទះ៖ កម្ពុជា។'

18. ActionAid UK (2021) Blog: 'ការងារថែទាំគ្មានប្រាក់កម្រៃ និងការងារក្នុងផ្ទះ'

19. Dean et al, above n., 9.

20. Sarrasanti, N., F. K. Donkor, C. Santos, M. Tsagkari and C. Wannous (2020), "ដល់ពេលដែលយើងយកចិត្តទុកដាក់លើពិភពលោកប្រកបដោយសមធម៌៖ ការងារថែទាំគ្មានប្រាក់កម្រៃរបស់ស្ត្រី និង មេរោគកូវីដ ១៩," in IEEE Engineering Management Review, vol. 48, no. 4, pp. 37-45

21. ILO (2018a) above n., 1.

22. Hasanbasri, A., Kilic, T., Koolwal, G., & Moylan, H. (2021) 'ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងការប្រើប្រាស់ពេលវេលា៖ ភស្តុតាងពីកម្ពុជា។'

23. CDRI (2022) 'សេដ្ឋកិច្ចដែលគិតគូរពីការថែទាំ និងការងារថែទាំគ្មានកម្រៃរបស់ស្ត្រីនៅកម្ពុជា'
24. Oxfam Cambodia (2021) 'អនុសាសន៍សម្រាប់ក្របខណ្ឌកិច្ចគាំពារសង្គមដែលផ្តល់អំណាចដល់ស្ត្រីក្នុងអាស៊ាន'

25. UN ESCAP (2022) above n., 7.

26. Oxfam Cambodia (2021), above n., 24.

27. Brickell, K. & Chant, S. (2010) 'ភាពធ្ងន់ដែលមិនអាចទ្រាំទ្របាន' ការឆ្លុះបញ្ចាំងពីភាពគិតគូរ និងខ្វាយខ្វល់របស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា ហ្វីលីពីន ហ្គាំប៊ី និងកូស្តារីកា', The Gambia and Costa Rica,' Progress in Development Studies, 10(2), pp.145-159

28. Brickell, K. (2011a) 'យើងមិនភ្លេចទំនៀមទំលាប់ចាស់ទេព្រោះតែទំនៀមទំលាប់ថ្មីទេ'៖ សុន្ទរកថាស្តីពីឧត្តមគតិ និងការអនុវត្តរបស់ស្ត្រីក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន' Signs: Journal of Women in Culture and Society, 36(2), pp.437-462

29. Brickell, K. (2011b) ស្នាមប្រឡាក់ដែលរាំងស្ទះការសម្រេចបាននៃការអភិវឌ្ឍន៍៖ ការ (មិន) ចូលរួមចំណែកក្នុងការធ្វើការងារផ្ទះដោយសារតែអត្តន័យយេនឌ័រនៅប្រទេសកម្ពុជា. Journal of Development Studies, 47(9), pp.1353-1370

30. Nakagawa, K. (2019), 'ការផ្លាស់ប្តូរបទដ្ឋានសង្គមដើម្បីសមភាពយេនឌ័រ៖ ភាពជាបុរស និង អំពើហិង្សាផ្អែកលើយេនឌ័រនៅកម្ពុជា'

31. Trading Economics (2020) 'កម្ពុជា - ប្រើអ៊ីនធឺណិតក្នុងកម្រិតបុគ្គល (ភាគរយនៃចំនួនប្រជាជន)'

32. Coffey, C., Espinoza Revollo, P., Harvey, R., Lawson, M., Parvez Butt, A., Piaget, K., Sarosi, D. and Thekkudan, J. (2020) ដល់ពេលត្រូវយកចិត្តទុកដាក់៖ ការងារថែទាំមិនទទួលបានប្រាក់កម្រៃ និង បានកម្រៃមិនសមរម្យ និងវិបត្តិវិសមភាពសកល. Oxfam.

33. ActionAid International (2015) above n., 4.

34. ILO (2018b), above n., 13, p. xxxi.

35. ILO (2018a), above n., 1.

36. Heng, M. (2022), above n., 16.

37. Ibid.

38. Gammage, S., Sultana, N., & Mouron, M., (2019) ‘ការបាត់បង់ដែលមើលមិនឃើញដោយសារការផ្តល់ការថែទាំដោយមិនទទួលបានកម្រៃ’

39. Retka, J. (2018) ‘ការផ្លាស់ប្តូរក្នុងវិស័យធនាគារ,’ The Southeast Asia Globe

40. Ibid.

41. Dean, L., Churchill, B. & Ruppanner, L. (2022), above n., 9.

42. Anderson, E. and Grace, K. (2018) ពីសិស្សសាលាទៅជាស្ត្រីខ្មែរដែលមាន“គុណធម៌”៖ 43. ការចោទសួរលើច្បាប់ស្រី និងយេនឌ័រក្នុងគោលនយោបាយអប់រំកម្ពុជា. Studies in Social Justice, 12(2), p. 216.

43. Ibid.

44. British Library (website) ‘ធម្មទានដល់យុវនារី’

45. Brickell, K. (2011b), above n., 29.

46. អង្គការ ស្ត្រីដើម្បីសន្តិភាព (2020) above n., 6.

47. Edwards, A. (2015), 'ជាពិភពលោករបស់បុរស៖ ឥទ្ធិពលនៃភាពជាបុរសបែបប្រពៃណីលើសមភាពយេនឌ័រ’

សម្រាប់ព័ត៌មានបន្ថែម ទំនាក់ទំនង៖ info@klahaan.org